# អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា (ខេប)

*"ការអភិវឌ្ឍមនុស្សប្រកបដោយសេចក្ដីថ្លៃថ្នូរ"*












# របាយការណ៍ប្រចាំឆ្នាំ ២០១៥

**៣០ មករា ២០១៦**

(អង្គការ ខេប បានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ ១៩៩៩)


| | |
|---|---|
| ការិយាល័យ: | សាលាគរុកោសល្យ និងវិក្រិតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម |
| ប្រអប់សំបុត្រ: | P.O Box ១៦២១ ភ្នំពេញ កម្ពុជា |
| ទូរស័ព្ទលើតុ: | ០៤២-០៩៤១-៤៨១ / ០៤២-៩៤១-៩១៨ |
| អ៊ីមែល: | kape@kapekh.org \| គេហទំព័រ: www.kapekh.org \| ទំព័របណ្ដាញសង្គម FB: www.facebook.com/kapeaction |
| **Linkedin:** | www.linkedin.com/company/kampuchean-action-for-primary-education |
| **Google Plus:** | www.plus.google.com/+KAPECambodia \| **YouTube:** www.youtube.com/TheKapeCambodia |

# មាតិកា


សារនាយកប្រតិបត្តិ....................................................................៣
សេចក្តីសង្ខេប.......................................................................... ៤
ការឆ្លុះបញ្ចាំង និងការឆ្ពោះទៅមុខ................................................. ៥


# កម្មវិធី


កម្មវិធី សាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) ................ ៦
គម្រោង សាលារៀនដៃគូ (BSI) ..........................................................៨
គម្រោង លើកកម្ពស់សេវាកម្មសុខភាពសាលារៀន (ISHS) ............... ១០
គម្រោង សៀវភៅសម្រាប់កម្ពុជា (BfC)...........................................១១
គម្រោង សាលារៀនល្អប្រសើរ (SfE) ..............................................១២
គម្រោង អប់រំកុមារ (EAC)..............................................................១៤
កម្មវិធី អប់រំបញ្ចូលគ្នា (IEP) ........................................................ ១៦
គម្រោង ខ្ញុំកំពុងរៀន! .................................................................... ២១
គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH) ..................................................................................... ២២
គម្រោង ងាយស្រួលរៀន (E2L)........................................................ ២៤
គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ (E4K) ................២៦
គម្រោង ពង្រឹងសិទ្ធិអំណាចយុវជនតាមរយៈការអប់រំ និងការតស៊ូមតិ (EYEA)................................................................................. ២៨

ព្រឹត្តិការណ៍សំខាន់ៗ និងការអភិវឌ្ឍក្នុងឆ្នាំនេះ................................. ២៩
បច្ចុប្បន្នភាពធនធានសិក្សា ខេប (TTS-KAPE) ................................៣៣
ការបង្ហាញហិរញ្ញវត្ថុក្នុងឆ្នាំ២០១៥.................................................៣៤
ក្រុមអ្នកគ្រប់គ្រងនៅក្នុងឆ្នាំ២០១៥ ............................................... ៣៥
រចនាសម្ព័ន្ធអង្គការ ខេប នៅក្នុងឆ្នាំ២០១៥.....................................៣៦


ខេប គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។ ខេប បានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ និងកម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកលវិទ្យាល័យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ១៥០.០០០ នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ ដែលបង្រៀននៅជាង ៤០០សាលាក្នុង ១១ខេត្ត។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេ តាមរយៈទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់អង្គការ ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី/ច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

## ក្រុមប្រឹក្សាភិបាល

- លោក ហ៊ាង គុយ — ប្រធាន
- លោក ប៊ុន ឫទ្ធី — អនុប្រធាន
- លោក ឃីត ប្រាឌិនបើក — ទីប្រឹក្សា-មិនបោះឆ្នោត
- លោក ធុច ថាត — សមាជិក
- លោកស្រី ហែម មណី — សមាជិក
- លោក ឆាយ ទីប៉ា — សមាជិក



បុគ្គលិកអង្គការ ខេប ឆ្នាំ២០១៥



# សារនាយកប្រតិបត្តិ

អង្គការ ខេប មានសេចក្តីសង្ឃឹម និងសុទិដ្ឋិនិយមទៅថ្ងៃអនាគត ដែល ខេប សូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំស្តីពីប្រតិបត្តិការរបស់ខ្លួនក្នុងឆ្នាំ២០១៥ នៃសារពើពន្ធ។ ក្នុងកំឡុងឆ្នាំនេះ អង្គការ ខេប បានសម្រេចការងារសំខាន់ៗ និងផែនការរយៈពេលវែងរបស់ខ្លួននៃអន្តរកាលពីការពឹងផ្អែកខ្លាំងលើការផ្តល់មូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) មកជាអង្គការមួយវិនិយោគមានតុល្យភាពជាងមុន។ បន្ទាប់ពីការបំពេញការងារកម្មវិធីសាកល្បងទប់ស្កាត់ការបោះបង់ការសិក្សា (SDPP) ដោយជោគជ័យនៅខែកញ្ញា ឆ្នាំ២០១៥ មក អង្គការ ខេប បានបញ្ចប់រយៈពេលបន្តឧបត្ថម្ភមូលនិធិកម្មវិធីពី USAIDដែលបានគាំទ្រថវិកាតាំងពីឆ្នាំ២០០៥។ ទោះបីជាមូលនិធិសរុបមានការធ្លាក់ចុះខ្លាំងពីចំណុចខ្ពស់ចំនួន៣លានដុល្លានៅកំឡុងឆ្នាំនេះក៏ដោយក៏អង្គការ ខេប អាចជំនួសបានពីជំនួយទ្វេភាគីដោយជោគជ័យ ដែលអង្គការ ខេប ទទួលមូលនិធិបានពីមូលនិធិឯកជនមានជាង ៨០% នៃធនធានដែលមាននាពេលបច្ចុប្បន្ន។ ម្យ៉ាងវិញទៀត មូលនិធិទទួលបានសរុបគឺស្ថិតនៅចន្លោះពី ១.៥ ទៅ ២លានដុល្លាអាមេរិក ដែលស្ថិតនៅក្នុងប្រវត្តិស្តង់ដាយ៉ាងខ្ពស់។

ការអភិវឌ្ឍដ៏មានសារៈសំខាន់នៅក្នុងឆ្នាំ២០១៥គឺកិច្ចចរចារព្រមព្រៀងដោយជោគជ័យជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់មូលនិធិផ្ទាល់ដល់គម្រោងសាលារៀនជំនាន់ថ្មី (NGS) ដែលជាគំនិតផ្តួចផ្តើមកំណែទម្រង់ថ្មី ត្រូវបានគាំទ្រដោយរដ្ឋមន្ត្រីថ្មី ឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន**។ ក្រសួងបានប្តេជ្ញាផ្តល់មូលនិធិជាង ៧០០.០០០ដុល្លាអាមេរិកសម្រាប់ឆ្នាំ២០១៦ និង ២០១៧ ដោយនេះគឺជាលើកដំបូងហើយដែលរដ្ឋាភិបាលបានផ្តល់មូលនិធិផ្ទាល់ដល់អង្គការសង្គមស៊ីវិលនៅក្នុងប្រវត្តិសាស្ត្រប្រព័ន្ធអប់រំ។ វាជាព្រឹត្តិការណ៍ផ្លាស់ប្តូរមួយដ៏សំខាន់ដែលបានផ្តល់ការលើកទឹកចិត្តដល់អង្គការ ខេប និងអង្គការសង្គមស៊ីវិលដទៃទៀតនៅក្នុងស្រុក។

អង្គការ ខេប ក៏បានបន្តបោះជំហានទៅមុខប្រកបដោយគំនិតច្នៃប្រឌិតជាចម្បងនៅក្នុងការធ្វើកម្មវិធី រួមមាន៖ ការអភិវឌ្ឍជោគជ័យលើស្តង់ដាអំណាន ដែលបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការអប់រំពិភពលោកក៏ ដូចជា សួសវ៉ែរ អេឡិចត្រូនិចសម្រាប់អំណាន គាំទ្រថវិកាដោយអង្គការ All Children Reading Grand Challenge។ ថវិកាពីអង្គការនេះគឺជាជោគជ័យដ៏ធំសម្រាប់អង្គការ ខេប ដែលជាអង្គការមួយបានទទួលមូលនិធិក្នុងចំណោមអង្គការទាំង១៤ ដែលបានដាក់ពាក្យស្នើសុំមូលនិធិនៅលើសកលលោក។ អង្គការ ខេប ក៏បានចាប់ផ្តើមដំណើរការកម្មវិធីបណ្ណាល័យអេឡិចត្រូនិចផងដែរ ដោយមានកិច្ចសហការជាមួយអង្គការមូលនិធិអាស៊ី។ កម្មវិធីទាំងអស់នេះបង្ហាញអំពីសមត្ថភាពរបស់អង្គការ ខេប ដែលមានពិសោធន៍បច្ចេកវិទ្យានៅក្នុងការអប់រំ។

អង្គការ ខេប ក៏បានចរចារជាមួយដៃគូដែលមានស្រាប់ និងដៃគូថ្មីៗជាច្រើនទៀតផងដែរ រួមមាន៖ ទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយអង្គការឆាលហ្វាន អូស្ត្រាលី និង Aide et Action ដែលបានផ្តល់ការគាំទ្រយ៉ាងច្រើនដល់កម្មវិធីអង្គការ ខេប។ កិច្ចទំនាក់ទំនងជាច្រើនក៏ត្រូវបានពង្រីកដោយជោគជ័យផងដែរដែលរួមមានអង្គការមូលនិធិ OakTree, Save the Children និង WeWorld។

ជាថ្មីម្តងទៀត អង្គការ ខេប សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍ និងរដ្ឋាភិបាលកម្ពុជាដែលជាដៃគូដ៏ជិតស្និទ ហើយអង្គការ ខេប នឹងឆ្ពោះទៅមុខបន្តភាពជោគជ័យក្នុងការជួយកុមារកម្ពុជា។

កំពង់ចាម ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៦

នាយកប្រតិបត្តិ

សៅ វណ្ណា

# សេចក្ដីសង្ខេប

នៅក្នុងឆ្នាំ២០១៥នេះ អង្គការ ខេប បានអនុវត្តគម្រោងសរុបចំនួន ១៤ នៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធ។ ការស្វែងរកមូលនិធិបានបន្តដំណើរការជោគជ័យយ៉ាងខ្លាំងដោយបានប្ដូរពីទទួលប្រភពមូលនិធិទ្វេភាគីមកជាមូលនិធិឯកជន។ ចំណូលថវិកាសរុបដែលបង្កើតបាននៅក្នុងអំឡុងឆ្នាំសារពើពន្ធនេះមានចំនួន **២.២៣១.៦៣៨,០៥** ដុល្លាអាមេរិក ដែលមានអត្រាប្រើប្រាស់ថវិកាខ្ពស់ **៩៤%**។ គម្រោងផ្សេងក្រៅពីគម្រោងទាំង១៤ដែលបានដាក់ស្នើនៅក្នុងឆ្នាំនេះ ទទួលបានជោគជ័យ លើកលែងតែគម្រោងចំនួនពីរ អំឡុងពេលគម្រោងមួយទៀងកំពុងរង់ចាំនៅឡើយ (សូមមើលតារាងនៅទំព័រទី៥)។ ខណៈពេលគម្រោងដាក់ស្នើមួយចំនួនមានលក្ខណៈតូច និងរយៈពេលខ្លី គម្រោងបានបង្ហាញពីលំដាប់មូលនិធិដ៏សំខាន់ និងភាពជាដៃគូរយៈពេលវែងជាពិសេស ករណីអង្គការឆាលហ្វាន និងអង្គការមូលនិធិ Oaktree។ ការមានសម្ព័ន្ធភាពជាមួយដៃគូអភិវឌ្ឍដទៃៗទៀត ដូចជា អង្គការ Save the Children អង្គការ WeWorld និងអង្គការមូលនិធិអាស៊ីបានបន្តសម្ព័ន្ធភាពតាំងពីបានបង្កើតឡើងដំបូងម្លេះ។




អង្គការ ខេប បានបន្តនាំមុខគេយ៉ាងសំខាន់នៅក្នុងវិស័យអប់រំផ្នែកបច្ចេកវិទ្យា ក៏ដូចជាការអភិវឌ្ឍគំរូសាលាធម្មនុញ្ញ (Charter School) នៅក្នុងបរិបទប្រទេសកម្ពុជា។ មកដល់បច្ចុប្បន្ននេះ អង្គការ ខេប ត្រូវក្រសួងអប់រំ យុវជន និងកីឡា ទទួលធ្វើជាដៃគូកំណែទម្រង់ការអប់រំថ្មីតាមរយៈគម្រោង សាលារៀនជំនាន់ថ្មី ឬហៅកាត់ថា NGS។ ការផ្ដួចផ្ដើមគម្រោងថ្មីនេះមានសក្ដានុពលចំពោះការផ្លាស់ប្ដូរប្រព័ន្ធអប់រំទូលំទូលាយដែលផ្ដោតលើស្វ័យភាពសាលា និងស្តង់ដាអភិបាលកិច្ចល្អ និងគុណភាពខ្ពស់។ គម្រោងនេះផ្អែកលើគំរូសាលាធម្មនុញ្ញដែលបានអភិវឌ្ឍចេញឡើងពីគម្រោង សាលារៀនដៃគូ ឧបត្ថម្ភដោយអង្គការមូលនិធិ Oaktree។ នៅក្នុងព្រឹត្តិការណ៍សំខាន់មួយទៀត ក្រសួងអប់រំ យុវជន និងកីឡា បានប្ដេជ្ញាផ្ដល់មូលនិធិផ្ទាល់ដល់អង្គការ ខេប ជាង ៧00.000 ដុល្លាអាមេរិក សម្រាប់ដំណើរការគម្រោងធំនេះ រួមទាំងការធ្វើការសិក្សាស្រាវជ្រាវទូទាំងប្រទេសដើម្បីកំណត់សក្ដានុពលបន្ថែមសម្រាប់គម្រោង NGS និងការបង្កើតគោលនយោបាយ។

## គម្រោងចំនួន ១៤ ក្នុងឆ្នាំ២០១៥

| | |
|---|---|
| SDPP | កម្មវិធី សាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា |
| BSI | គម្រោង សាលារៀនដៃគូ |
| ISHS | គម្រោង លើកកម្ពស់សេវាកម្មសុខភាពសាលារៀន |
| GEI | គម្រោង អប់រំកុមារី |
| CTSP | គម្រោង អាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ |
| PEI | គម្រោងអប់រំជនជាតិភាគតិចដើម |
| SfE | គម្រោង សាលារៀនល្អប្រសើរ |
| REACH (1&2) | គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ |
| EAC | គម្រោង អប់រំកុមារ |
| E2L | គម្រោង ងាយស្រួលរៀន |
| ILP/QLE | គម្រោង ខ្ញុំកំពុងរៀន! |
| BfC | គម្រោង សៀវភៅសម្រាប់កម្ពុជា |
| EYEA | គម្រោង ពង្រឹងសិទ្ធិអំណាចយុវជន និងការតស៊ូមតិ |
| E4K | គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ |

អង្គការ ខេប ក៏បានឈានមុខគេដ៏ច្រើនទៀតផងដែរនៅក្នុងកម្មវិធីអំណានថ្នាក់ដំបូងដោយបន្តកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការអប់រំពិភពលោកដើម្បីអភិវឌ្ឍស្តង់ដាអំណាន។ ដោយលំនាំទៅលើសាវតាការងារគម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC) អង្គការ ខេប បានបោះជំហានទៅមុខដោយបានបញ្ចប់ការងារស្តង់ដាអំណានសម្រាប់ថ្នាក់ទី៣នៅក្នុងឆ្នាំ២០១៥នេះ។ អង្គការ ខេប ក៏បានធ្វើការងារដ៏ជិតស្និទផងដែរជាមួយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់អភិវឌ្ឍថ្នាក់អំណានអេឡិចត្រូនិច ដែលមានលំដាប់អត្ថបទយកតាមកម្មវិធីអំណានថ្នាក់ជាតិ។ ការបោះជំហានសំខាន់មួយទៀត គឺសម្រេចលទ្ធផលកំណែឧបករណ៍វាយតម្លៃអំណានថ្នាក់ដំបូងត្រូវបានប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា និងការបញ្ចូលទៅជាអត្ថបទទម្រង់អេឡិចត្រូនិច។

ក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើតកម្មវិធីប្រើប្រាស់ឧបករណ៍ឡើងវិញ អង្គារ ខេប បានបន្តចូលរួមក្នុងសកម្មភាពស្រាវជ្រាវសំខាន់ៗ រួមមាន៖ ការធ្វើសមាហរណកម្មកម្មវិធីឧបត្ថម្ភពីអង្គារ Save the Children ក្របខ័ណ្ឌគម្រោង គុណភាពបរិស្ថានសិក្សា (QLE) ក៏ដូចជាការវិភាគផ្នែកអំណាន ដែលត្រូវអនុវត្តរួមសហការជាមួយវិទ្យាស្ថានស្រាវជ្រាវ RTI។

អង្គការ ខេប ក៏បានធ្វើការដាក់ពាក្យឡើងវិញដើម្បីទទួលបានវិញ្ញាបនបត្រធានាគុណភាពពីកម្មវិធីអភិបាលកិច្ចល្អ និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ (GPP) ដែលអនុវត្តដោយគណៈកម្មាធិការប្រតិបត្តិការដើម្បីកម្ពុជា (CCC)។ វិញ្ញាបនបត្រនេះ អង្គការ ខេប ទទួលបាននៅក្នុងឆ្នាំ២០១២ ហើយដាក់ពាក្យឡើងវិញបន្ទាប់ពីមានសុពលភាពរយៈពេលបីឆ្នាំ។ អង្គការ ខេប សង្ឃឹមថានឹងទទួលបានវិញ្ញាបនបត្រនេះម្ដងទៀតបន្ទាប់ពីការផ្ទៀងផ្ទាត់ដោយប្រព័ន្ធកម្មវិធី GPP។

# ការឆ្លុះបញ្ចាំង និង ការឆ្ពោះទៅមុខ!



នៅក្នុងឆ្នាំ២០១៥នេះ គម្រោងមួយចំនួនដែលដំណើរការរយៈពេលវែងបានបញ្ចប់ រួមមាន៖ កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) គម្រោងកម្មវិធីអាហារូបករណ៍នៅសាកលវិទ្យាល័យ (CTSP) និងគម្រោងអប់រំជនជាតិពួង (PEI)។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការ ខេប ក៏អាចកំណត់បានចំនួនឱកាសទទួលមូលនិធិមានសក្តានុពល ដែលមានដំណើរការខ្ពស់ មានរបៀបវារៈផែនការយុទ្ធសាស្ត្រ ដូចជា៖ *ការផ្តោតទៅលើអំណានថ្នាក់ដំបូង សាលារៀនជំនាន់ថ្មី បច្ចេកវិទ្យាក្នុងការអប់រំ និងការកសាងកម្មវិធីសាលាបឋមសិក្សាឡើងវិញ*។ ដូចទៅនឹងអ្វីដែលបាននិយាយខាងលើ អង្គការ ខេប បានបង្ហាញអត្រាជោគជ័យ ៨០% នៅក្នុងការអភិវឌ្ឍគម្រោងស្នើសុំមូលនិធិរបស់ខ្លួន។ គ្រប់កម្មវិធីទាំងអស់គឺត្រូវនឹងគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួន ដូច្នេះ ជាធម្មតា អង្គការ ខេប មិនគ្រាន់តែអនុវត្តកម្មវិធីតាមការស្នើឡើងប៉ុណ្ណោះទេ ប៉ុន្តែអង្គការ ខេប បំពេញការងារតាមរបៀបវារៈជាយុទ្ធសាស្ត្រ។ យុទ្ធសាស្ត្រនេះគឺផ្តោតទៅលើការច្នៃប្រឌិតការអប់រំថ្មីៗតាមរយៈកម្មវិធីអំណានថ្នាក់ដំបូងរបស់ខ្លួន ក៏ដូចជាការផ្តោតទៅលើគំរូអភិបាលកិច្ចល្អៗ (ឧ. សាលារៀនជំនាន់ថ្មី) និងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើនប្រសិទ្ធភាព។

## ការអភិវឌ្ឍកម្មវិធីថ្មីៗ

| គម្រោង | ដៃគូ | ម្ចាស់ជំនួយ | លក្ខខណ្ឌ | រយៈពេល |
|---|---|---|---|---|
| ១. គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ (E4K) | ធនធានសិក្សាខេប (TTS-KAPE) | All Children Reading (World Vision) | ជោគជ័យ | ២ ឆ្នាំ |
| ២. គម្រោង ងាយស្រួលរៀន (E2L) | -- | អង្គការឆាលហ្វាន | ជោគជ័យ | ៣ ឆ្នាំ |
| ៣. គម្រោង ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន (SML) | -- | អង្គការឆាលហ្វាន | ជោគជ័យ | ៣ ឆ្នាំ |
| ៤. គម្រោង សិក្សាស្រាវជ្រាវការអប់រំគ្រូបង្រៀន | -- | អង្គការឆាលហ្វាន | ជោគជ័យ | ៥ ខែ |
| ៥. គម្រោង សាលារៀនជំនាន់ថ្មី (NGS/វិ. ស៊ីសុវត្ថិ) | អង្គការអប់រំពិភពលោក | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ៣ ឆ្នាំ |
| ៦. គម្រោង សាលារៀនជំនាន់ថ្មី (NGS/ស្វាយរៀង) | -- | អង្គការឆាលហ្វាន | ជោគជ័យ | ៣ ឆ្នាំ |
| ៧. គម្រោង អប់រំកុមារី (GEI/ពង្រីកបន្ថែម) | -- | អង្គការមូលនិធិ Oaktree | ជោគជ័យ | ៣ ឆ្នាំ |
| ៨. គម្រោង ស្បៀងអាហារសម្រាប់ការអប់រំ (FfE) | កម្មវិធីស្បៀងអាហារពិ.លោក<br>អង្គការអប់រំពិភពលោក | នាយកដ្ឋានកសិកម្មរបស់សហរដ្ឋអាមេរិក | នៅរង់ចាំ | ៤ ឆ្នាំ |
| ៩. គម្រោង បណ្ណាល័យអេឡិចត្រូនិច (ELP) | កម្មវិធីសៀវភៅសម្រាប់អាស៊ី | ម្ចាស់ជំនួយឯកជន | ជោគជ័យ | ១ ឆ្នាំ |
| ១០. គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (TRAC II) | អង្គការមូលនិធិអូស្ត្រាលីសម្រាប់ប្រជាជននៅអាស៊ីប៉ាស៊ីហ្វិក (AFAP) | អង្គការ Atlassian | ជោគជ័យ | ៦ ខែ (មានលទ្ធភាពពង្រីកបន្ត) |
| ១១. គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH 2/ពង្រីកបន្ថែម) | Ciai | អង្គការ WeWorld | ជោគជ័យ | ៣ ឆ្នាំ |
| ១២. គម្រោង សិក្សាវិភាគផ្នែកអំណាន (RSAS) | Research Triangle Institute<br>World Education | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ | ជោគជ័យ | ២ ខែ |
| ១៣. គម្រោង សេវាសង្គមតាមរយៈការទទួលខុសត្រូវ (SSAP) | FHI 360<br>HEAD | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ | មិនជោគជ័យ | ៣ ឆ្នាំ |
| ១៤. គម្រោង ទប់ស្កាត់ការជួញដូរនៅកម្ពុជា (CTIP) | អង្គការមូលនិធិអាស៊ី | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ | មិនជោគជ័យ | ៤ ឆ្នាំ |

# ៦ កម្មវិធីសាកល្បងទប់ស្កាត់សិស្ស បោះបង់ការសិក្សា (SDPP)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | ក្រុមហ៊ុនគ្រីអេធីវ អាសូស៊ីអេត អន្តរជាតិ/ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ(USAID) |
| អ្នកទទួលផលផ្ទាល់ (ចំនួនសរុប) | N/A ដោយសារកម្មវិធីSDPP ជួយផ្ទាល់ និងជាអន្តរាគមន៍សាកល្បងត្រូវបានបញ្ចប់ក្នុងឆ្នាំសិក្សា ២០១៣/១៤ សាលារដ្ឋទាំងនោះបានបន្តអន្តរាគមន៍ EWS និងបន្ទប់រៀនកុំព្យូទ័រ |
| ថវិកាទទួលបានឆ្នាំ២០១៤ | ៨៩៥.២៣០,៦៤ ដុល្លាអាមេរិក |
| តម្លៃឯកតាសម្រាប់អ្នកទទួលផលម្នាក់ៗ | មិនចាំបាច់សម្រាប់ឆ្នាំនេះ |
| ខេត្តប្រតិបត្តិការ | ៦ខេត្តៈ បន្ទាយមានជ័យ ពោធិ៍សាត់ បាត់ដំបង កំពង់ស្ពឺ ព្រៃវែង និងស្វាយរៀង |
| ស្រុកប្រត្តិបត្តិការ | ៤៥ ស្រុក |
| សាលាគោលដៅបឋមសិក្សា | គ្មាន |
| សាលាគោលដៅមធ្យមសិក្សា | សាលាទទួលអន្តរាគមន៍២១៥ និងសាលាប្រៀបធៀប ១០៧ |
| កាលបរិច្ឆេទចាប់ផ្តើម | កញ្ញា ២០១០ |
| កាលបរិច្ឆេទ បញ្ចប់ | កញ្ញា ២០១៥ |

## បច្ចុប្បន្នភាពគម្រោង

ការពិសោធន៍នៃអន្តរាគមន៍ទប់ស្កាត់ចំនួនពីរ គឺប្រព័ន្ធរំលឹកជាមុនចំនួន២១៥ និងបន្ទប់រៀនកុំព្យូទ័រចំនួន១០៨កន្លែងបានបញ្ចប់នៅចុងឆ្នាំសិក្សា ២០១៣/២០១៤។ ទោះជាយ៉ាងណាក៏ដោយ កម្មវិធី SDPP មានភាពរវល់ក្នុងការប្រមូលទិន្នន័យដែលនៅសេសសល់ ដើម្បីកំណត់ថាតើអន្តរាគមន៍ទាំងនោះបានកាត់បន្ថយការបោះបង់ការសិក្សា និងជះឥទ្ធិពលពីទិន្នន័យដទៃទៀត ក្នុងនោះក្រុមការងារបានធ្វើការជិតស្និទ្ធជាមួយសាលារៀន ហើយក្រសួងអប់រំគាំទ្រលើផែនការនិរន្តរភាពនៃអន្តរាគមន៍នេះ។ ខាងក្រោមនេះគឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់កម្មវិធីៈ

- បានប្រមូលទិន្នន័យពីសាលាទទួលអន្តរាគមន៍ និងសាលាប្រៀបធៀបចំនួនសរុប៣២២ និងបានវិភាគបានលទ្ធផល (ដូចបានរៀបរាប់ក្នុងរបាយការណ៍សង្ខេបក្នុងសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវរបស់កម្មវិធី SDPP ដែលបានធ្វើនៅខេត្តបាត់ដំបង ក្រោមអធិបតីភាពឯកឧត្តម **អ៊ឹម កុច** រដ្ឋលេខាធិការក្រសួងអប់រំ ព្រមទាំងនាយកបេសកកម្ម USAID/កម្ពុជា និងគ្រីអេធីវ អាសូស៊ីអេត អន្តរជាតិ ដែលមានអ្នកចូលរួមប្រមាណជាង៣០០នាក់ មកពីសាលា សហគមន៍ រួមមានៈ ថ្នាក់ស្រុក ខេត្ត និងពីក្រសួងអប់រំ (ថ្នាក់ជាតិ និងក្រោមជាតិ)។
- ក្រសួងអប់រំបានចេញ**សេចក្តីសម្រេច**ស្តីពីការបន្តប្រតិបត្តិប្រព័ន្ធរំលឹកជាមុន និងអន្តរាគមន៍បន្ទប់រៀនកុំព្យូទ័រ
- ផ្សព្វផ្សាយ**សេចក្តីសម្រេច**របស់ក្រសួងអប់រំទៅកាន់ខេត្តចំនួន៦ដែលកម្មវិធី SDPPត្រូវអនុវត្ត និងខេត្តចំនួន៣ដែលគម្រោង IBEC ត្រូវអនុវត្ត។
- វគ្គបណ្តុះបណ្តាលគ្រូឧទ្ទេស (TOT) អំពីប្រព័ន្ធរំលឹកជាមុន (EWS) សម្រាប់មន្ត្រីរាជការថ្នាក់ជាតិ ក្រសួងអប់រំ និងគ្រូឧទ្ទេសចំនួន ៨៨នាក់ ដែលមកពីសាលាគរុកោសល្យថ្នាក់ខេត្ត និងថ្នាក់ភូមិភាគទូទាំងប្រទេស ក្នុងន័យនឹងបន្តចំណេះខាងលើនេះជូនដល់គរុនិស្សិតគ្រូបង្រៀនដែលចូលមករៀនដំបូង។
- ការផ្តល់ និងការបន្ថែមបន្ទះសូឡា ការប្តូរអាគុយសូឡា អាំងវើតទ័រ និងឧបករណ៍ដែលខូចផ្សេងទៀតដើម្បីជំរុញបន្តដំណើរការយ៉ាងរលូនដល់បន្ទប់រៀនកុំព្យូទ័រ ដែលកម្មវិធី SDPP និង គម្រោង IBEC បានផ្គត់ផ្គង់ដល់សាលាទាំងនោះ។
- លើសពីនោះទៅទៀត កម្មវិធីបានបណ្តុះបណ្តាល វគ្គការថែទាំ និងគ្រប់គ្រងកុំព្យូទ័រសម្រាប់គ្រូកុំព្យូទ័រក្នុងសាលាចំនួន១០៨ នៃកម្មវិធី SDPP និងសាលាចំនួន៣៦ ក្រោមគម្រោង IBEC បុគ្គលិកមជ្ឈមណ្ឌលពត៌មានវិទ្យាក្នុងខេត្ត និងស្រុក ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការថែទាំ និងគ្រប់គ្រងកុំព្យូរទ័រដោយខ្លួនឯង។
- ការបណ្តុះបណ្តាលគ្រូទទួលបន្ទុកថ្នាក់ និងនាយកសាលាចំនួន១.១៥៧នាក់ ព្រមទាំងសមាជិកសហគមន៍ចំនួន៣២២នាក់ អំពីអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន (EWS) ដែលមកពីសាលាប្រៀបធៀបចំនួន១០៧។
- ការបណ្តុះបណ្តាលគ្រូទទួលបន្ទុកថ្មី និងនាយកសាលាចំនួន ៣២៨នាក់ សម្រាប់សាលាដែលបានផ្តល់អន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន (EWS)។
- បង្កើត និងផលិតសៀវភៅណែនាំស្តីពីប្រព័ន្ធរំលឹកជាមុន (EWS) និងសៀវភៅណែនាំពីបន្ទប់រៀនកុំព្យូទ័រ។

កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) គឺជាកម្មវិធីពហុប្រទេសមួយដែលមានរយៈពេល៥ឆ្នាំ ដែលផ្តល់មូលនិធិដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ(USIAD) ក្នុងគោលបំណងកាត់បន្ថយសិស្សបោះបង់ការសិក្សា។ កម្មវិធីនេះមានគោលបំណងផ្តល់គោលការណ៍ណែនាំកម្មវិធីផ្អែកលើភស្តុតាងអំពីបេសកម្មរបស់ USAID និងប្រទេសនានាក្នុងតំបន់អាស៊ី និងមជ្ឈិមបូព៌ាស្តីពីការទប់ស្កាត់សិស្សបោះបង់ការសិក្សាតាមរយៈការសាកល្បង និងការធ្វើតេស្តលើប្រសិទ្ធភាពនៃអន្តរាគមន៍ទប់ស្កាត់សិស្សបោះបង់ការសិក្សានៅក្នុងប្រទេសគោលដៅចំនួនបួន រួមមានៈ កម្ពុជា ឥណ្ឌា តាជីគីស្ថាន និងទីម័រខាងកើត។

### កម្មវិធីនេះមានដំណើរការបីដំណាក់កាលៈ

1. កំណត់ការអនុវត្តល្អក្នុងការទប់ស្កាត់សិស្សបោះបង់ការសិក្សានៅសហរដ្ឋអាមេរិក និងបណ្តាប្រទេសកំពុងអភិវឌ្ឍ។
2. វិភាគនិន្នាការបោះបង់ការសិក្សាក្នុងប្រទេសនីមួយៗ ដើម្បីកំណត់ក្រុមទាំងនោះ កម្រិតថ្នាក់រៀន និង/ឬតំបន់ភូមិសាស្ត្រ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតដោយសារការបោះបង់ការសិក្សា និងធ្វើការវិភាគស្ថានភាពទៅលើក្រុមគោលដៅដើម្បីឈ្វេងយល់អំពីកត្តាហានិភ័យ និងល័ក្ខខ័ណ្ឌដែលមានផលប៉ះពាល់ទៅលើសិស្សបោះបង់ការសិក្សា។
3. គ្រោងរៀបចំអនុវត្ត និងវាយតម្លៃស៊ីជម្រៅលើអន្តរាគមន៍ ដើម្បីធ្វើយ៉ាងណាឱ្យសិស្សប្រឈមនៅបន្តការសិក្សានៅក្នុងតំបន់ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតដោយប្រើប្រាស់វិធីសាស្ត្រប្រៀបធៀបសាលាទទួលបានអន្តរាគមន៍ និងសាលាប្រៀបធៀប និងច្របាច់បញ្ចូលវិធីសាស្ត្របែបបរិមាណ និងគុណភាព។

កម្មវិធី SDPP ត្រូវបានអនុវត្តដោយក្រុមហ៊ុនគ្រីអេធីវ អាសូស៊ីអេត អ៊ីនធើណេសិនណល ហើយអង្គការខេបកំពុងអនុវត្តកម្មវិធី SDPP នៅប្រទេសកម្ពុជា ដោយបានធ្វើការជិតស្និទ្ធជាមួយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។ ទោះបីជាមានវិធីសាស្ត្រអនុវត្ត និងមានការព្រមព្រៀងពីក្រសួងអប់រំ យុវជន និងកីឡាក៏ដោយ ក៏កម្មវិធី SDPP កំណត់គោលដៅចំពោះថ្នាក់ទី៧, ៨ និង៩ នៅអនុវិទ្យាល័យ ៣២២ នៅក្នុងខេត្តគោលដៅទាំង៦ រួមមានៈ បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ ព្រៃវែង ពោធិ៍សាត់ និងស្វាយរៀង។ នៅឆ្នាំ២០១១ ភាគីពាក់ព័ន្ធអប់រំសំខាន់ៗបានអភិវឌ្ឍគំនិតដើម្បីកាត់បន្ថយសិស្សបោះបង់ការសិក្សាតាមរយៈដំណើរការពិគ្រោះយោបល់។ អន្តរាគមន៍អាទិភាពពីរ រួមមានៈ ប្រព័ន្ធរំលឹកជាមុន (EWS) និងបន្ទប់រៀនកុំព្យូទ័រ(CL) ត្រូវបានបង្កើតឡើងស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងតម្រូវការភាពអាចអនុវត្តបានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រព័ន្ធរំលឹកជាមុនៈ** (i).ការប្រើប្រាស់ទិន្នន័យសាលារៀនដែលមានស្រាប់អំពីវត្តមាន ឥរិយាបថ និងលទ្ធផលសិក្សា និងសូចនាករផ្សេងទៀតដើម្បីកំណត់សិស្សប្រឈមនឹងការបោះបង់ (ii).ការពង្រឹងសមត្ថភាពសាលារៀនដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សប្រឈមនឹងការបោះបង់ និង (iii).ការពង្រឹងភាពជាដៃគូរវាងបុគ្គលិកសាលារៀន និងមាតាបិតា ឬអាណាព្យាបាលសិស្សប្រឈមនឹងការបោះបង់។

**បន្ទប់រៀនកុំព្យូទ័រៈ** ការដំឡើងបន្ទប់រៀនកុំព្យូទ័រម៉ូដែល "thin-client" តម្លៃទាបប្រើថាមពលពន្លឺព្រះអាទិត្យនៅសាលារៀន និងបានផ្តល់ការបណ្តុះបណ្តាលជំនាញកុំព្យូទ័រដល់សិស្សដើម្បីបង្កើនការយល់ដឹងអំពីតម្លៃ និងអត្ថប្រយោជន៍ការសិក្សា។



បន្ទប់កុំព្យូទ័រត្រូវបានតំឡើងដាក់នៅសាលាឱ្យសិស្សរៀន

## “ កម្មវិធីអភិវឌ្ឍន៍ផ្អែកលើភស្តុតាង ”



# ករណីសិក្សា

សមាគមមាតាបិតាសិស្ស (PTA) នៅអនុវិទ្យាល័យ ព្រៃគគីរ គឺជាកម្លាំងចលករដ៏សំខាន់ក្នុងការទប់ស្កាត់សិស្សបោះបង់ការសិក្សានៅពេលសាលាចាប់ផ្តើមអនុវត្តប្រព័ន្ធរំលឹកជាមុន (EWS) និងកម្មវិធីកែលម្អគុណភាពអប់រំជាអន្តរាគមន៍របស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សារបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ។ លោក សួន សេន នាយករងអនុវិទ្យាល័យ ព្រៃគគីរ បានពន្យល់ថា៖

> *"សិស្សមួយចំនួនបានត្រឡប់មករៀនវិញ ហើយពួកគេមករៀនទៀងទាត់ទៀតផង បន្ទាប់ពីអវត្តមានញឹកញាប់ ឬសូម្បី[បន្ទាប់ពីបោះបង់ការសិក្សា] បន្ទាប់ពីការចុះទៅដល់ផ្ទះពីសំណាក់សមាជិកសហគមន៍ និងសមាជិក PTA"។*

តាមធម្មតា PTA រៃអង្គាសមូលនិធិដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលា ស្ថាបនាផ្លូវ និងចូលរួមការប្រជុំរបស់សាលាជាដើម។ ទោះបីយ៉ាងណាក៏ដោយ ក៏រហូតមកទល់ការចាប់ផ្តើម EWS និងកម្មវិធីកែលម្អគុណភាពអប់រំមក PTA កម្រដោះស្រាយបញ្ហាសិស្សបោះបង់ការសិក្សាណាស់។

បុគ្គលិក SDPP បានបណ្តុះបណ្តាលសមាជិក PTA នៅក្នុងសាលាគោលដៅចំនួន២១៥នាក់ ក្នុងខេត្តចំនួន៦ស្តីពីការអនុវត្ត EWS សកម្មភាពសិក្សាបន្ថែម និងរបៀបទប់ស្កាត់សិស្សមិនឱ្យបោះបង់ការសិក្សា។ ការបណ្តុះបណ្តាលធ្វើឱ្យពួកគាត់ត្រៀមខ្លួនចុះតាមផ្ទះទៅជួបជាមួយឪពុកម្តាយសិស្សដែលកូនៗរបស់ពួកគាត់តែងតែអវត្តមានពីសាលា រៀបចំការប្រជុំនៅក្នុងសហគមន៍ដើម្បីបង្កើនការយល់ដឹងពីផលប៉ះពាល់អវិជ្ជមាននៃការបោះបង់ការសិក្សា និងប្រមូលធនធានក្នុងសហគមន៍ដើម្បីធ្វើយ៉ាងណាជួយកុមារឱ្យនៅបន្តការសិក្សា។ សមាជិក PTA នៅអនុវិទ្យាល័យ ព្រៃគគីរ បានចុះតាមផ្ទះដើម្បីទៅជួបសិស្សដែលប្រឈមនឹងការបោះបង់ការសិក្សា និងដឹកនាំការប្រជុំសហគមន៍ចំនួនបីដង ឬលើសពីនេះក្នុង១ឆ្នាំៗ។ លោក អ៊ុំ សាក់ ប្រធាន PTA បានលើកឡើងថា *"ខ្ញុំរីករាយណាស់ក្នុងការជំរុញលើកទឹកចិត្តសិស្សឱ្យចូលរៀនវិញ ពីព្រោះខ្ញុំមិនមានឱកាសសិក្សាដូចពួកគេទេ"*។

ការអវត្តមានញឹកញាប់គឺជាសូចនាករបោះបង់ការសិក្សារបស់សិស្ស។ នៅពេលសាលារាយការណ៍ពីអវត្តមានរបស់សិស្ស សមាជិក PTA នៃអនុវិទ្យាល័យ ព្រៃគគីរ បានចុះទៅដល់ផ្ទះរបស់សិស្សទាំងនោះដើម្បីនិយាយជាមួយឪពុកម្តាយ និងសិស្សទាំងនោះអំពីបញ្ហានេះ និងស្វែងរកដំណោះស្រាយ ដើម្បីទប់ស្កាត់សិស្ស ស៊ុំ រ៉ុង កុំឱ្យបោះបង់ការសិក្សា PTA បានរៃអង្គាសមូលនិធិដើម្បីទិញកង់ឱ្យនាង មួយគ្រឿងពីព្រោះនាងរស់នៅឆ្ងាយពីសាលាណាស់ និងទិញសម្ភារៈសិក្សាឱ្យនាងផងដែរ។ ហេតុផលនេះហើយ បានធ្វើឱ្យ ស៊ុំ រ៉ុង ផ្លាស់ប្តូរចិត្ត ហើយមានបំណងទៅបន្តការសិក្សាវិញ៖

> *"ខ្ញុំទៅរៀនទៀងទាត់ និងទាន់ពេលវេលាទៀតផងចាប់តាំងពីខ្ញុំទទួលបានកង់មក ខ្ញុំហៀបនឹងបោះបង់ការសិក្សាទៅហើយពីព្រោះវាលំបាកណាស់ក្នុងការដើរតាមផ្លូវនៅតំបន់ជនបទចម្ងាយ៧គីឡូម៉ែត្រទៅសាលារៀននោះ"*។

ឥឡូវនេះ រ៉ុង គ្មានបំណងឈប់រៀនឡើយ។ *"ខ្ញុំចង់រៀនណាស់ ហើយខ្ញុំប្តេជ្ញាបន្តការសិក្សារបស់ខ្ញុំដើម្បីក្លាយជាគ្រូបង្រៀន"*។ នេះគ្រាន់តែជារឿងមួយស្តីពី ភាពជោគជ័យដែលបានកើតចេញពីការងាររបស់ SDPP នៅតាមសាលា និងសហគមន៍នានានៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ។ សំខាន់ជាងនេះទៅទៀតនោះ មានសិស្សតិចជាង១៣% ដែលប្រឈមនឹងការបោះបង់ការសិក្សាតាមរយៈការប្រើ EWS ក្នុងរយៈពេលពីរឆ្នាំក្នុងសាលាដែលមានក្រុមគ្រប់គ្រងនេះ។ ដូចគ្នាផងដែរការស្រាវជ្រាវរបស់ SDPP បង្ហាញថា ៥០% នៃសិស្សប្រឈមនឹងការបោះបង់ការសិក្សា ឬជាង៤.០០០នាក់ នឹងបោះបង់ការសិក្សាក្នុងរយៈពេលពីរឆ្នាំ ប្រសិនបើមិនមាន SDPP ទេនោះ។

## ផលជះរបស់គម្រោង

ដំណើរការវាយតម្លៃលម្អិតបានវិភាគទិន្នន័យកម្រិតសាលារៀនសម្រាប់សិស្ស ៦៥.១៤៥នាក់ នៅក្នុងសាលាទទួលបានអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន១០៧ សិស្ស ៦៦.០៤១នាក់ នៅក្នុងសាលាទទួលបានអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន បូកនឹងសាលាទទួលបានអន្តរាគមន៍បន្ទប់រៀនកុំព្យូទ័រ១០៨និងសិស្ស៦០.៨២៦នាក់នៅក្នុងសាលាប្រៀបធៀបចំនួន១០៧ នៅក្នុងខេត្តទាំង៦ ក្នុងអំឡុងពីរឆ្នាំសិក្សា។ លើសពីនេះទៅទៀត ទិន្នន័យស្តីពីឥរិយាបថ និងការអនុវត្តរបស់គ្រូបង្រៀន និងការយល់ដឹង និងឥរិយាបថរបស់សិស្សទទួលបានតាមរយៈបទសម្ភាសន៍បុគ្គល។

លទ្ធផលវាយតម្លៃផលប៉ះពាល់បានបង្ហាញថា កម្មវិធី SDPP បានកាត់បន្ថយអត្រាបោះបង់ជារួម និងបានកែលម្អការអនុវត្តទប់ស្កាត់សិស្សបោះបង់ការសិក្សា ស្មារតីស្វ័យប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវរបស់គ្រូបង្រៀន ជាពិសេស៖

- កម្មវិធី SDPP បានកាត់បន្ថយអត្រាបោះបង់៥% ជារួមសម្រាប់សិស្សមកពីសាលារៀនដែលទទួលបានតែអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន (EWS) ព្រមទាំងសម្រាប់សិស្សមកពីសាលារៀនដែលទទួលបានអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន និងបន្ទប់រៀនកុំព្យូទ័រ។
- អត្រាបោះបង់ត្រូវបានកាត់បន្ថយ១៣% សម្រាប់សិស្សប្រឈមនឹងការបោះបង់នៅក្នុងសាលារៀនដែលទទួលបានតែអន្តរាគមន៍ប្រព័ន្ធរំលឹកជាមុន។
- លើសពីនេះទៅទៀត កម្មវិធី SDPP បានកែលម្អការអនុវត្តទប់ស្កាត់សិស្សបោះបង់ការសិក្សា ស្មារតីស្វ័យប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវរបស់គ្រូបង្រៀនចំពោះសិស្សប្រឈមនឹងការបោះបង់។

កម្មវិធី SDPP បានកែលម្អឥរិយាបថសិស្ស ព្រមទាំងការយល់ដឹងរបស់សិស្សអំពីការគាំទ្រដែលពួកគេទទួលបានពីគ្រូបង្រៀន និងឪពុកម្តាយរបស់ពួកគេ។ យើងបានធ្វើការសិក្សាបែបគុណភាព ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីទស្សនៈអ្នកទទួលផលដោយមានអ្នកឆ្លើយសំណួរជាង៤៦០នាក់ មានប្រតិកម្មចំពោះអន្តរាគមន៍ទាំងពីរនេះ តាមរយៈបទសម្ភាសន៍ជាក្រុម និងបទសម្ភាសន៍បុគ្គល។ លទ្ធផលស្រាវជ្រាវបែបគុណភាពបានលើកឡើងថា ប្រព័ន្ធរំលឹកជាមុនមានផលប៉ះពាល់វិជ្ជមានទៅលើឥរិយាបថសិស្ស (វត្តមានទម្លាប់សិក្សា) ប៉ុន្តែមិនទាន់គ្រប់គ្រាន់ដើម្បីបញ្ឈប់សិស្សបោះបង់ការសិក្សាបានទាំងអស់នោះទេ។ សិស្ស និងមាតាបិតាសិស្សបានរាយការណ៍ថា មានប្រតិកម្មផ្សេងៗគ្នាចំពោះសាលារៀនដែលទាក់ទងមាតាបិតាសិស្សពាក់ព័ន្ធនឹងសូចនាករសិស្សប្រឈម ប៉ុន្តែមានប្រសិទ្ធភាព ហើយមាតាបិតាសិស្សបានឆ្លើយតបទៅនឹងតម្រូវការ។ បុគ្គលិកសាលារៀនជឿជាក់ថា អន្តរាគមន៍ទាំងពីរបានកែលម្អវត្តមានសិស្ស និងបានកាត់បន្ថយសិស្សបោះបង់ការសិក្សា ប៉ុន្តែមានក្តីបារម្ភអំពីការបន្ថែមបន្ទុកការងារប្រព័ន្ធរំលឹកជាមុន និងគាំទ្រចំពោះបន្ទប់រៀនកុំព្យូទ័រ។ សិស្សចូលចិត្តបន្ទប់រៀនកុំព្យូទ័រ ប៉ុន្តែចង់អនុវត្តឱ្យបានច្រើនជាងនេះ។ មាតាបិតាសិស្សមិនបានទស្សនកិច្ចបន្ទប់រៀនកុំព្យូទ័រនោះទេ ហើយមិនបានយល់ដឹងអំពីការរីកចម្រើនរបស់កូនខ្លួននៅក្នុងថ្នាក់រៀនកុំព្យូទ័រ ប៉ុន្តែបានទទួលស្គាល់ថា វាជាជំនាញដ៏ល្អសម្រាប់ពួកគេ។ សហគមន៍បាននិយាយថា ពួកគាត់នៅមានចិត្តចង់ផ្តល់ការគាំទ្របន្តដើម្បីកាត់បន្ថយសិស្សបោះបង់ការសិក្សា។

ក្នុងសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវរបស់គម្រោងនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា បានប្រារព្ធឡើងក្នុងខែកក្កដា ឆ្នាំ២០១៥ នៅខេត្តបាត់ដំបង។ ការឆ្លើយតបដ៏លើសលប់ពីមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងនាយកសាលាគឺថា ពួកគាត់បានកោតសរសើរប្រព័ន្ធរំលឹកជាមុន និងបន្ទប់រៀនកុំព្យូទ័រ និងបានចាត់ទុកថា ជាឧបករណ៍ដ៏សំខាន់សម្រាប់ដោះស្រាយបញ្ហាទប់ស្កាត់សិស្សបោះបង់ការសិក្សា។ ពួកគាត់បានប្តេជ្ញាចិត្តបន្តអន្តរាគមន៍ទាំងពីរនេះ ហើយក៏បានស្នើឱ្យក្រសួងអប់រំ យុវជន និងកីឡាគាំទ្រ និងកែប្រែកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីដាក់បញ្ចូលការបណ្តុះបណ្តាលប្រព័ន្ធរំលឹកជាមុន និងបន្ទប់រៀនកុំព្យូទ័រក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូតាមបណ្តាសាលាគរុកោសល្យទាំងអស់ ដែលគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា។



ភ្ញៀវកិត្តិយស និងអ្នកចូលរួមសិក្ខាសាលានៅថ្ងៃទី១

# ៨

# គម្រោង សាលារៀនដៃគូ (BSI)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការអ្នកទ្រី/ក្រុមហ៊ុន Flight Center, សមាគមន៍ចិន, មូលនិធិ Breteau Foundation, ម្ចាស់ជំនួយឯកជន, ក្រុមហ៊ុន Apple Corporation |
| អ្នកទទួលផលផ្ទាល់ | • សិស្សថ្នាក់ទី៧ដល់៩ ចំនួន១.៦៥៨នាក់ (ស្រី៨១៥នាក់)<br>• គ្រូបង្រៀនថ្នាក់ទី៧ដល់៩ ចំនួន៨៣នាក់ (ស្រី៤១នាក់)<br>• គណៈគ្រប់គ្រងសាលា ១៣នាក់ (ស្រី១នាក់) |
| ថវិកាប្រចាំឆ្នាំ ២០១៥ | ១២៣.៦៦៨,៦៤ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ៧០,៥៥ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ២ខេត្ត (កំពង់ចាម និងត្បូងឃ្មុំ) |
| ចំនួនស្រុកគ្របដណ្តប់ | ៣ស្រុក (ជើងព្រៃ កំពង់ចាម និងត្បូងឃ្មុំ) |
| មធ្យមសិក្សាគោលដៅ | ៣សាលា (វិ. ហស ស្តង់ អនុវិ. ហស អនុវត្តកំពង់ចាម) |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ខែមករា ឆ្នាំ២០១១ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ខែកញ្ញា ឆ្នាំ២០១៦ |

## សន្និទានភាពនៃកម្មវិធី

គម្រោងសាលារៀនដៃគូព្យាយាមបង្កើតឱ្យបានគំរូអភិវឌ្ឍច្រើនជម្រើសក្នុងសាលារៀនរដ្ឋ ដោយផ្អែកលើលក្ខណៈអំណោយផលរបស់សាលាក្នុងការប្រើប្រាស់ជំនួយបច្ចេកទេស។ គម្រោងមិនមែនត្រឹមតែផ្តល់ជំនួយបច្ចេកទេសដ៏ល្អពេញលេញដល់សាលាដែលត្រូវបានជ្រើសរើសប្រកបដោយសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែក៏បានសង្កត់ធ្ងន់លើរចនាសម្ព័ន្ធអភិបាលកិច្ចជំនាញ ដែលធានាឱ្យការប្រើប្រាស់ធនធានថវិកាឧបត្ថម្ភគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព និងមានគណនេយ្យភាព ដោយផ្អែកលើភារកិច្ចបន្ថែមដែលគ្រូបង្រៀនបានបំពេញ (ឧ. ការរៀបចំគម្រោងការពិសេសពាក់ព័ន្ធនឹងការសិក្សាបែបស្ថាបនា ការផ្តល់ប្រឹក្សាអាជីព និងក្លឹបសិក្សា...។ល។ វិធីអភិវឌ្ឍទាំងពីរគន្លងនេះបង្ហាញពី***គំរូនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន*** ក្នុងការគ្រប់គ្រងសាលារៀនរដ្ឋទាំងបីដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលសហការយ៉ាងជិតស្និទជាមួយតួអង្គមិនមែនរដ្ឋាភិបាល (ឧ. អង្គការ ខេប)។

## បច្ចុប្បន្នភាពគម្រោង

នៅចុងឆ្នាំ២០១៤ អង្គការ ខេប បានចចារជាមួយមូលនិធិអ្នកទ្រី ដើម្បីអនុញ្ញាតឱ្យបន្តគម្រោងរយៈ២ឆ្នាំបន្ត ដើម្បីធានាបានថា គំរូសាលារៀនជំនាន់ថ្មីដែលបានអនុវត្តសាកល្បងរយៈពេល៣ឆ្នាំកន្លះអាចបន្តពង្រឹង និងមាននិរន្តរភាព។ ការបន្តគម្រោងចាប់ផ្តើមពីខែតុលា ឆ្នាំ២០១៤ និងបានបញ្ចប់រយៈពេល១ឆ្នាំនៅក្នុងខែកញ្ញា ឆ្នាំ២០១៥។ ចំណុចគន្លឹះដែលត្រូវបានផ្តោតការយកចិត្តទុកដាក់ក្នុងបរិបទនេះ រួមមាន៖ ការជំរុញសកម្មភាពរកប្រាក់ចំណូលសម្រាប់សាលា (ដូចជា អាហារដ្ឋានសាលារៀន) ការបង្កើតកញ្ចប់ថវិកាអំណោយទទួលបានពីក្រុមហ៊ុន Apple, ការពង្រឹងប្រព័ន្ធអភិបាលកិច្ច ការពង្រឹងសមត្ថភាពគ្រូលើជំនាញបច្ចេកវិទ្យាព័ត៌មាន ការពង្រឹងសេវាផ្តល់ប្រឹក្សាអាជីព និងការពង្រឹងការចូលរួមរបស់មាតាបិតាសិស្ស។

## ព្រឹត្តិការណ៍សំខាន់ៗ

- សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ពានរង្វាន់សាលារៀនឆ្នើមប្រចាំឆ្នាំក្នុងចំណាត់ថ្នាក់លេខ ២ អមដោយថវិកាចំនួន៦លានរៀលដល់អនុវិទ្យាល័យ ហស អនុវត្តកំពង់ចាម។
- ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអង្គការឆាលហ្វានបានទទួលយកជាផ្លូវការនូវគំរូសាលារៀនជំនាន់ថ្មី។
- ការរីកចម្រើនយ៉ាងឆាប់រហ័សនូវចំណេះដឹងកុំព្យូទ័រ។
- ការបញ្ចប់ឯកសារពិគ្រោះយោបល់ដែលរំលេចពីជោគជ័យ និងមេរៀនបទពិសោធន៍សម្រាប់ការផ្សព្វផ្សាយថ្នាក់ជាតិ។
- ការរកប្រាក់ចំណូលអនុវិទ្យាល័យ ហស អនុវត្តកំពង់ចាម ទទួលបានលើស ១៥.000ដុល្លាអាមេរិកនៅក្នុងឆ្នាំទី៥។
- ការចាប់ផ្តើមដោយជោគជ័យសកម្មភាពរកប្រាក់ចំណូលនៅវិទ្យាល័យសម្តេចម៉ែ។



***ពានខ្វាន់ថ្នាក់ជាតិ***:*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រគល់ពានរង្វាន់ដល់លោក ប៉ាល់ សុវណ្ណ នាយកអនុវិទ្យាល័យ អនុវត្តកំពង់ចាមក្នុងសន្និបាតអប់រំជាតិកាលពីខែមីនា ឆ្នាំ២០១៥។ ពានរង្វាន់បានផ្តល់ការទទួលស្គាល់សាលារៀនល្អជាងគេមួយក្នុងចំណោមសាលារៀនល្អបំផុតចំនួន៣នៅកម្ពុជា។*



***ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ***:*ពិធីចុះហត្ថលេខាលើអនុសារណៈយោគយល់រវាងឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា(ខាងស្តាំ) និងលោកនាយកប្រតិបត្តិអង្គការខេប(ខាងឆ្វេង) ដែលក្នុងនោះក្រសួងបានសន្យាផ្តល់ថវិកាចំនួន ៣៧០.000 ដុល្លាអាមេរិក ដើម្បីអនុវត្តតាមគំរូសាលារៀនជំនាន់ថ្មី។ នេះជាលើកទី១ដែលក្រសួងបានបែងចែកថវិកាបានពីពន្ធដារដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។*

## រូបភាពសំខាន់ៗ

**អង្គការជាង ២០ បានមកទស្សនកិច្ចសាលាអនុវត្តក្នុងរយៈមួយឆ្នាំកន្លងទៅនេះ ដែលបានឆ្លុះបង្ហាញផលជះយ៉ាងធំធេងរបស់គម្រោង។**



ភ្ញៀវមកពីអង្គការ VSO បានមកចូលរួមស្តាប់បទបង្ហាញអំពីសាលាអនុវត្តនៅក្នុងខេត្តកំពង់ចាម

## ផលជះរបស់គម្រោង

**ចីរភាពគម្រោង:** ឆ្លងដល់ពាក់កណ្តាលផ្លូវនៃដំណាក់កាលបន្តគម្រោងសម្រេចបានសូចនាករប្រមាណ **៧៩%** ចំណែក **១២%** ទៀតកំពុងឆ្ពោះទៅសម្រេចបាន។ ក្នុងន័យនេះ គម្រោងសម្រេចបាននូវសមិទ្ធិផលធំៗក្នុងការកសាងស្ថាប័នទាក់ទងនឹងគណៈកម្មការទ្រទ្រង់សាលា និងក្រុមប្រឹក្សាកុមារ ព្រមទាំងសេវាបន្តពង្រឹងឱ្យកាន់តែប្រសើរ ដូចជាការប្រឹក្សាអាជីព និងបច្ចេកវិទ្យាព័ត៌មានជាដើម។ លទ្ធផលសិក្សាក៏បង្ហាញឱ្យឃើញមានការរីកចម្រើនផ្នែកការគិតដោយវិភាគ និងវប្បធម៌ទូទៅ។ ភាពលេចធ្លោសំខាន់មួយដែលគម្រោងសម្រេចបានគឺក្រសួងបានព្រមព្រៀងទទួលយកគំរូសាលារៀនជំនាន់ថ្មីធ្វើជាកម្មវិធីថ្នាក់ជាតិ ដោយបានដាក់បញ្ចូលក្នុងកម្មវិធីកំណែទម្រង់វិស័យអប់រំទាំង១៥ចំណុច ដាក់ចេញដោយឯកឧត្តមរដ្ឋមន្ត្រី។ សេចក្តីសង្ខេបសមិទ្ធិផលសម្រេចបានមានដូចក្នុងតារាងខាងក្រោម។

## ករណីសិក្សា: ការបង្កើតភាពច្នៃប្រឌិតរបស់គ្រូក្នុងការបង្រៀនសិស្ស

គ្រូវិទ្យាសាស្ត្រម្នាក់បានផ្តល់ឱកាសឱ្យសិស្សមួយក្រុមធ្វើបទបង្ហាញតាម PowerPoint ដល់មិត្តរួមថ្នាក់អំពីគម្រោងវិទ្យាសាស្ត្រដែលក្រុមនេះបានសហការគ្នាធ្វើ។ សិស្សបានចូលរួមធ្វើកិច្ចការក្នុងគម្រោងពិសេសនេះជាផ្នែកមួយនៃកម្មវិធីក្លឹបវិទ្យាសាស្ត្ររៀបចំដោយសាលារៀន។ គ្រូឯកទេសធ្វើកិច្ចការជាមួយសិស្ស ដែលដឹកនាំសកម្មភាពដោយខ្លួនឯងតាមរយៈសមាជិកក្លឹប។ គ្រូបង្រៀនទទួលការបំប៉នដើម្បីធានាបានថា គោលការណ៍ផ្តល់សិទ្ធិអំណាចដល់យុវជនមានការអង្កេត ដើម្បីគាំទ្រក្លឹប សិស្សបានច្នៃបង្កើតគំរូរថយន្តផ្អែកលើគោលការណ៍មេរៀនរូបវិទ្យា ដែលបានរៀនក្នុងថ្នាក់។ រថយន្តនេះប្រើថាមពលថ្មពិល ហើយផ្តល់ជាលំហាត់រូបីយ៉ាងច្បាស់សម្រាប់សិស្សធ្វើកិច្ចការដោយម្ចាស់ការ ដើម្បីបង្ហាញពីការច្នៃប្រឌិតរបស់ខ្លួន។ សកម្មភាពបែបនេះដែលធ្វើឱ្យសិស្សមានឱកាសបង្ហាញការច្នៃប្រឌិតរបស់ខ្លួនគឺកម្រមានណាស់នៅក្នុងសាលារៀនរដ្ឋប្រទេសកម្ពុជា ហើយវាជាសមិទ្ធិផលសំខាន់មួយនៃគម្រោងសាលារៀនជំនាន់ថ្មី។



សិស្សនៅសាលាអនុវត្តបានធ្វើបទបង្ហាញប្រើកម្មវិធី PowerPoint

| លទ្ធផល | សូចនាករសរុប | សម្រេចបាន | | មិនទាន់សម្រេច/កំពុងសម្រេច | | សម្រេចបានដោយផ្នែក | | មិនសម្រេច | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| **លទ្ធផលទី ១៖** បន្តអនុវត្តសកម្មភាពសាលាកុមារមេត្រី | ៥ | ៤ | ៨០% | -- | -- | -- | -- | ១ | ២០% |
| **លទ្ធផលទី២៖** បន្តពង្រឹងសេវាពិសេសដល់សិស្ស | ៦ | ៥ | ៨៣% | -- | -- | -- | -- | ១ | ១៧% |
| **លទ្ធផលទី៣៖** ពង្រឹងសមត្ថភាពគ្រូបង្រៀន | ៣ | ៣ | ១០០% | -- | -- | -- | -- | -- | -- |
| **លទ្ធផលទី៤៖** គំរូរបស់គម្រោងធានាបាននិរន្តរភាព | ៦ | ៤ | ៦៧% | ១ | ១៧% | ១ | ១៧% | -- | -- |
| **លទ្ធផលទី៥៖** ជោគជ័យការតស៊ូមតិសម្រាប់គំរូសាលារៀនជំនាន់ថ្មី | ៤ | ៣ | ៧៥% | ១ | ២៥% | | | -- | -- |
| **សរុប** | ២៤ | ១៩ | ៧៩% | ២ | ៨% | ១ | ៤% | ២ | ៨% |

# ១០ គម្រោង លើកកម្ពស់សេវាកម្មសុខភាពសាលារៀន (ISHS)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | មូលនិធិ Breteau |
| អ្នកទទួលផលផ្ទាល់ | ១,៨៧៥ (ស្រី៨៩៦ នាក់) |
| ថវិកាប្រចាំឆ្នាំ ២០១៣ | ៧.៤១០,៦០ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលម្នាក់ | ៤ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ១ (កំពង់ចាម) |
| ចំនួនស្រុកគ្របដណ្តប់ | ១ (ស្រុកជើងព្រៃ) |
| មធ្យមសិក្សាគោលដៅ | ១ (វិទ្យាល័យ ហ៊ុន សែន ស្គន់) |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | កក្កដា ២០១៣ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | មិថុនា ២០១៧ |

## បច្ចុប្បន្នភាពគម្រោង

បន្ទប់សង្គ្រោះបឋមមួយបានចាប់ផ្តើមដំណើរការនៅខែកញ្ញា ឆ្នាំ២០១៣ នៅក្នុងវិទ្យាល័យ ហ៊ុន សែន ស្គន់ ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ នេះជាសមិទ្ធផលលេចធ្លោមួយ ដែលបានបង្ហាញឱ្យឃើញការសម្រេចបានថ្មីមួយនៃកម្មវិធីសាលាកុមារមេត្រី ព្រោះកម្មវិធីនេះបានផ្តួចផ្តើមឡើងទាំងស្រុងដោយក្រុមប្រឹក្សាកុមារ។ ក្នុងន័យនេះវាបានឆ្លុះឱ្យឃើញពីគំរូនៃទង្វើប្រកបដោយភាពម្ចាស់ការរបស់សាលារៀន និងសេចក្តីក្លាហានក្នុងការច្នៃប្រឌិតថ្មីៗ។ ក្នុងឆ្នាំសិក្សា ២០១៤-២០១៥ បន្ទប់សង្គ្រោះបឋមរបស់សាលាបានផ្តល់សេវាសុខភាពជូនសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងបុគ្គលិកសាលាសរុបប្រមាណ៧៥៨នាក់។



## ផលជះរបស់គម្រោង

ដោយមានបន្ទប់សង្គ្រោះបឋមក្នុងសាលា សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងបុគ្គលិកសាលាទាំងអស់មានទឹកចិត្តសប្បាយរីករាយយ៉ាងខ្លាំងនឹងសកម្មភាពរៀន និងបង្រៀន។ លើសនេះទៀត វាបានរួមចំណែកកាត់បន្ថយបានយ៉ាងច្រើននូវអវត្តមាន និងអត្រាបោះបង់របស់សិស្សបណ្តាលមកពីបញ្ហាសុខភាព។



## សនិទានភាពនៃកម្មវិធី

ដោយប្រកាន់ខ្ជាប់នូវវិធីសាស្ត្រអនុវត្ត ដែលលើកកម្ពស់ការអភិវឌ្ឍអ្នកពាក់ព័ន្ធ ក្រុមប្រឹក្សាកុមារនៅវិទ្យាល័យ ហ៊ុន សែន ស្គន់ បានចាប់ធ្វើសកម្មភាពរងមួយនៃការផ្តួចផ្តើមគំនិតដោយខ្លួនឯង ដើម្បីបង្កើតកន្លែងដែលគេអាចជួបប្រជុំគ្នា (សហព័ន្ធសិស្ស) និងគាំពារសិស្សឈឺនៅក្នុងសាលារៀន។ មានសិស្សជាច្រើននាក់មកពីទីឆ្ងាយធ្វើដំណើរដោយជិះកង់ពីផ្ទះរបស់ពួកគេមកសាលារៀន។ សិស្សជាច្រើនគឺជាកូនគ្រួសារក្រីក្រមានអាហារបរិភោគមិនគ្រប់គ្រាន់។ បន្ទាប់ពីពួកគេខំប្រឹងដោយប្រើកម្លាំងមួយចំនួនមានសុខភាពមិនល្អ ជួនកាលចុះខ្សោយកម្លាំង និងត្រូវការឈប់សម្រាក។ ដោយសារគ្មានការផ្គត់ផ្គង់ពីសាលារៀនចំពោះតម្រូវការទាំងនេះ ដែលជារឿយៗ គេត្រូវដេកក្នុងថ្នាក់រៀន ឬអង្គុយនៅបរិវេណក្រៅថ្នាក់។ ក្រុមប្រឹក្សាកុមារបានជួបម្ចាស់ជំនួយម្នាក់ ដែលបានសម្រេចចិត្តជួយគេដោះស្រាយតម្រូវការនេះរបស់សិស្ស។ ការទំនាក់ទំនងទាំងនេះហើយបានឈានដល់ការសាងសង់គ្លីនិកសុខភាព ដែលមានការផ្គត់ផ្គង់គ្រប់គ្រាន់នៅវិទ្យាល័យ ស្គន់ ដោយមានគិលានុបដ្ឋាយិកាពេញម៉ោងផ្តល់ដោយការិយាល័យសុខាបាល (ការជ្រើសរើសដោយមានការប្រកួតប្រជែង)។ សកម្មភាពនេះគឺជាឧទាហរណ៍មួយនៃការផ្តល់អំណាចឱ្យអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍ដោយមានសិស្សជាអ្នកផ្តួចផ្តើមគំនិតទាំងស្រុង។





# គម្រោង សៀវភៅសម្រាប់កម្ពុជា (BfC)

## “ បង្កើនការលូតលាស់ជីវិតកុមារតាមរយៈសៀវភៅសិក្សា និងប្រព័ន្ធផ្សព្វផ្សាយ ”

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការមូលនិធិអាស៊ី (TAF) |
| អ្នកទទួលផលផ្ទាល់ | ៤១.៣១១ នាក់ (ស្រីចំនួន ២០.៥៤១នាក់) |
| ថវិកាគាំទ្រផ្ទាល់ | ១៨.៤៦៨ ដុល្លាអាមេរិក |
| បដិភាគទទួលក្នុងឆ្នាំ ២០១៥ | ២៤៧.៨៩៩,១៤ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ៦ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | កំពង់ចាម សៀមរាប ក្រចេះ ព្រៃវែង ស្វាយរៀង ភ្នំពេញ កំពង់ឆ្នាំង និងបាត់ដំបង |
| ស្រុកគ្របដណ្តប់ | ២៨ |
| បឋមសិក្សាគោលដៅដែលជួយ | ២២ |
| វិទ្យាល័យដែលជួយ និង | ២៦ |
| វិទ្យាស្ថានដទៃទៀត | ១២ |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ខែមេសា ឆ្នាំ២០១៤ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ខែកញ្ញា ឆ្នាំ២០១៦ |

## បង្កើនភាពសម្បូរបែបបណ្ណាល័យនៅតាមសាលារៀន

បច្ចុប្បន្ននេះអង្គការ ខេប និងដៃគូរបស់ខ្លួនគឺអង្គការមូលនិធិអាស៊ី បានបញ្ចប់យ៉ាងពេញលេញពីដំណើរការធ្វើមូលដ្ឋានីយកម្មកម្មវិធីសៀវភៅសម្រាប់អាស៊ីនៅក្នុងប្រទេសកម្ពុជា។ ជាការពិតណាស់ នៅក្នុងឆ្នាំ២០១៥ បានឃើញពីការបញ្ចប់ឆ្នាំទីពីរនៃកម្មវិធីចែកចាយសៀវភៅក្រោមការគ្រប់គ្រងរបស់អង្គការ ខេប របស់គម្រោង BFC។ បើទោះបីជាការបាត់បង់ការផ្តល់ថវិកាសម្រាប់គាំទ្រដល់កម្មវិធីពីជំនួយរបស់ពលរដ្ឋអាមេរិកកាំង (USAID) កាលពីឆ្នាំមុនយ៉ាងណាក្តី បច្ចុប្បន្ននេះមូលនិធិអាចនៅបន្តសកម្មភាពចែកចាយធនធានសៀវភៅយ៉ាងពេញលេញដដែល។ អំឡុងពេលឆ្នាំសិក្សាកន្លងមក អង្គការ ខេប បានបង្កើននូវសកម្មភាពផ្សព្វផ្សាយរបស់ខ្លួនយ៉ាងច្រើន រួមបញ្ចូលសាលារៀនចំនួន៦០ និងស្ថាប័នអប់រំផ្សេងៗទៀតនៅទូទាំងខេត្តចំនួនប្រាំបី ដែលមានស្រុកសរុបចំនួន ២៨ស្រុក។ នៅក្នុងអំឡុងឆ្នាំនេះ អង្គការ ខេប បានទទួលការនាំចូលនូវសៀវភៅពីសហរដ្ឋអាមេរិកចំនួន២កុងតឺណឺ ហើយបានរៀបចំជាបញ្ជីបរិច្ចាគ និងការដាក់តាំងបង្ហាញសៀវភៅទាំងនេះនៅក្នុងទីរួមខេត្តកំពង់ចាម។ ការនាំចូលទាំងនេះមានសៀវភៅសរុបចំនួន ២០.៧១៣ក្បាល ព្រមទាំងឧបករណ៍ និងសម្ភារៈអប់រំផ្សេងៗទៀត។ ទោះបីជាពេលខ្លះបុគ្គលិកគម្រោងបានជួបនូវបញ្ហាប្រឈមខ្លះពីអត្រាអ្នកប្រើប្រាស់សៀវភៅមានកម្រិតទាបនៅក្នុងចំណោមអ្នកដែលបានទទួលមួយចំនួន ជាពិសេស នៅតាមសាលារដ្ឋដែលការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំខ្សោយគឺបន្តជាឧបសគ្គធំមួយក្នុងការធ្វើឱ្យប្រសើរឡើងនូវការអប់រំ។ កម្មវិធីនេះមានការពេញចិត្តយ៉ាងច្រើនជាមួយនឹងអត្រាសៀវភៅខ្ពស់បំផុត បានដាក់បញ្ចូលទៅក្នុងកម្មវិធីអ្នកទទួលក្នុងចំណោមអ្នកទទួលបានជំនួយសៀវភៅទាំងនោះ។

## ឱកាសសម្រាប់ពង្រីកអំណានធ្វើឱ្យជីវិតកុមារមានការច្នៃប្រឌិត

កម្មវិធីសៀវភៅសម្រាប់កម្ពុជាស្វែងរកការផ្តល់អំណោយទៅដល់សាលារៀនជាច្រើន ដែលមានការគ្រប់គ្រងដ៏ល្អមួយ។ សាលាមួយក្នុងចំណោមសាលារៀនគំរូទាំងនេះគឺសាលាអនុវត្តន៏ដែលស្ថិតនៅក្នុងក្រុងកំពង់ចាម ជាផ្នែកមួយនៃការផ្តួចផ្តើមរបស់អង្គការ ខេប ទទួលបានជោគជ័យ។ គម្រោង BfC បានធ្វើការបរិច្ចាគនូវសៀវភៅយ៉ាងសំខាន់ដល់មជ្ឈមណ្ឌលព័ត៌មាន និងបណ្ណាល័យសាលាអនុវត្តន៏។ អំណោយសៀវភៅនេះបានបង្កើនឲ្យសាលាមានសៀវភៅភាសាអង់គ្លេសយ៉ាងច្រើនក្នុងសាលា និងរួមចំណែកយ៉ាងខ្លាំងទៅនឹងកម្មវិធីភាសាអង់គ្លេសរបស់ខ្លួន។ កម្មវិធីនេះត្រូវបានពង្រីកនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ វាមិនត្រឹមចំពោះតែជាសាលារៀនគោលដៅរបស់អង្គការ ខេប ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសាលារៀនគោលដៅឯកជន និងស្ថាប័នអប់រំនៅទូទាំងប្រទេសផងដែរ។




## សកម្មភាពកម្មវិធី

នៅក្នុងឆ្នាំ២០១៤ អង្គការ ខេប និងអង្គការមូលនិធិអាស៊ី បានចុះកិច្ចព្រមព្រៀងមូលដ្ឋានីយកម្មសៀវភៅ ដែលមានការទទួលស្គាល់សម្រាប់កម្មវិធីប្រចាំតំបន់អាស៊ីដោយមានការផ្តល់មូលនិធិគាំទ្រដែលបានផ្តល់ដោយមូលនិធិអាស៊ី និងការអនុវត្តដោយផ្ទាល់ដែលផ្តល់ដោយអង្គការ ខេប។ គោលដៅទាំងនេះត្រូវបានគេដឹងឮ ហើយអង្គការ ខេប បានធ្វើការចែកចាយនូវសៀវភៅភាសាអង់គ្លេសដែលមានគុណភាពខ្ពស់រាប់ពាន់ក្បាលប្រកបដោយជោគជ័យទៅសាលារៀនជាង៦០ និងស្ថាប័នអប់រំផ្សេងៗទៀតនៅក្នុងអំឡុងឆ្នាំសិក្សា។

⇒ សៀវភៅ និងសម្ភារៈសិក្សាដទៃទៀតដែលបានចែកចាយ ចំពោះសាលារៀន ស្ថាប័នអប់រំ និងអង្គការក្រៅរដ្ឋាភិបាល មានដូចខាងក្រោម៖
- សៀវភៅសម្រាប់កុមារចំនួនៈ **៣.៤០១** ក្បាល
- សៀវភៅសម្រាប់ថ្នាក់បឋម/មធ្យមចំនួនៈ **២.៥៧១**ក្បាល
- សៀវភៅសម្រាប់ថ្នាក់អប់រំជាន់ខ្ពស់ចំនួនៈ **៧០៨**ក្បាល
- សៀវភៅសម្រាប់ថ្នាក់អាជីពចំនួនៈ **១.១៥៤** ក្បាល
- សម្ភារៈសិក្សាជា មេឌៀសម្រាប់បឋមសិក្សាចំនួនៈ **៩៨**
- ឧបករណ៍សិក្សាដទៃទៀតចំនួនៈ **១១២**
- សៀវភៅគ្រូចំនួនៈ **៧៦**ក្បាល
- ឧបករណ៍សម្រាប់ដាក់ឯកសារចំនួនៈ **១៨**ប្រអប់
- សរុបចំនួនសៀវភៅ និងសម្ភារៈដែលបានចែកចាយៈ **៨.១៣៨**ក្បាល/ឈុត

⇒ គាំទ្រការបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធ សៀវភៅសម្រាប់អង្គការ រៀបចំឱ្យមានភាពងាយស្រួលក្នុងការចូលដំណើរការដល់យុវជន និងសិស្សនិស្សិត

⇒ ចុះត្រួតពិនិត្យតាមដានពីអត្រាប្រើប្រាស់សៀវភៅ

⇒ គាំទ្រដល់ការអភិវឌ្ឍន៍បណ្ណាល័យអេឡិចត្រូនិច។

# ១២

# គម្រោង សាលារៀនល្អប្រសើរ (SfE)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការថ្នាក់រៀនមានសង្ឃឹម (CoH) និង Global Development Group (GDG) |
| អ្នកទទួលផលផ្ទាល់ | សិស្ស ៤.៧៣២នាក់ (ស្រី ២.២០០នាក់) |
| ចំនួនអ្នកទទួលផលប្រយោលពីគម្រោង | (សន្មត) មាតាបិតា៩.៤៦៤នាក់, គ្រូ៦០នាក់ នាយកសាលា១៥នាក់ **សរុប: ១៥.២០៧នាក់** |
| ថវិកាទទួលបានប្រចាំឆ្នាំ ២០១៥ | ៤០.៦១៤,៩៩ ដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ៨,៦០ ដុល្លារអាមេរិក |
| ខេត្តគ្របដណ្តប់ | ១ខេត្ត (ត្បូងឃ្មុំ) |
| ចំនួនស្រុកគ្របដណ្តប់ | ១ស្រុក (ក្រូចឆ្មារ) |
| បឋមសិក្សាគោលដៅ | ១៥សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ១ តុលា ឆ្នាំ២០១៣ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣១ កក្កដា ២០១៥ |

**គោលបំណង/ទិសដៅគម្រោង:** គោលបំណងគម្រោង គឺដើម្បីបង្កើតសាលាកុមារមេត្រីគំរូ ដែលពិតជាធ្វើឱ្យល្អប្រសើរនូវសមាសភាពសំខាន់មួយចំនួន ដូចជាៈ ពង្រឹងគុណភាពអប់រំ កម្មវិធីអប់រំបញ្ចូលគ្នា (សម្រាប់កុមារី កុមារជនជាតិភាគតិច និងកុមារដែលពិការផ្នែករាងកាយ) និងបង្កើនការចូលរួមពីអ្នកពាក់ព័ន្ធនៅមូលដ្ឋាន។

សកម្មភាពសំខាន់ៗ គម្រោងសាលារៀនល្អប្រសើរត្រូវបានបែងចែកជា៤ផ្នែកដូចខាងក្រោមៈ

i) សកម្មភាពកសាងសមត្ថភាពបុគ្គលិកសិក្សា

ii) សកម្មភាពអភិវឌ្ឍសាលារៀនផ្សារភ្ជាប់ទៅនឹងកម្មវិធីសាលាកុមារមេត្រី ផ្តែកលើបញ្ជីសេវាកម្ម ដោយមានកញ្ចប់ថវិកាអំណោយសាលារៀនប្រមាណ ៧៥០ដុល្លាអាមេរិកក្នុងមួយសាលា។

iii) សកម្មភាពផ្សេងៗក្នុងការសម្របសម្រួលដល់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន ដើម្បីបង្កើនការចូលរួមរបស់សហគមន៍ក្នុងការអប់រំ។

iv) ផ្តោតលើការកសាងសមត្ថភាពអង្គការដៃគូ រួមទាំងសាលារៀន សហគមន៍ និងអង្គការសង្គមស៊ីវិល។ គម្រោងបានកសាងសមត្ថភាពដៃគូ អង្គការសកម្មភាពកុមារដើម្បីអភិវឌ្ឍន៍(CAD) នៅខេត្តបាត់ដំបង ដើម្បីពង្រឹងផ្នែកហិរញ្ញវត្ថុ និងប្រព័ន្ធគ្រប់គ្រងស្ថាប័នអង្គការសង្គមស៊ីវិល។

## បច្ចុប្បន្នភាពគម្រោង

គម្រោង សាលារៀនល្អប្រសើរ បានបញ្ចប់ប្រតិបត្តិការក្នុងឆ្នាំ២០១៥ បន្ទាប់ពីប្រតិបត្តិការអស់រយៈពេល៣ឆ្នាំមក។ គម្រោងបិទបញ្ចប់ដោយមានជំនឿយ៉ាងមុតមាំថា សាលារៀនអាចបន្តសកម្មភាពទាំងអស់តាមរយៈការគាំទ្រថវិការបស់រដ្ឋាភិបាល រួមមានៈ ថវិកា PB និងថវិកា SIG។

## សកម្មភាពសំខាន់ៗ

- ការបញ្ចូលកម្មវិធីដើម្បីលើកកម្ពស់ភាសាខ្មែរ រួមមានៈ បណ្ណាល័យសតវត្សទី២១ ការសិក្សាតាមអេឡិចត្រូនិច និងសម្ភារៈពង្រឹងអំណានមួយចំនួនទៀត
- ការកសាងផែនការអភិវឌ្ឍប្រចាំឆ្នាំ
- ផែនទីសិក្សា និងអាហារូបករណ៍សម្រាប់កុមារក្រីក្រ។
- កុមារជួយកុមារផ្តោតលើសកម្មភាពកុមារធំជួយបង្រៀនកុមារតូច។
- បំប៉នបន្ថែមសម្រាប់សិស្សដែលមានតម្រូវការពិសេស។
- គាំទ្រកម្មវិធីសាលាកុមារមេត្រីសម្រាប់គ្រូក្នុងមូលដ្ឋាន និងក្រុមប្រឹក្សាកុមារ ដើម្បីបង្កើនការចូលរួម។
- បណ្តុះបណ្តាលគ្រូដើម្បីប្រាកដថា គ្រូទទួលបានតម្រូវការផ្នែកបច្ចេកទេសដើម្បីផ្លាស់ប្តូរការអនុវត្តនៅក្នុងថ្នាក់រៀនរបស់ពួកគេ។
- ការប្រើប្រាស់ហិបពង្រឹងអំណាន (សម្ភារៈសិក្សា) នៅក្នុងបណ្ណាល័យ ឬថ្នាក់រៀនដើម្បីពង្រឹងអំណានសម្រាប់ថ្នាក់ដំបូង។
- កម្មវិធីបំណិនជីវិតដែលផ្សារភ្ជាប់នឹងស្ថានភាពជាក់ស្តែងក្នុងមូលដ្ឋាន។
- បំប៉នភាពជាអ្នកដឹកនាំដល់អ្នកគ្រប់គ្រងសាលារៀន គណៈកម្មការទ្រទ្រង់សាលា ដើម្បីធានាថាពួកគេមានសមត្ថភាពគ្រប់គ្រងថវិកាអំណោយសាលារៀនត្រឹមត្រូវតាមនីតិវិធី។
- អប់រំសុខភាព និងការថែទាំ ដើម្បីប្រាកដថា កុមារស្ថិតក្នុងស្ថានភាពធូរធំផ្នែកសុខភាព ឬពិការទទួលបានការឧបត្ថម្ភ និងការព្យាបាល។

គម្រោងសាលារៀនល្អប្រសើរ (SfE) ផ្តោតលើការបង្កើនការចូលរួម និងគុណភាពអប់រំកម្រិតបឋមសិក្សា ព្រមទាំងកសាងសមត្ថភាពពង្រឹងការគ្រប់គ្រងសាលារៀន។ គោលដៅទាំងនេះស្របទៅតាមគម្រោងផែនការអភិវឌ្ឍរបស់ក្រសួងអប់រំ យុវជន និងកីឡា (អយក) និងគោលនយោបាយកម្មវិធីសាលាកុមារមេត្រី។

### ធាតុសំខាន់ៗនៃបច្ចេកទេសក្នុងការអនុវត្ត

- ការគាំទ្រផ្តែកលើអំណានថ្នាក់ដំបូង
- ការអនុវត្តន៍ដោយផ្តែកលើសិទ្ធិជាមូលដ្ឋាន
- ការផ្ទេរអំណាចដល់អ្នកពាក់ព័ន្ធ
- ភាពជាម្ចាស់ការក្នុងតំបន់
- គម្រោងផែនការដែលអនុវត្តប្រកបដោយនិរន្តរភាព។



*កុមារក្រោសាលាត្រូវបានចូលរៀនយកចិត្តទុកដាក់ខ្ពស់ពីសំណាក់លោកគ្រូអ្នកគ្រូ*



*កម្មវិធីចែកអាហារូបករណ៍ដល់សិស្សក្រីក្រ ដែលមានសិស្សពិការផងដែរ*

# “ ការអប់រំផ្តល់នូវក្តីសង្ឃឹមសម្រាប់អនាគត ”

## រូបភាពសកម្មភាពខ្លីៗ


សកម្មភាពយុទ្ធនាការប្រមូលកុមារចូលរៀន


គ្រូបង្រៀនរៀនរបៀបប្រើប្រាស់សម្ភារៈបង្រៀនថ្មី

## បច្ចុប្បន្នភាពគម្រោង

ជាទូទៅសូចនាករជាច្រើនបង្ហាញថា សាលារៀនបានរីកចម្រើនគួរឱ្យកត់សម្គាល់ដោយប្រៀបទៅនឹងទិន្នន័យមូលដ្ឋានតាំងពីចាប់ផ្តើមអនុវត្តគម្រោងនៅឆ្នាំ២០១២ ។ ប្រសិទ្ធភាពរីកចម្រើនមានដូចជា៖

- អត្រាបោះបង់ត្រូវបានកាត់បន្ថយ ៨%
- អត្រាឡើងថ្នាក់បានកើនឡើង ៥%
- សមភាពយែនឌ័របានកើនឡើង ៧%
- អសមាមាត្រគ្រូសិស្សកើនឡើងគួរឱ្យកត់សម្គាល់ គឺ ៤២%។

| ការវាស់វែង | ឆ្នាំចាប់ផ្តើមគម្រោង | ឆ្នាំបញ្ចប់គម្រោង | ការផ្លាស់ប្តូរ |
|---|---|---|---|
| អត្រាបោះបង់ | ១០% | ២% | -៨% |
| អត្រាឡើងថ្នាក់ | ៨៨% | ៩៣% | +៥% |
| សមភាពយេនឌ័រ នៃការចូលរៀនរបស់កុមារ | 0,៨ | 0,៨៧ | +0,0៦ |
| សមាមាត្រគ្រូសិស្ស | ៧៨,៦ទៅ១ | ៤៥,៥ទៅ១ | -៣៣,១ |

# ការផ្តោតលើសិស្ស

កុមារី អិមរ៉ន រ៉ស៊ីតៈអាយុ១០ឆ្នាំ គឺជាសិស្សអាហារូបករណ៍គម្រោង SfE។ នាងមកពីគ្រួសារក្រីក្រនៃសហគមន៍ខ្មែរឥស្លាមនៅប្រទេសកម្ពុជា។ រ៉ស៊ីតៈរស់នៅជាមួយម្តាយឈ្មោះ ក្រីម៉ះ ជាស្ត្រីមេម៉ាយម្នាក់ក្នុងផ្ទះឬស្សីមួយតាមដងទន្លេមេគង្គ ម្តាយនាងតស៊ូក្នុងការរស់នៅយ៉ាងលំបាកក្នុងភាពក្រីក្រ ដើម្បីពុះពាររាល់ការលំបាកដើម្បីផ្គត់ផ្គង់ឲ្យកូនមករៀន។ មុខរបរសំខាន់របស់ម្តាយនាងគឺការងារពនាចរស៊ីឈ្នួលគេដែលអាចរកប្រាក់ចំណូលបានប្រមាណជាពី ៣ ទៅ ៤ដុល្លាអាមេរិកក្នុងមួយថ្ងៃ។ លោក ទូល័ស ក្រីយ៉ា ជាហាកិម/ទូនរស់នៅសហគមន៍ខ្មែរឥស្លាមបានបញ្ជាក់ថា កត្តាវប្បធម៌នៅតែជាឧបសគ្គក្នុងការចូលរៀនដែលត្រូវបន្តដោះស្រាយ។ គាត់បន្ថែមទៀតថា “*យើងសង្កេតឃើញថានៅសាលារៀន កុមារជនជាតិខ្មែរឥស្លាមនិងកុមារខ្មែរពុំមានការរើសអើងអីទេ តែនៅមានបែងចែកក្រុមខ្លះនៅពេលលេង និងអង្គុយរៀនក្នុងថ្នាក់ដូច្នេះយើងខ្ញុំបានស្នើឲ្យនាយក គ្រូចាត់ចែងការអង្គុយរបស់សិស្សឲ្យមានចម្រុះខ្មែរ និងចាម*”។

ភាពក្រីក្រជាកត្តារារាំងសំខាន់មួយក្នុងការអប់រំ រ៉ស៊ីតៈ ត្រូវបានលើកទឹកចិត្តដោយគណៈកម្មការទ្រទ្រង់សាលាមាន លោក ម៉ាត់ ហាគីម និងសមាជិកដ៏ទៃទៀតទទួលបានអាហារូបករណ៍ពីគម្រោង SfE ជាសម្ភារៈសិក្សា ដូចជា៖ សម្លៀកបំពាក់ សៀវភៅ ប៊ិច ជាដើមដែលអាចកាត់បន្ថយនូវបន្ទុកដ៏ធ្ងន់ធ្ងរពីម្តាយរបស់នាង។

រស៊ីតៈ ទៅរៀនទៀងទាត់បន្ទាប់ពីបានទទួលកញ្ចប់អាហារូបករណ៍ពីគម្រោង នាងចូលរួមសកម្មភាពផ្សេងៗជាច្រើនជាមួយមិត្តរួមថ្នាក់ថ្មីនាងក្នុងក្រុមប្រឹក្សាកុមារ។ រ៉ស៊ីតៈ និយាយទាំងទឹកមុខញញឹមថា «*ខ្ញុំលែងមានការបារម្ភទៀតហើយទាក់ទងទៅនឹងសម្ភារៈសិក្សាព្រោះត្រូវបានឧបត្ថម្ភពីអង្គការ ខេប*»។ នាងទទួលបានខោអាវ ២កំប្លេ ស្បែកជើង ១គូ និងសម្ភារៈសិក្សាមួយចំនួនទៀត។ នាងទទួលបានការឧបត្ថម្ភពីគម្រោងចំនួន៣ឆ្នាំហើយ គឺតាំងពីនាងរៀនថ្នាក់ទី៣មកម្លេះ ឥឡូវនាងរៀនថ្នាក់ទី៥ហើយ។ នាងបានបន្តទៀតថា “*ខ្ញុំនឹងមិនបោះបង់ការសិក្សាទេពីព្រោះមានមនុស្សជាច្រើនជួយជ្រោមជ្រែងនាងខ្ញុំ និងគ្រួសារនាងខ្ញុំផងដែរ ហើយខ្ញុំនឹងខំរៀនឱ្យពូកែក្នុងថ្នាក់ទៀតផង*»។

ម្តាយ រ៉ស៊ីតៈ បានបញ្ជាក់ថា “*ខ្ញុំសែនរីករាយក្រៃលែងដែលកូនបានទទួលអាហារូបករណ៍ វាពិតជាពិបាកណាស់បន្ទាប់ ពា៉ រ៉ស៊ីតៈស្លាប់ទៅ ពេលខ្លះខ្ញុំត្រូវការ រ៉ស៊ីតៈ ជួយកិច្ចការមួយចំនួន។ ខ្ញុំពិតជាមិនចង់ទេ តែគ្មានជម្រើស*» *ទោះជាយ៉ាងណាក៏ដោយ ខ្ញុំរីករាយណាស់ព្រោះឃើញកូនស្រីទទួលបានលទ្ធផលល្អក្នុងការសិក្សា ហើយខ្ញុំពិតជាចង់ឱ្យកូនរបស់ខ្ញុំក្លាយទៅជាសិស្សពូកែណាស់ និងបន្តការសិក្សារហូតចប់តាមដែលអាចធ្វើទៅបាន*”។ រ៉ស៊ីតៈ រំពឹងថា នឹងអាចរៀនបញ្ចប់បឋមសិក្សានៅក្នុងឆ្នាំសិក្សាបន្ទាប់នេះផងដែរ៕





# ១៤

# គម្រោង អប់រំកុមារ (EAC)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | EDUCATE A CHILD (EAC)<br>• មូលនិធិ Qatar<br>• អង្គការ Aide et Action (AeA) |
| អ្នកទទួលផលផ្ទាល់ | សិស្សចំនួន ១០.០៨៧នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ ២០១៥ | ៦២.០៥១ ដុល្លារអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ៦ ដុល្លារអាមេរិក |
| ខេត្តគ្របដណ្តប់ | ២ខេត្ត (ត្បូងឃ្មុំ និងក្រចេះ) |
| ស្រុកគ្របដណ្តប់ | ៥ស្រុក |
| បឋមសិក្សាគោលដៅ | ៤០សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ១ មិថុនា ២០១៤ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ កក្កដា ២០១៧ |

## បច្ចុប្បន្នភាពគម្រោង

គម្រោង អប់រំកុមារ គឺជាសម្ព័ន្ធគម្រោងមួយមានចំនួន១៧អង្គការ ដែលគាំទ្រថវិកាដោយមូលនិធិអប់រំកុមារពីប្រទេសកាតា (Qatar) ហើយសម្របសម្រួលដោយ *Aide et Action*។ គម្រោងផ្តោតចម្បងលើការប្រមូលកុមារក្រៅសាលាចូលរៀន ដែលបែងចែកជា៥ក្រុម៖ (I) ក្រុមផ្តោតលើកុមារពិការ (II) ក្រុមផ្តោតលើកុមារជនជាតិភាគតិច (III) ក្រុមផ្តោតលើកុមារនៅតំបន់ដាច់ស្រយាល (IV) ក្រុមផ្តោតលើកុមារអនាថាតាមចិញ្ចើមផ្លូវក្នុងទីប្រជុំជន និង (V) ក្រុមផ្តោតលើលើកុមារលើសអាយុ។ អង្គការ ខេប អនុវត្តគម្រោងនេះផ្តោតលើក្រុមកុមារជនជាតិភាគតិច ជាពិសេស ជនជាតិចាម និងកុលសម្ព័ន្ធនៅតាមភ្នំក្នុងខេត្តក្រចេះ។ គម្រោងផ្តោតលើវិស័យសំខាន់ៗចំនួន៤គឺ៖

- **បន្តភាពងាយស្រួលចូលសាលា:** បង្កឱកាសដល់កុមារក្រៅសាលាក្នុងតំបន់ គោលដៅរបស់គម្រោងឱ្យទទួលបានការអប់រំក្នុងប្រព័ន្ធរដ្ឋ និងរក្សាពួកគេឱ្យនៅគង់វង្ស។
- **គុណភាព និងប្រសិទ្ធភាពការអប់រំ:** បង្កើនគុណភាពអប់រំ និងផ្តល់ការអប់រំដែលមានការពាក់ព័ន្ធទៅនឹងការរស់នៅដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា ហើយធានាថា កុមារទទួលការអប់រំប្រកបដោយស្តង់ដា។
- **ការកសាងសមត្ថភាពអ្នកពាក់ព័ន្ធ:** អភិវឌ្ឍសមត្ថភាពអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន ដូចជា៖ ក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យ (DTMTs) គណៈកម្មការទ្រទ្រង់សាលារៀន និងដើម្បីកែលម្អរដ្ឋបាលសាលារៀន។
- **ការស្រាវជ្រាវ និងការតស៊ូមតិ:** ដោះស្រាយកត្តាកង្វះគ្រូក្នុងប្រព័ន្ធអប់រំដែលរារាំងការចូលរៀន ដូចជា ការកង្វះគ្រូ និងសាលាមិនគ្រប់កម្រិត។ល។



## គោលបំណងសកល

គោលបំណងសំខាន់របស់គម្រោង អប់រំកុមារ (EAC) គឺដើម្បីផ្តល់នូវការអប់រំបរិយាបណ្ណនៃប្រព័ន្ធអប់រំកម្ពុជាដែលបំពេញបំណងដល់កុមារគ្រប់រូប រួមមាន៖ កុមារក្រៅសាលា កុមារពិការ កុមារជនជតិភាគតិច កុមារលើសអាយុ កុមាររស់នៅតំបន់ជនបទដាច់ស្រយ៉ាល និងកុមារអនាថារស់នៅតាមចិញ្ចើមថ្នល់ក្នុងទីប្រជុំជន។



កុមារចូលរួមសប្បាយរីករាយនៅថ្ងៃចូលរួមរៀនដំបូងនៅក្នុងសាលា

## សកម្មភាពកម្មវិធី

- → កសាងអាគារឆ្លងកាត់/ជ្រើសរើសគ្រូសហគមន៍ ដើម្បីប្រាកដថា មានគ្រូបង្រៀន
- → យុទ្ធនាការប្រមូលកុមារចូលរៀនសម្រាប់ប្រមូលកុមារក្រៅសាលា
- → គូរផែនទីសិក្សា និងផ្តល់អាហារូបករណ៍សមម្រាប់សិស្សក្រីក្រ/សិស្សក្រៅសាលា
- → កម្មវិធីកុមារជួយកុមារ គឺផ្តោតទៅលើកុមារធំជួយកុមារតូច
- → ជ្រើសរើស និងបណ្តុះបណ្តាលគ្រូជំនួយភាសា (បកប្រែពីរភាសា រើសចេញសហគមន៍ជនជាតិភាគតិចក្នុងមូលដ្ឋាន)
- → បណ្តុះបណ្តាលគ្រូដើម្បីធានាថា គ្រូមានបច្ចេកទេស វិធីសាស្ត្រដើម្បីផ្លាស់ប្តូរក្នុងការអនុវត្តន៍សកម្មភាពបង្រៀននៅក្នុងថ្នាក់រៀនរបស់ពួកគេ។
- → រៀបចំថ្នាក់បំប៉នសិស្សរៀនយឺតតាមភូមិសម្រាប់កុមារដែលត្រូវការសិក្សាពិសេស
- → ផ្តល់កម្មវិធីបំណិនជីវិតដែលផ្សារភ្ជាប់នឹងស្ថានភាពជាក់ស្តែងក្នុងមូលដ្ឋាន។
- → បណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់នាយកសាលា និងសហគមន៍ដើម្បីប្រាកដថាអ្នកពាក់ព័ន្ធមានជំនាញក្នុងការគ្រប់គ្រង និងត្រួតពិនិត្យថវិកាប្រកបដោយប្រសិទ្ធភាព។
- → ប្រជុំពីសហគមន៍/មាតាបិតាសិស្សដើម្បីកំណត់អំពីសិស្សក្រៅសាលារៀន
- → ក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យ (DTMTs) តាមដាន និងធ្វើរបាយការណ៍ស្តីពីដំណើរការមូលដ្ឋាននៅសាលារៀនជាប្រចាំ។

# “ ធ្វើឱ្យសាលារដ្ឋមានជនជាតិភាគតិចបានចូលរៀនស្ថិទស្ថាល ”

## រូបភាពសំខាន់ៗ



*ដោយការគាំទ្រពីគម្រោង EAC សហគមន៍បានចាប់ផ្តើមកសាងអគារឆ្លងកាត់ ដើម្បីកុមារបានចូលរៀនទាន់ពេល*



*សិស្សជនជាតិភាគតិចរីករាយនឹងសកម្មភាពបំណិនជីវិត*

## ផលជះរបស់គម្រោង

ជាទូទៅ សូចនាករជាច្រើនបានបង្ហាញពីប្រសិទ្ធភាពនៅសាលារៀនគួរឱ្យកត់សម្គាល់ក្នុងតំបន់គោលដៅ។ ក្នុងឆ្នាំដំបូងនៃប្រតិបត្តិការរបស់គម្រោង កុមារក្រៅសាលាចំនួន៥៦៦នាក់ត្រូវបានអន្តរាគមន៍ឱ្យបានចូលរៀននៅសាលារៀនរដ្ឋក្នុងប្រព័ន្ធអប់រំចំណេះទូទៅ។ គម្រោងបានសម្រេចគោលដៅប្រមាណ៩៨%សម្រាប់ឆ្នាំនេះ។ កុមារទាំងអស់នេះភាគច្រើននៅតាមតំបន់ដាច់ស្រយាល និងមានតិចតួចនៅជនបទ។ លទ្ធផលសំខាន់ៗនៅក្នុងឆ្នាំនេះ រួមមានៈ

- កសាងអាគារឆ្លងកាត់បាន១៦បន្ទប់រួចរាល់។
- ការជ្រើសរើស និងបណ្តុះបណ្តាលគ្រូសហគមន៍ចំនួន២០នាក់ ដើម្បីធ្វើជាបុគ្គលិកនៅសាលាដែលខ្វះគ្រូ/សាលាឆ្លងកាត់ ដើម្បីដោះស្រាយបញ្ហាខ្វះគ្រូបង្រៀននៅតាមសាលាជាច្រើន។
- ការផ្តល់កញ្ចប់អាហារូបករណ៍ដល់កុមារចំនួន៥០០នាក់នៅក្នុងឆ្នាំនេះ។
- គម្រោងបានបណ្តុះបណ្តាលគ្រូចំនួន៨៩នាក់អំពីកម្មវិធីសាលាកុមារមេត្រី។
- បន្ទប់រៀនចំនួន៤៨ត្រូវបានជួសជុល ឬកសាងឡើងវិញ។
- សាលាទាំង២៨ក្នុងចំណោម២៩ត្រូវបានធ្វើផែនទីសាលារួច។
- ផ្តល់គ្រូជំនួយបង្រៀនពីរភាសានៅតាមសាលាជាច្រើនដើម្បីបង្កើនការចូលរួមក្រុមជនជាតិភាគតិច ដែលមានការពិបាកបង្រៀនពីគ្រូខ្មែរជនជាតិភាគតិច។

## ករណីសិក្សា

រ៉ាន សុខនី គឺជាកុមារីមានអាយុ៦ឆ្នាំ និងកំពុងរៀននៅថ្នាក់ទី១។ នាងជាកូនស្រីដែលមានដើមកំណើតជាជនជាតិភាគតិចព្នង ហើយជាកូនពៅក្នុងគ្រួសាររបស់នាង។ នាងរស់នៅជាមួយឪពុកម្តាយរបស់នាង និងបងស្រីនៅក្នុងតំបន់ដាច់ស្រយាលមួយក្នុងខេត្តត្បូងឃ្មុំ។ ផ្ទះសុខនីមានចម្ងាយប្រមាណ៩គម ពីសាលារៀន ដែលធ្វើឱ្យនាងមានការលំបាកក្នុងការធ្វើដំណើរទៅសាលារៀន។

ឪពុកម្តាយសុខនីមានការលំបាកក្នុងការបញ្ជូនកូនទៅសាលារៀន។ ពួកគាត់ធ្វើការងារជារៀងរាល់ថ្ងៃ ហើយគ្មានពេលបញ្ជូននាងទៅសាលារៀនដែលនៅឆ្ងាយពីផ្ទះ និងទៅយកនាងមកពីសាលារៀនវិញពេលល្ងាចនោះទេ។ នាងនៅក្មេងខ្ចីណាស់ មិនអាចធ្វើដំណើរក្នុងចម្ងាយពីផ្ទះទៅសាលារៀនបាន។ ដូច្នេះ ឪពុកម្តាយរបស់នាងក៏បានសម្រេចចិត្តទុកនាងនៅផ្ទះមួយឆ្នាំទៀតរហូតដល់នាងពេញវ័យបន្តិចដោយសារនាងអាចជួយមើលគោនៅផ្ទះនៅពេលពួកគាត់ជាប់កិច្ចការរវល់ចេញឆ្ងាយពីផ្ទះដែរ។

ជាភព្វសំណាង គម្រោង EAC និងសហគមន៍បានកសាងសាលារៀនឆ្លងកាត់ដែលនៅជិតផ្ទះកុមារី សុខនី។ ម្តាយរបស់នាងបាននិយាយថា គាត់សប្បាយចិត្តណាស់ដែលមានសាលារៀនថ្មីនៅជិតផ្ទះគាត់រស់នៅ។ បង្ហាញផ្ទៃមុខរីករាយលាយទឹកភ្នែក គាត់និយាយថា *“ខ្ញុំពិតជាសប្បាយចិត្តណាស់ដោយសារកូនខ្ញុំអាចទៅសាលារៀន និងទទួលការឧបត្ថម្ភបន្ថែមជាសម្ភារៈសិក្សាពីអង្គការ ខេប តាមរយៈគម្រោង EAC”*។ លោក ឈៀង សំអៀន ជាគ្រូរបស់សុខនី បានប្រាប់មន្ត្រីគម្រោងថា ឥឡូវនេះ សុខនី អាចអាន និងនិយាយភាសាខ្មែរបាន និងក៏អាចសរសេរអក្សរខ្មែរបានផងដែរ។ លទ្ធផលសិក្សារបស់នាងបច្ចុប្បន្ននេះគឺខុសប្លែកពីកាលនាងទើបបានចូលសាលារៀនដំបូង ដែលពេលនោះស្ទើតែមិនអាចនិយាយភាសាខ្មែរបាន ទាំងអាន និងសរសេរ។ សុខនីទទួលបានអាហារូបករណ៍ពីគម្រោងដែលរួមមានសម្ភារៈសិក្សា ឯកសណ្ឋាន និងស្បែកជើង ធ្វើឱ្យនាងមានភាពងាយស្រួលទៅសាលារៀន។

លោក ឯម ឈឿន ជាសមាជិកសហគមន៍ម្នាក់ដែលបានជួយកសាងសាលាឆ្លងកាត់បានលើកឡើងថា គាត់សប្បាយចិត្តខ្លាំងណាស់ព្រោះបច្ចុប្បន្នមានកុមារជាច្រើននៅក្នុងសហគមន៍របស់គាត់អាចចូលមករៀនដើម្បីអភិវឌ្ឍគំនិតរបស់ពួកគេ។

គាត់បានលើកទឹកចិត្តដល់កុមារទាំងអស់ ក៏ដូចជាកុមារី សុខនី ត្រូវខិតខំរៀនសូត្រឱ្យខ្លាំង។ គាត់សប្បាយចិត្តដោយសារកុមារជាច្រើនក្នុងភូមិអាចអាន និងសរសេរភាសាខ្មែរបានល្អដូចជាភាសាកំណើតព្នងរបស់ពួកគេដែរ។ ដើម្បីបង្ហាញសេចក្តីដឹងគុណ លោកបានដឹកនាំកសាងសាលាបុណ្យនៅក្បែរសាលារៀនមួយទៀតដើម្បីធ្វើបុណ្យរក្សាប្រពៃណីរបស់ពួកគេ។



ចុងក្រោយ សុខនី បាននិយាថា *“ខ្ញុំចង់រៀនពេទ្យនៅថ្ងៃអនាគត។ ខ្ញុំសូមអរគុណអង្គការ ខេប តាមរយៈគម្រោង EAC និងគ្រូ ដែលបានជួយខ្ញុំចូលរៀន និងរៀនចេះច្រើន។”*

*← រ៉ាន សុខនី អង្គុយអនុញ្ញាតឱ្យថតរូបនៅផ្ទះក្នុងពេលនាងកំពុងធ្វើលំហាត់។ ឥឡូវ នាងមានឯកសណ្ឋានសាលារៀនស្អាត ធ្វើឱ្យនាងមានមោទនភាព។ នៅពេលកសាងសាលារៀនឆ្លងកាត់នៅក្បែរផ្ទះ នាងបានមករៀនទៀងទាត់ជាមួយកុមារដទៃទៀតក្នុងភូមិ ហើយនាងចាប់ផ្តើមរៀនអាន និងសរសេរភាសាខ្មែរបានល្អ។*

១៦

# កម្មវិធីអប់រំបញ្ចូលគ្នា (IEP)

អង្គការ ខេប តែងតែប្រឈមនឹងការគ្រប់គ្រងគម្រោងតូចៗដោយសារតែទទួលបានថវិកាមិនបានច្រើន និងមិនអាចជួយគាំទ្រលើការចំណាយផ្នែកគ្រប់គ្រងរដ្ឋបាលទាំងស្រុង។ ទោះជាយ៉ាងនេះក្តី គម្រោងទាំងនេះគឺជាការផ្តួចផ្តើមដ៏មានតម្លៃ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ អង្គការ ខេប បានបញ្ចូលគម្រោងតូចៗ និងមធ្យោបាយមួយចំនួនស្ថិតក្រោមឆ័ត្រតែមួយរបស់កម្មវិធីមួយឈ្មោះថា កម្មវិធីអប់រំបញ្ចូលគ្នា ឬហៅកាត់ថា IEP។ គោលបំណងដ៏សំខាន់របស់គម្រោងគឺដើម្បីបង្កើនភាពងាយស្រួលចូលសាលារៀន ជាពិសេស កុមារី កុមារជនជាតិ និងកុមារ ឬយុវជនងាយរងគ្រោះដទៃទៀត។ កម្មវិធីអប់រំបញ្ចូលគ្នាជួយកុមារ និងយុវជននៅកម្រិតបឋមសិក្សាដល់សាកលវិទ្យាល័យ កម្រិតវិជ្ជាជីវៈ បណ្តុះបណ្តាលគ្រូជាដើម។ កម្មវិធី IEP បង្កើតឡើងដើម្បីកាត់បន្ថយចំណាយផ្សេងៗ និងចំណេញពេលវេលា ដោយមានអ្នកសម្របសម្រួលតែម្នាក់គ្រប់គ្រងគម្រោងទាំងអស់នោះ។ មានគម្រោងចំនួនបីក្នុងកម្មវិធីអប់រំបញ្ចូលគ្នា រួមមានៈ ១) គម្រោងអប់រំកុមារី (GIE) ២) គម្រោងអប់រំជនជាតិព្នង (PEI) និងគម្រោងអាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ (CTSP)។

| | **គម្រោងអប់រំកុមារី (GEI)** | **គម្រោងអប់រំជនជាតិព្នង (PEI)** | **គម្រោងអាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ (CTSP)** |
|---|---|---|---|
| ម្ចាស់ជំនួយ | អង្គការមូលនិធិ *Oaktree* | អង្គការ *Lotus Outreach* | អង្គការមូលនិធិអាស៊ី (TAF) |
| ថវិកាប្រចាំឆ្នាំ ២០១៥ | **៩០.៦៥៤ ដុល្លារអាមេរិក** | **២២.៥៧៧ ដុល្លារអាមេរិក** | **៤៧.២៧០ ដុល្លារអាមេរិក** |
| អ្នកទទួលផលផ្ទាល់ និងសកម្មភាពសំខាន់ៗ | • សិស្សអាហារូបករណ៍ ៣៣៨នាក់ (ស្រី ២៥៤នាក់)<br>• សិស្សអាហារូបករណ៍វិជ្ជាជីវៈ ២៦នាក់ (ស្រី ១៥នាក់)<br>• សិស្សរៀនជំនាញអាជីព ៦០នាក់ (ស្រី ៤៨នាក់)<br>• មាតាបិតាសិស្ស៤០នាក់ ទទួលផលពីកម្មវិធីបំណិន<br>• សិស្ស ៤១៤នាក់ (ស្រី ២៧៣នាក់) ចូលរួមកម្មវិធីបំណិនជីវិត (ជលារវប្បកម្ម ការបណ្តុះរុក្ខជាតិ ការចិញ្ចឹមត្រី)<br>• ស៊ីហ្វាក់ចំនួន ៨នាក់<br>• អ្នកផ្តល់ប្រឹក្សា ២៨នាក់<br>• សិស្ស១.២៦៨នាក់ (ស្រី ៥៧០នាក់) ទទួលផលប្រឹក្សាអាជីព<br>• សាលារៀនចំនួន៧បានបង្កើតក្រុមប្រឹក្សាកុមារ<br>• គណៈកម្មាការគ្រប់គ្រងអាហារូបករណ៍ថ្នាក់មូលដ្ឋាន ១២នាក់(ស្រី៨នាក់)<br>**សរុបៈ ២.១៩៧នាក់ (ស្រី ១.១៦៣នាក់)** | • សិស្សអាហារូបករណ៍ព្នង៣១នាក់ (ស្រីទាំងអស់)<br>• អាហារូបករណ៍គរុសិស្សព្នង២០នាក់ (ស្រីទាំងអស់)<br>• សិស្ស ៩៦នាក់ (ស្រី ៣១នាក់) ក្លឹបស្រាវជ្រាវវប្បធម៌ព្នង<br>• សិស្ស ៤៤នាក់ (ស្រី ២៥នាក់) និងគ្រូ ១០នាក់ (ស្រី ៤នាក់) បានរៀបចំប្រារព្ធទិវាកុមារអន្តរជាតិ<br>• មណ្ឌលវប្បធម៌១<br>• បន្ទប់ទឹក១<br>• អណ្តូងស្នប់១<br>**សរុបៈ ១៩៧នាក់ (ស្រី ១១១នាក់)** | និស្សិតសាកលវិទ្យាល័យ ៩៦នាក់ (ស្រីទាំងអស់)<br>ការអភិវឌ្ឍអាជីពៈ<br>• វគ្គសិក្សាកុំព្យូទ័រ<br>• វគ្គបណ្តុះបណ្តាលខ្លីៗ<br>**សរុបៈ ៩៦នាក់(ស្រីទាំងអស់)** |
| ចំនួនសាលា | ១២ អនុវិទ្យាល័យ និងវិទ្យាល័យ<br>៣ វិទ្យាស្ថានដទៃទៀត (សាលាគរុកោសល្យ និងវិក្រឹតការខេត្ត សាលាគរុកោសល្យភូមិភាគ និងវិទ្យាស្ថានបច្ចេកវិទ្យា) និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន៣នៅប្រទេសថៃ | ២ អនុវិទ្យាល័យ<br>១ សាលាគរុកោសល្យ និងវិក្រឹតការ | ១ សាកលវិទ្យាល័យ<br>(សាកលវិទ្យាល័យ វេស្ទើន) |
| ថវិកាអ្នកទទួលផលក្នុងម្នាក់ | **៤២ដុល្លារអាមេរិក** | **៨៨ដុល្លារអាមេរិក** | **៩០២ដុល្លារអាមេរិក** |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | **សីហា ២០០០** | **មករា ២០១០** | **វិច្ឆិកា ២០១០** |
| កាលបរិច្ឆេទបញ្ចប់គម្រោង | **ធ្នូ ២០១៨** | **ធ្នូ ២០១៥** | **កញ្ញា ២០១៥** |

**គម្រោងអប់រំកុមារីៈ** គឺជាគម្រោងដែលមានការគាំទ្រ មានថវិកាកាន់តែច្រើន និងជាគម្រោងដែលមានអាយុកាលវែង។ ចាប់តាំពីគម្រោងចាប់ផ្តើមជាសញ្ញាណមួយបង្ហាញថា ការអប់រំកម្រិតមធ្យមសិក្សាក្នុងប្រទេសកម្ពុជាកាន់តែមានសមភាពយែនឌ័រ។ ចំពោះការចូលរៀននៅកម្រិតមធ្យមសិក្សារបស់ក្មេងស្រីគឺកើនពី០.៦៨ ក្នុងឆ្នាំ២០០១ ដល់ ១.០២ ក្នុងឆ្នាំ ២០១៥ សម្រាប់ខេត្តកំពង់ចាម និងត្បូងឃ្មុំ (កម្រិតស្មើគ្នានៃការចូលរៀនស្មើនឹង១)។ កម្រិតស្មើគ្នានៃការចូលរៀននេះគឺសំដៅលើកុមារា និងកុមារី។ ផ្ទុយទៅវិញ យុវជនកម្ពុជាមានអាយុចាប់ពី១៥ឆ្នាំទៅ២៩ឆ្នាំ ចំនួន៤.៣៨៩.០០០នាក់ ក្នុងនោះមានត្រឹមតែ៥%ប៉ុណ្ណោះបានចូលរៀនកម្រិតសាកលវិទ្យាល័យនាពេលថ្មីៗនេះ។ ចំពោះក្រុមយុវជនចំនួនតូចនោះ គឺក្នុងនោះមាននារីត្រឹមតែ៣៩%ប៉ុណ្ណោះ។ វាគឺមានសារៈសំខាន់ក្នុងការតស៊ូមតិឱ្យស្ត្រីបានចូលរៀនកាន់តែច្រើននៅកម្រិតសាកលវិទ្យាល័យ និងវិទ្យាល័យ។



## ករណីសិក្សាសិស្សអាហារូបករណ៍

**លី សុភា** មានអាយុ១៩ឆ្នាំ គឺជានិស្សិតឆ្នាំទី១ផ្នែកប្រព័ន្ធបណ្តាញរដ្ឋបាល (Systems Network Administration) នៅវិទ្យាស្ថាន *Passerelles Numeriques Cambodia (PNC)* ទីក្រុងភ្នំពេញ ឯកទេសកម្មវិធីបច្ចេកវិទ្យាកុំព្យូទ័រ។ សុភា បានទទួលអាហារូបករណ៍ពីអង្គការ ខេប តាមរយៈគម្រោងអប់រំកុមារី។ ឪពុកម្តាយរបស់នាងជាកសិករ ហើយចំណូលគឺបានមកពីការធ្វើស្រែចំការសុទ្ធសាធ។ ប៉ុន្មានឆ្នាំកន្លងមកនេះ គ្រួសាររបស់នាងខាតបង់ពីការធ្វើស្រែដោយសារទឹកជំនន់ ហើយពួកគេបានខ្ចីលុយពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៉ុន្តែជាអកុសលគ្រួសារនាងមិនអាចរកប្រាក់ចំណូលដើម្បីបង់ថវិកាកម្ចីបាន ទើបពួកគេបានលក់ដីរបស់ខ្លួនមួយចំនួន។

សុភា ជាក្មេងស្រីសុភាពរាបសារ មានទំនាក់ទំនងល្អជាមួយមិត្តភក្តិ និងខិតខំរៀនសូត្រ ទោះជាដូច្នេះក្តី នាងរៀនទទួលបានពិន្ទុមិនទាន់បានល្អទេ តែនាងប្រឡងជាប់គ្រប់មុខវិជ្ជា។ នាងនិយាយថា នៅពេលនាងបញ្ចប់ការសិក្សា នាងចង់បន្តការសិក្សានៅសាកលវិទ្យាល័យ។ នាងនឹងជួយគ្រួសាររបស់នាងនៅពេលដែលនាងអាចរកប្រាក់ចំណូលបាន។ ចុងក្រោយ នាងនឹងជួយបងប្អូនប្រុសស្រីរបស់នាងឲ្យបានបន្តការសិក្សារបស់ពួកគេ៕

# គម្រោង អប់រំកុមារី (GEI)

## បច្ចុប្បន្នភាពគម្រោង

នៅក្នុងឆ្នាំ២០១៥ ចំនួនសិស្សសរុប ៤២៣នាក់ (ស្រី ៣១៤នាក់) បានទទួលអាហារូបករណ៍សិក្សានៅអនុវិទ្យាល័យ វិទ្យាល័យ និងសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈ រួមមានជំនាញ៖ អគ្គិសនី អេឡិចត្រូនិច ការចិញ្ចឹមសត្វ និងកសិកម្ម។ សិស្សផ្សេងទៀតបានសិក្សានៅសាលាគរុកោសល្យ និងវិក្រិតខេត្ត និង ១១នាក់ទៀតសិក្សានៅសាកលវិទ្យាល័យនៅប្រទេសថៃកម្រិតបរិញ្ញាបត្ររយៈពេលពីរឆ្នាំ រួមមាន៖ ស្ថាបត្យកម្ម អេឡិចត្រូនិច សណ្ឋាគារ និងសេវាកម្ម គីមីអាហារ បច្ចេកវិទ្យាកុំព្យូទ័រ និងគណនេយ្យ។ កញ្ចប់អាហារូបករណ៍កម្រិតវិទ្យាល័យ មានដូចជា៖ សៀវភៅ ប៊ិច ឯកសណ្ឋាន ថវិកាប្រចាំខែ ថៃទាំសុខភាព និងបង្រៀនគួរបន្ថែម។

អង្គការ ខេប បានតស៊ូមតិដ៏គួរឱ្យភ្ញាក់ផ្អើលជាមួយនឹងបណ្ដាវិទ្យាស្ថានក្នុងប្រទេសកម្ពុជា និងប្រទេសថៃ។ ដោយគួរឱ្យសរសើរ គម្រោង អប់រំកុមារីបង្កើតទំនាក់ទំនងយ៉ាងល្អជាមួយរដ្ឋាភិបាលថៃ និងវិទ្យាស្ថាន *Pass erelles Numerique Cambodia (PNC)* ដែលជាវិទ្យាស្ថានបណ្ដុះបណ្ដាលបច្ចេកវិទ្យាកុំព្យូទ័រ នៅទីក្រុងភ្នំពេញឱ្យបានសិក្សាដោយឥតបង់ថ្លៃ និងការស្នាក់នៅរយៈពេលពីរឆ្នាំដល់សិស្សចំនួន ១៦នាក់។ ក្នុងនោះសិស្ស ១១នាក់កំពុងសិក្សាឆ្នាំទី២នៅប្រទេសថៃ និងចំនួន៥នាក់ទៀតកំពុងសិក្សាឆ្នាំទី១ ផ្នែកបច្ចេកវិទ្យាកុំព្យូទ័រនៅប្រទេសកម្ពុជា។ តាមរយៈការតស៊ូមតិរបស់អង្គការផ្ទាល់ រដ្ឋាភិបាលប្រទេសថៃស្ថិតក្រោមគម្រោងម្ចាស់ក្សត្រីបានយល់ព្រមចំណាយលើថ្លៃបង់ការសិក្សា និងការស្នាក់នៅដល់និស្សិតអាហារូបករណ៍របស់គម្រោង អប់រំកុមារី។

សិស្សអាហារូបករណ៍ថ្នាក់ទី១២ ចំនួន២២៩នាក់ (ស្រី១៦៩នាក់) ស្មើនឹង៩៥% អន្តរាគមន៍ដោយគម្រោង អប់រំកុមារីបានប្រឡងជាប់ថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា ២០១៤-២០១៥ ដែលប្រហែលនឹងភាគរយសិស្សប្រឡងទូទាំងប្រទេស។ សិស្សទទួលបាននិទ្ទេស B, C, D និង E ។ ១២%នៃសិស្សសរុបថ្នាក់ទី១២ អន្តរាគមន៍ដោយគម្រោងបានទទួលអាហារូបករណ៍សិក្សាដោយឥតបង់ថ្លៃសិក្សានៅកម្រិតសាកលវិទ្យាល័យផ្នែកគ្រូពេទ្យ បច្ចេកវិទ្យាកុំព្យូទ័រ គ្រូបង្រៀន គ្រប់គ្រង ទីផ្សារ សណ្ឋាគារទេសចរបរិស្ថាន និងកសិកម្មក្នុងខេត្តកំពង់ចាម និងភ្នំពេញ។ ៤៣%នឹងប្រឡងធ្វើជាគ្រូបង្រៀន។ ចំនួន៦%នៃសិស្សប្រឡងធ្លាក់ទី១២ បានដាក់ពាក្យសិក្សានៅវិទ្យាស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់រដ្ឋាភិបាលដោយឥតបង់ថ្លៃការសិក្សា និងស្នាក់នៅ។ ចំណែកឯសិស្សផ្សេងទៀតធ្វើការនៅរោងចក្រ ឬចុះឈ្មោះចូលរៀនថ្នាក់ទី១២ឡើងវិញ។




គរុសិស្សចំនួន៤០នាក់ (ស្រី៣០នាក់) បានបញ្ចប់វគ្គបណ្ដុះបណ្ដាលគ្រូរយៈពេល២ឆ្នាំនៅសាលាគរុកោសល្យ និងវិក្រិតការខេត្តកំពង់ចាម ហើយពួកគេនឹងក្លាយជាគ្រូបឋមសិក្សា និងមធ្យមសិក្សានៅខែវិច្ឆិការ ២០១៥ នេះ នៅខេត្តកំពង់ចាម និងត្បូងឃ្មុំ។

សិស្សជាង ១.២០០នាក់បានចូលរួមសកម្មភាពបំណិនជីវិតតាមសាលារៀននៅឆ្នាំនេះ។ ប្រធានបទដែលពួកគេបានសិក្សា រួមមាន៖ ការផ្ដល់ប្រឹក្សាយោបល់ បំណិនជីវិត យុទ្ធនាការអប់រំ និងសកម្មភាពក្រុមប្រឹក្សាកុមារ។ ប្រធានបទទាំងនេះអាចជួយសិស្សកំណត់គោលដៅ និងជ្រើសរើសមុខជំនាញសិក្សានៅពេលបញ្ចប់ការសិក្សាពីវិទ្យាល័យ។

គម្រោងផ្ដល់ថវិកាចំនួន៨០ដុល្លាដល់គ្រួសារសិស្សទទួលអាហារូបករណ៏ក្នុង១នាក់សម្រាប់ទិញមាន់ ជ្រូក ចំណី ថ្នាំវ៉ាក់សាំង និងសំណាញ់។ បំណិនជីវិតនោះរួមមាន៖ ចិញ្ចឹមសត្វ និងដាំបន្លែ។ គ្រួសារទាំងនោះទទួលបានវគ្គបណ្ដុះបណ្ដាល និងបង្រៀនពីវិធីកត់ត្រាប្រាក់ចំណាយ និងចំណូល។ សមាជិកគណៈកម្មការអប់រំទាំងអស់គ្នាថ្នាក់ឃុំជួយតាមដានក្រុមគ្រួសារ ដែលទទួលបានបំណិនជីវិតពីគម្រោង។ សូមពិនិត្យមើលចំនួនគ្រួសារសិស្សអាហារូបករណ៏ទទួលបានបំណិនជីវិតខុសៗគ្នាក្នុងប្រអប់ខាងក្រោម៖




**សុផល**គឺជាម្ដាយមេម៉ាយម្នាក់។ ប្ដីរបស់គាត់បានចែកឋានបន្ទាប់ពីកូនភ្លោះទាំងពីររបស់ពួកគេកើតបានរយៈពេលបីខែប៉ុណ្ណោះ។ គាត់មានកូន៥នាក់ កូនប្រុសពីរនាក់ និងកូនស្រីបីនាក់ ហើយគាត់ពុំទាន់មានផ្ទះទេ។ គាត់រស់នៅជាមួយបងប្រុសថ្លៃ។ កូនប្រុសរបស់គាត់ឈ្មោះ តុង ហេង គឺជាសិស្សអាហារូបករណ៍របស់គម្រោង អប់រំកុមារីកំពុងសិក្សាថ្នាក់ទី៩ និងទទួលបានអាហារូបករណ៍រយៈពេលបីឆ្នាំហើយ។ មុនពេលប្ដីស្លាប់ អ្នកស្រីសុ ផល និងប្ដីគាត់បានជិះម៉ូតូដឹកចេកមួយជាលធំទៅផ្សារ។ នៅរដូវភ្លៀង ពួកគាត់ត្រូវស្នាក់ផ្ទះអ្នកភូមិមួយយប់មុនពេលធ្វើដំណើរតាមទូកដរទៅដល់ផ្សារពេលព្រឹកព្រលឹម។ ឥឡូវនេះគាត់មិនប្រកបមុខរបរនេះបានទៀតទេ ព្រោះគាត់មិនអាចធ្វើដំណើរឆ្ងាយពីកូនភ្លោះតូចៗរបស់នាងបាន។ ជំនួយដោយការធ្វើដំណើរឆ្ងាយ គាត់ត្បាញក្រម៉ានៅផ្ទះ ដែលគាំទ្រថវិកាពីគម្រោងចំនួន ៨០ដុល្លាអាមេរិកសម្រាប់ធ្វើដើមទុនរកស៊ី៕



## “ កម្មវិធីអប់រំបញ្ចូលគ្នា: លើកកម្ពស់សិទ្ធិអប់រំរវាងក្រុមជនជាតិព្នង ”

# គម្រោង អប់រំជនជាតិព្នង (PEI)

អង្គការ Lotus Outreach អន្តរជាតិបានផ្តល់ជំនួយដល់គម្រោង អប់រំជនជាតិព្នងក្នុងរយៈពេល៥ឆ្នាំ ដែលបានបញ្ចប់គម្រោងនៅខែធ្នូ ឆ្នាំ២០១៥។ គម្រោងនេះមានគោលបំណងជំរុញកុមារជនជាតិព្នង ដែលមានបញ្ហាក្នុងការនិយាយភាសាខ្មែរឱ្យបានចូលរៀនសាសារដ្ឋ។ គម្រោងនេះជំរុញឱ្យមានការផ្លាស់ប្តូរបីកម្រិត ១.តស៊ូមតិឱ្យស្ត្រីព្នងបានចូលរៀនធ្វើជាគ្រូបឋមសិក្សាដោយមានការផ្តល់ជំនួយពីគម្រោង ២.ផ្តល់អាហារូបករណ៍ដល់ក្មេងស្រីជនជាតិព្នងសិក្សានៅកម្រិតមធ្យមសិក្សា និងបន្តធ្វើជាបេក្ខជនប្រឡងធ្វើជាគ្រូបង្រៀន ៣.លើកស្ទួយការស្វែងយល់ពីគ្នាទៅវិញទៅមករវាងសហគមន៍ខ្មែរ និងព្នងក្នុងសាលាគាំទ្រដោយគម្រោង។ គម្រោងនេះលើកស្ទួយការយល់ដឹងពីវប្បធមិជនជាតិភាគតិចព្នងក្នុងចំណោមក្មេងជនជាតិខ្មែរនៅសាលារៀន និងសហគមន៍តាមរយៈសកម្មភាពដែលបង្ហាញពីវប្បធមិខុសគ្នា។ ឧ. របាំ បំណិនជីវិត ការប្រារព្ធពិធីសំខាន់ៗ ដូចជា ការរៀបអាពាហ៍ពិពាហ៍ និងពិធីបុណ្យសព។ លទ្ធផលទាំងនេះបានជួយក្មេងជនជាតិព្នមានមោទនភាពចំពោះវប្បធមិរបស់ពួកគេ និងគោរពគ្នាទៅវិញទៅមកកាន់តែច្រើនក្នុងសហគមន៍ខ្មែរ និងព្នង។ កុមារីជនជាតិព្នងសរុប៦០នាក់ទទួលថវិកាពីម្ចាស់ជំនួយ Lotus Outreach អន្តរជាតិបានក្លាយជាគ្រូបឋមសិក្សា ហើយឥឡូវនេះពួកគេបង្រៀនក្មេងជនជាតិព្នងច្រើននាក់។ ក្នុងសាលារៀនរដ្ឋពួកគេអាចជួយសិស្សជនជាតិព្នងថ្នាក់ទី១ និងទី២ មានបញ្ហាប្រឈមនឹងភាសានិយាយ (ក្នុងថ្នាក់រៀនត្រូវបង្រៀនភាសាខ្មែរ)។ ដូច្នេះ មានគ្រូជនជាតិព្នងអាចជួយសិស្សានុសិស្សជនជាតិព្នងរៀនបានយ៉ាងងាយស្រួល។ បច្ចុប្បន្ននេះ គ្រូជនជាតិព្នង ២៨%ត្រូវបានជ្រើសរើសចេញពីសិស្សអាហារូបករណ៍កម្រិតអនុវិទ្យាល័យអន្តរាគមន៍ដោយគម្រោង។

**តម្លៃអាហារូបករណ៍ប្រចាំ**

| ការចំណាយ | ចំនួន | តម្លៃ | សរុប |
|---|---|---|---|
| កាតាប | ១ | ៨,៥ដុល្លាអាមេរិក | ៨,៥ដុល្លាអាមេរិក |
| ឯកសណ្ឋាន | ២សម្រាប់ | ៧ដុល្លាអាមេរិក | ១៤ដុល្លាអាមេរិក |
| ផ្គត់ផ្គង់ការអប់រំ | ១ | ៨ដុល្លាអាមេរិក | ៨ដុល្លាអាមេរិក |
| ស្បែកជើងផ្ទាត់ | ១គូ | ២ដុល្លាអាមេរិក | ២ដុល្លាអាមេរិក |
| ចំណាយប្រចាំខែ | ៩ខែ | ២០ដុល្លាអាមេរិក | ១៨០ដុល្លាអាមេរិក |
| សរុប | | | ២១២ដុល្លាអាមេរិក |
| **តម្លៃសិក្សា** | **៨ខែកន្លះ** | **៤០ដុល្លាអាមេរិក** | **៣៤០ដុល្លាអាមេរិក** |



**បច្ចុប្បន្នភាព:** អង្គការ ខេប បានផ្តល់ប្រព័ន្ធសូឡាថ្មី រួមមាន Server, Inverter, Thin Clients ចំនួន៥ និង Solar Panels ចំនួន៥ជូនដល់វិទ្យាល័យ អូរាំង ក្នុងខេត្តមណ្ឌលគិរី។ អង្គការ ខេប បានផ្តល់កុំព្យូទ័រដល់សាលាកាលពីប្រាំឆ្នាំមុន។ ដោយមានការខូចខាតកាលពីឆ្នាំទៅ អង្គការ ខេប បានបំពាក់ និងជួសជុលឱ្យមានដំណើរការឡើងវិញ។ សិស្សសប្បាយចិត្តបានសិក្សាជាមួយកុំព្យូទ័រផ្តើមចេញពីការរៀនវាយអត្ថបទ។ ឥឡូវនេះ សិស្សសិក្សាកុំព្យូទ័រពីរថ្ងៃក្នុងមួយសប្តាហ៍ (ថ្ងៃសុក្រ-សៅរ៍) រយៈពេលពី១ទៅ២ម៉ោង។ សិស្សនៅសាលារៀនចាប់អារម្មណ៍រៀនកុំព្យូទ័រ។

កម្មវិធីអាហារូបករណ៍សិស្សកម្រិតអនុវិទ្យាល័យអន្តរាគមន៍ដោយគម្រោង អប់រំជនជាតិព្នងចំណាយលើការអប់រំ ព្រមទាំងអាហារ និងការស្នាក់នៅ។ កុមារីជនជាតិព្នងក្រីក្រចំនួន៣១នាក់មកពីពីរអនុវិទ្យាល័យក្នុងខេត្តមណ្ឌលគិរី ទទួលបានកញ្ចប់អាហារូបករណ៍ក្នុងមួយឆ្នាំ រួមមាន៖ ឯកសណ្ឋានសិស្ស កាតាប សម្ភារៈសិក្សា ស្បែកជើង ថវិកាប្រចាំខែ និងរៀនគួរ។ សូមពិនិត្យមើលការចំណាយលើកម្មវិធីអាហារូបករណ៍ខាងក្រោម៖

សិស្សទាំងអស់បានប្រឡងជាប់ឆមាសទី២ ហើយពួកគេនឹងចូលរៀនថ្នាក់ទី៨ និងទី៩ នៅឆ្នាំក្រោយ។



ការចែកអាហារូបករណ៍វិទ្យាល័យដែលឧបត្ថម្ភដោយគម្រោង



គរុសិស្សអាហារូបករណ៍ថតរូបជាមួយម្ចាស់ជំនួយ



សិស្សសប្បាយរីករាយដោយបានចូលរួមក្នុងការបណ្តុះបណ្តាលអំពីទឹកស្អាត និងធ្វើអនាម័យ

# ករណីសិក្សាសិស្សអាហារូបករណ៍



**អែល សុនា** ជាសិស្សអាហារូបករណ៍ជនជាតិព្នងមានអាយុ១៥ឆ្នាំ បានកំពុងសិក្សានៅថ្នាក់ទី៨ នៅវិទ្យាល័យ អូរាំង ដែលមានចម្ងាយ៨គីឡូម៉ែត្រពីផ្ទះរបស់នាង។ ជារៀងរាល់ថ្ងៃ នាងដើរទៅសាលារៀនក្នុងចម្ងាយ៨គីឡូម៉ែត្រឡើងភ្នំ និងឆ្លងកាត់ព្រៃស្ងាត់ ប៉ុន្តែវាមានសុវត្ថិភាពសម្រាប់ធ្វើដំណើរទៅសាលារៀន។

សុភាពគឺជាសិស្សឆ្នើម និងខិតខំរៀនសូត្រខ្លាំងនៅក្នុងថ្នាក់។ នាងរៀនជាប់ចំណាត់ថ្នាក់លេខ២ក្នុងចំណោមសិស្ស៤០នាក់ក្នុងឆមាសទី១។ នាងពូកែខាងគណិតវិទ្យា និងអក្សរសាស្ត្រ។ នាងបានចូលរួមក្នុងសកម្មភាពស្រាវជ្រាវ និងក្នុងសកម្មភាពក្រុមប្រឹក្សាកុមារ។

សុភាពប្រាថ្នារៀនឱ្យបានចប់ដល់ថ្នាក់ទី១២ ហើយម្តាយរបស់នាងបាននិយាយថា គាត់សប្បាយចិត្តខ្លាំងណាស់ដោយបានឃើញកូនរបស់គាត់ជាសិស្សឆ្លាតវៃ និងជាកូនគួរឱ្យគោរព ហើយគាត់ចង់ជួយបំពេញក្តីសុបិន្តរបស់នាងក្លាយទៅជាគ្រូបង្រៀនម្នាក់នៅថ្ងៃអនាគត។

សុភាពចេញពីផ្ទះទៅសាលារៀនដោយថ្មើរជើង

**ប៊្លូ សាញ** គឺជាសិស្សជនជាតិព្នងរៀនថ្នាក់ទី៧ នៅវិទ្យាល័យ អូរាំង។ នាងរស់នៅក្នុងភូមិពូទ្រូ ឃុំសែនមនោរម្យ ស្រុកអូរាំង ខេត្តមណ្ឌលគិរី។ នាងគឺជាកូនពៅក្នុងចំណោមបងប្អូនបង្កើតទាំង៦នាក់។ បងប្អូនប្រុសស្រីនាងបានរៀបការ និងបានបែកផ្ទះពីគ្រួសារទៅរស់នៅជាមួយប្តីប្រពន្ធរបស់ពួកគេរៀងៗខ្លួន។ ប៊្លូ សាញ អាយុ១៤ឆ្នាំ កំពុងរស់នៅជាមួយឪពុកម្តាយរបស់នាងក្នុងខ្ទមតូចមួយមានជញ្ជាំងធ្វើពីឬស្សី។ ឪពុកនាងមានជម្ងឺពិបាកដកដង្ហើម និងគាត់មិនអាចធ្វើការនៅចំការបាន ហើយម្តាយនាងអាចធ្វើការងារបានតិចតួចនៅចំការព្រោះគាត់កាន់តែមានអាយុច្រើន។ បងប្អូនប្រុសស្រីរបស់នាងមិនបានរៀនដល់អនុវិទ្យាល័យពីព្រោះថាសាលារៀននៅឆ្ងាយពីភូមិ។

សាញ មិនដែលគិតថាបន្តការសិក្សាឡើយ ព្រោះសាលារៀនរបស់នាងឆ្ងាយដល់ទៅ១៨គីឡូម៉ែត្រ។ សំណាងល្អ នាងបានទទួលអាហារូបករណ៍ពីអង្គការ ខេប ក្រោមជំនួយ Lotus Outreach អន្តរជាតិ ដែល ផ្តល់ឱ្យសម្លៀកបំពាក់ ស្បែកជើង១គូ សម្ភារៈសិក្សា ថវិកាឧបត្ថម្ភប្រចាំខែ និងសំខាន់ជាងនេះទៀត អន្តេវាសិកដ្ឋានស្នាក់នៅរបស់នាងគឺនៅក្បែរសាលារៀនដែលមានផ្ទះបាយ បន្ទប់ទឹក និងអណ្តូងទឹកសម្រាប់សិស្សរស់នៅទីនោះបានប្រើប្រាស់។ ពេលវិស្សមកាលតូច នាងតែងតែទៅផ្ទះជួយម្តាយនាងធ្វើការនៅចំការនៅរដូវច្រូតកាត់។

ប្លូ សាញបានរៀបរាប់ថា *"នាងខ្ញុំរីករាយខ្លាំងណាស់ដែលបានក្លាយជាសិស្សអាហារូបករណ៍អង្គការ ខេប។ អាហារូបករណ៍នេះជួយខ្ញុំឲ្យមានឱកាសសិក្សាបានកាន់តែខ្ពស់ ហើយខ្ញុំកាន់តែមានទំនុកចិត្តនិយាយជាមួយមនុស្សផ្សេងគ្នា។ ពីមុននាងខ្ញុំជាមនុស្សខ្មាស់អៀន និងមិនចូលចិត្តនិយាយជាមួយមនុស្សដែលមិនស្គាល់មុខ។ ជាងនេះទៅទៀត នាងខ្ញុំដឹងថាមនុស្សជួយគ្នាទៅវិញទៅមក មិនសម្រាប់តែការរស់នៅ ប៉ុន្តែរៀនពីគ្នាផងដែរ។ នាងខ្ញុំរៀនពីមនុស្សផ្សេងគ្នានៅជុំវិញខ្ញុំ៕"*



# គម្រោង អាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ (CTSP)

គម្រោង CTSP ត្រូវបានគាំទ្រថវិកាដោយមូលនិធិ Merali និងប្រតិបត្តិដោយអង្គការ ខេប និងអង្គការមូលនិធិអាស៊ី បានឧបត្ថម្ភដល់សិស្សស្រីចំនួន១១៦នាក់ ដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យរយៈពេល៤ឆ្នាំ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៥។ សិស្សជំនាន់ទី១ចំនួន៦៥នាក់ បានបញ្ចប់ការសិក្សានៅក្នុងខែកញ្ញា ឆ្នាំ២០១៤ ហើយសិស្សជំនាន់ទី២ដែលមានចំនួន ៤៦នាក់ នឹងបញ្ចប់ការសិក្សារបស់ពួកគេនៅដើមឆ្នាំ២០១៦ ខណៈពេលដែលមានសិស្សចំនួន៥នាក់បានបោះបង់ចោលការសិក្សា។ ទោះជាយ៉ាងណា ក៏អត្រាសិស្សនៅគង់វង់មានចំនួនដល់ទៅ៩៦%ដែរ។ ជាងនេះទៅទៀត សិស្សចំនួន៩៤%ទទួលបានការងារធ្វើ។ នៅក្នុងអំឡុងពេលអនុវត្តកម្មវិធីនេះផងដែរ សិស្សបានមូលមតិគ្នាបង្កើតមូលនិធិសង្គមសម្រាប់រៃអង្គាសរកថវិកា។ ថវិកានេះនឹងប្រើប្រាស់សម្រាប់ជួយឧបត្ថម្ភក្មេងស្រីដែលជួបការលំបាកពីរ ឬបីនាក់ឱ្យទទួលបានឱកាសសិក្សាដល់កម្រិតឧត្តមសិក្សាបានល្អប្រសើរនៅឆ្នាំសិក្សា២០១៦។ ការផ្តល់ឱកាសសិក្សាថ្នាក់មហាវិទ្យាល័យដល់ក្មេងស្រី និងឱកាសជោគជ័យលើអាជីពការងារ គឺជាការជួយធ្វើឱ្យមានការផ្លាស់ប្តូរដ៏ល្អមួយនៅក្នុងសង្គមកម្ពុជា និងជួយកាត់បន្ថយផ្នត់គំនិតយែនឌ័រ។ មូលនិធិនេះបានបញ្ចប់នៅឆ្នាំ២០១៥ ក៏ប៉ុន្តែអង្គការ ខេប នៅតែសង្ឃឹមថាមូលនិធិនេះនឹងនៅតែបន្តជួយសិស្សសម្រាប់ឆ្នាំសិក្សា២០១៦ខាងមុខនេះ។

## សកម្មភាពសំខាន់ៗ

- សិក្សារយៈពេល៤ឆ្នាំនៅសាកលវិទ្យាល័យ
- ការរៀបចំប្រជុំប្រចាំខែ
- ការសិក្សាតាមក្រុមមុខវិជ្ជា
- សិក្ខាសាលាស្តីពីការអភិវឌ្ឍអាជីពគឺផ្តោតទៅលើៈ
  - → ភាពជាអ្នកដឹកនាំ ការលើកទឹកចិត្ត ជំនាញទំនាក់ទំនង
  - → ការស្វែងយល់ការងារស្ម័គ្រចិត្ត
  - → ទស្សនកិច្ចសិក្សា
  - → ការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មាន
  - → ជំនាញភាសាអង់គ្លេស។

## សញ្ញាប័ត្រទទួលបាន

និស្សិតអាហារូបករណ៍គម្រោង CTSP បានជ្រើសរើសមុខជំនាញខាងក្រោមដែលមានបង្រៀននៅសាកលវិទ្យាល័យ វេស្ទើន ដូចជាៈ

- ហិរញ្ញវត្ថុ និងធនាគារ
- គណនេយ្យ
- ការគ្រប់គ្រង

## លទ្ធផលគម្រោង

ចំនួន៩៤%នៃសិស្ស១១១នាក់បានទទួលការងារធ្វើពេញម៉ោង ដែល៨% បានការងារធ្វើក្រៅម៉ោង។






ម្ចាស់ជំនួយមកពីមូលនិធិ Merali លោកស្រី យ៉ាស្មីន បានមកទស្សនកិច្ចនិស្សិតអាហារូបករណ៍នៅការិយាល័យអង្គការ ខេប នៅខែកញ្ញា ឆ្នាំ២០១៥។ លោកស្រីមានសេចក្តីរំភើបដោយបានជួបជាមួយនិស្សិតអាហារូបករណ៍ និងរៀនបានពីលទ្ធផលនិស្សិតអាហារូបករណ៍។



ប៉ូ ស៊ីណេង នៅ ការិយាល័យធ្វើការថ្មីរបស់នាង

**ប៉ូ ស៊ីណេង** ជានិស្សិតជំនាន់ទី២ ផ្នែកគណនេយ្យ ហើយនាងរស់នៅជាមួយឪពុកម្តាយរបស់នាងនៅក្នុងអាគារដែលចាស់ទ្រុឌទ្រោមមួយមានគ្រួសារជាច្រើនរស់នៅទីនោះនៅក្នុងស្រុកកំពង់ចាម។ នាងបានបោះបង់ក្តីស្រមៃរបស់ខ្លួនចង់ក្លាយទៅជាឱសថការីពីព្រោះឪពុកម្តាយរបស់នាងមិនអាចជួយនាងឲ្យទៅរៀននៅភ្នំពេញបានទេហើយការរៀនមុខវិជ្ជាវិទ្យាសាស្ត្រគឺត្រូវចំណាយខ្ពស់ណាស់។ ជាសំណាងល្អ នាងបានទទួលអាហារូបករណ៍ពីអង្គការ ខេប ដែលបានផ្តល់ឱកាសដល់នាងបានបន្តការសិក្សានៅសាកលវិទ្យាល័យនៅក្នុងខេត្តកំពង់ចាមដែលនៅជិតផ្ទះរបស់នាង។ បច្ចុប្បន្ននេះ នាងកំពុងរៀននៅឆ្នាំទី៤ ហើយនាងក៏កំពុងធ្វើការងារជាគណនេយ្យករនៅស្ថាប័នមីក្រូហិរញ្ញវត្ថុហត្ថាកសិករនៅស្រុកស្ទឹងត្រង់ ដែលនាងអាចរកប្រាក់ចំណូលដើម្បីជួយគាំទ្រការសិក្សាប្អូនប្រុសដែលកំពុងរៀនថ្នាក់ទី១២។ ស៊ីណេង បានរៀបរាប់ថា «ការងារនៅទីនោះនាងខ្ញុំទទួលខុសត្រូវលើផ្នែកសន្សំ ផ្តល់ប្រាក់កម្ចីកត់ត្រាលើប្រតិបត្តិការផ្សេងៗ ត្រួតពិនិត្យរាល់ការងារប្រចាំថ្ងៃរបស់បេឡាករ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុផ្ញើទៅការិយាល័យកណ្តាល។» ស៊ីណេង មានភាពរឹងមាំក្នុងការនិយាយជាសាធារណៈពីព្រោះនាងធ្លាប់បានស្ម័គ្រចិត្តចូលរួមសកម្មភាពជាច្រើន ដូចជា ធ្វើជាអ្នកដឹកនាំក្រុមកិច្ចការសាលាដឹកនាំការប្រជុំប្រចាំខែ ដឹកនាំក្លឹបសិក្សាគណនី។ លើសពីនេះទៅទៀតនៅពេលដែលនាងបានចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាផ្សេងៗ នាងតែងតែព្យាយាមចែករំលែកអ្វីដែលនាងធ្លាប់បានដឹង និងសួរសំនួរជាច្រើនដើម្បីពង្រឹងទំនុកចិត្ត និងចំណេះដឹងរបស់ខ្លួន។ នាងបានទទួលការសរសើរជាច្រើនពីសំណាក់លោកសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ ព្រមទាំងប្រធាននៅកន្លែងការងាររបស់នាងផងដែរ។ លោក ចន្ទ សុភា ប្រធានសាខាស្ថាប័នមីក្រូហិរញ្ញវត្ថុហត្ថាកសិករបានបង្ហាញពីចំណាប់អារម្មណ៍របស់គាត់ថា «ស៊ីណេងជាបុគ្គលិកដែលប្រឹងប្រែងធ្វើការងារណាស់ ហើយឆាប់យល់ការងារទៀត។ ឥឡូវរាល់ការងាររបស់នាង នាងអាចធ្វើបានដោយខ្លួនឯង ហើយនាងដើរតួនាទីសំខាន់ក្នុងការបង្រៀនបុគ្គលិកថ្មីៗថែមទៀតផង។» គាត់បានបន្ថែមទៀតថា «ខ្ញុំនឹងផ្តល់អនុសាសន៍ឲ្យនាងធ្វើជាប្រធានគណនេយ្យករនៅពេលដែលសាខាថ្មីបានបង្កើតឡើងនៅឆ្នាំ២០១៦ខាងមុខនេះ។»

# គម្រោង ខ្ញុំកំពុងរៀន!

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការ Save the Children និងទីភ្នាក់ងារណ័រវេ ដើម្បីសហប្រតិបត្តិការអភិវឌ្ឍ(NORAD) |
| អ្នកទទួលផលផ្ទាល់ | ៤.៥៤៥ នាក់ (ស្រី ២.២៣៦ នាក់) |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៤ | ១៣៤.០០០ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | គ្មាន (គម្រោងស្រាវជ្រាវ) |
| ខេត្តគ្របដណ្តប់ | ៥ខេត្ត (កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ព្រៃវែង និងកំពង់ឆ្នាំង) |
| ស្រុកគ្របដណ្តប់ | ១៦ |
| បឋមសិក្សាគោលដៅ | ១៥ សាលាអនុវត្ត និង ១៥ សាលាប្រៀបធៀប |
| វិទ្យាល័យគោលដៅ | គ្មាន |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ខែមីនា ឆ្នាំ២០១៣ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ខែធ្នូ ឆ្នាំ២០១៧ |

## បច្ចុប្បន្នភាពគម្រោង

គម្រោងខ្ញុំកំពុងរៀន (ILP)! បានបញ្ចប់សកម្មភាពឆ្នាំទី២របស់ខ្លួន និងមានការផ្លាស់ប្តូរមួយចំនួនទៅលើរចនាសម្ព័ន្ធបុគ្គលិក។ ចំណុចសំខាន់គឺការសម្រេចចិត្តបញ្ចូលផ្នែកប្រមូល «ទិន្នន័យគុណភាព» ដើម្បីបំពេញបន្ថែមលើសកម្មភាពប្រមូលទិន្នន័យដែលផ្តោតសំខាន់លើទិន្នន័យបរិមាណ។ ការផ្លាស់ប្តូរនេះបានបញ្ចប់នៅពាក់កណ្តាលឆ្នាំ រួមជាមួយវត្តមានទីប្រឹក្សាថ្មីដែលមានឯកទេសខ្ពស់ក្នុងផ្នែកនេះ។ ការផ្តោតលើការប្រមូលទិន្នន័យគុណភាពមានសារៈសំខាន់ណាស់ ដើម្បីវាយតម្លៃសមត្ថភាពប្រើប្រាស់បំណិនជីវិតរបស់សិស្សដែលជាផ្នែកកម្មវិធីសិក្សាថ្នាក់ជាតិ។

គម្រោងខ្ញុំកំពុងរៀនក៏បានធ្វើជាម្ចាស់ផ្ទះនៃការប្រជុំបីប្រទេសដើម្បីពិនិត្យមើលលទ្ធផលស្រាវជ្រាវដំបូង ក៏ដូចជាវិធីសាស្រ្តស្រាវជ្រាវ និងការវិវត្តន៍រហូតមកដល់បច្ចុប្បន្ន។ ក្នុងការប្រជុំនេះ តំណាងមកពីប្រទេស អ៊ូហ្កាន់ដា និងហ្ស៊ីមបាបវ៉េ បានចូលរួមជាមួយក្រុមកម្ពុជាដើម្បីពិភាក្សាអំពីការស្រាវជ្រាវ។ ការប្រជុំរួមគ្នាបានធ្វើឡើងនៅក្នុងក្រុងកំពង់ចាមដែលជាឱកាសដ៏ល្អសម្រាប់បង្ហាញពីការវិវត្តន៍។

នៅចុងឆ្នាំ អង្គការ ខេប បានធ្វើការវាយតម្លៃប្រចាំឆ្នាំ និងផ្តល់ជាអនុសាសន៍ក្នុងការអនុវត្តកម្មវិធីរយៈពេល៣ឆ្នាំ។ របាយការណ៍បានរៀបចំជាពង្រាងនៅចុងឆ្នាំ និងបានប្រគល់ដល់សាកលវិទ្យាល័យ អូស្លូ នៅដើមឆ្នាំ២០១៦។

## សនិទានភាពនៃគម្រោង

គម្រោងខ្ញុំកំពុងរៀន (ILP)! ជាគម្រោងសាកល្បងដែលបានចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ២០១៣ និងបានបញ្ចប់សកម្មភាពរបស់ខ្លួនរយៈពេល២ឆ្នាំ ក្នុងឆ្នាំ២០១៥។ គម្រោងនេះគឺជាឧទាហរណ៍នៃនិន្នាការថ្មីក្នុងការអភិវឌ្ឍដែលផ្តោតលើកម្មវិធីផ្អែកលើភស្តុតាង និងស្រដៀងគ្នានឹងគោលបំណងកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) របស់អង្គការ ខេប ទោះបីជាបានផ្តោតលើវិទ្យាល័យ ចំណែកឯគម្រោង ខ្ញុំកំពុងរៀន ផ្តោតលើបឋមសិក្សាក៏ដោយ។ គម្រោងខ្ញុំកំពុងរៀនមានផ្នែកច្រើនផ្សេងៗគ្នា រួមទាំងផ្នែកស្រាវជ្រាវ ផ្នែកតាមដាន ផ្នែកវាយតម្លៃ និងផ្នែកអនុវត្តកម្មវិធី។ អង្គការ Save the Children ទទួលខុសត្រូវលើការអនុវត្តកម្មវិធីនៅក្នុងសាលាអនុវត្តចំនួន១៥ ក្នុងខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ និងកំពង់ឆ្នាំង ចំណែកអង្គការ ខេប ទទួលខុសត្រូវលើការតាមដាន និងវាយតម្លៃ ក៏ដូចជាបង្កើតផែនការស្រាវជ្រាវដែលធ្វើសុពលភាពឥទ្ធិពលប្រែប្រួលអន្តរាគមន៍នៅក្នុងសាលាអនុវត្តធៀបទៅនឹងសាលាប្រៀបធៀប។

គោលការណ៍របស់គម្រោងគឺត្រូវផ្តល់ភស្តុតាងជាក់ស្តែងដែលថា វិធីសាស្រ្តពហុចម្រុះវិស័យ ដែលអនុវត្តក្នុងសាលាពិតជាអាចធ្វើឱ្យការសិក្សារបស់សិស្សប្រសើរឡើងបាន។ ទោះបីគោលវិធីសាស្រ្តពហុចម្រុះវិស័យ ដូចជា កម្មវិធីកុមារមេត្រីរបស់អង្គការ ខេប ដែលមាន៦ផ្នែក ត្រូវបានឱ្យអនុវត្តយ៉ាងទូលំទូលាយទាំងក្នុងពិភពលោក ក៏ដូចជាក្នុងប្រទេសកម្ពុជា វាកម្រនឹងមានឧទាហរណ៍សុពលភាពជាក់ស្តែងណាស់។ ដូច្នេះហើយ គម្រោង ខ្ញុំកំពុងរៀន ខិតខំស្វែងរកការគាំទ្រថ្មីៗដល់សាលារៀនដែលមានគ្រោងការអនុវត្តមួយនឹងបង្ហាញភស្តុតាងអំពីប្រសិទ្ធភាពអន្តរាគមន៍នេះ។ សកម្មភាពត្រូវរៀបចំជា «បរិស្ថានសិក្សាប្រកបដោយគុណភាព» ដែលមាន៤ផ្នែកធំៗ៖

- ការការពារផ្លូវអារម្មណ៍ និងផ្លូវចិត្ត
- ការការពាររាងកាយ
- សកម្មភាពរៀនបែបសកម្ម និង
- ការចូលរួមពីសហគមន៍។

## មេរៀនទទួលបានពីគម្រោង

គម្រោងខ្ញុំកំពុងរៀន(ILP)! មានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងការបង្កើតឧបករណ៍បំណិនជីវិតថ្មី។ ដំណើរការបង្កើតមានច្រើនជំហាន ដោយចាប់ផ្តើមពីការវិភាគខ្លឹមសារសៀវភៅសិក្សាដល់ការធ្វើតេស្តសាកល្បងដើម្បីធ្វើសុពលភាពពិន្ទុដែលអាចជឿជាក់បាន។ ការសម្រេចបានពិន្ទុនៃភាពជឿជាក់ជាក់គឺជាការលំបាកមួយដែលតម្រូវឱ្យមានការកែប្រែឧបករណ៍ជាច្រើនដង។



គ្រូប្រមូលទិន្នន័យដោយសម្ភាសន៍ដើម្បីវាយតម្លៃប្រសិទ្ធភាពគម្រោង

# ២២ គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀន តាមរយៈការគាំទ្រពីសហគមន៍ (REACH/រីក) ១ និង២

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការវីវើល (We World) |
| ដៃគូ (បានធ្វើកិច្ចព្រមព្រៀង) | អង្គការវឌ្ឍនភាព (WP); Ciai |
| អ្នកទទួលផលផ្ទាល់ | កុមារ ១៧.៣៨៨នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ២០១៥ | ២៩៥.៨៩៤,៨ ដុល្លាអាមេរិក |
| អ្នកទទួលផលផ្ទាល់ក្នុងម្នាក់ | ១៧,០២ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ៤ ខេត្ត (ស្វាយរៀង ព្រៃវែង កំពង់ឆ្នាំង និងពោធិសាត់) |
| ចំនួនស្រុកគ្របដណ្តប់ | ៨ ស្រុក |
| សាលាគោលដៅ | ៣៦ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ១ កក្កដា ២០១២ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ មិថុនា ២០១៨ |

## បច្ចុប្បន្នភាពគម្រោង

គម្រោងរីកដំណាក់កាលទី១ដែលមានរយៈពេល៣ឆ្នាំបានបញ្ចប់នៅក្នុងខែមិថុនា ឆ្នាំ២០១៥។តាមរយៈការវាយតម្លៃការអនុវត្តគម្រោង៣ឆ្នាំពីស្ថាប័នឯករាជផ្នែកខាងក្រៅបានបង្ហាញថា គម្រោងទទួលបានលទ្ធផលជាវិជ្ជមានគួរឱ្យកត់សំគាល់ដោយបានធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំ និងជាពិសេស ការអប់រំផ្នែកបំណិនជីវិត។ ដោយមើលឃើញពីភាពជោគជ័យ និងការអនុវត្តល្អរបស់គម្រោងដែលប្រតិបត្តិដោយអង្គការ ខេប អង្គការវីវើល បានស្នើសុំអង្គការ ខេប ឱ្យរៀបចំសំណើរសុំគម្រោងថ្មីដើម្បីអនុវត្តនៅក្នុងសាលាគោលដៅក្នុងគម្រោងរីកដំណាក់កាលទី ១ នៅខេត្តស្វាយរៀង និងព្រៃវែង និងថែមទាំងពង្រីកកម្មវិធីដែលមានរយៈពេល៣ឆ្នាំទៀតក្នុងសាលាមួយចំនួននៅក្នុងខេត្ត២ទៀត គឺខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់។ ការស្រាវជ្រាវប្រមូលទិន្នន័យ បានធ្វើឡើងនៅពាក់កណ្តាលឆ្នាំ២០១៥ ដើម្បីជ្រើសរើសបន្ថែមសាលាថ្មីចំនួន១១ទៀតសម្រាប់អនុវត្តក្នុងគម្រោងរីក ២។ គម្រោងថ្មីដែលមានរយៈពេល៣ឆ្នាំបានចាប់ផ្តើមអនុវត្តនៅក្នុងខែកក្កដា ឆ្នាំ២០១៥ និងបញ្ចប់នៅខែមិថុនា ឆ្នាំ២០១៨។ គម្រោងរីក ២ មិនដូចគម្រោងរីក ១ ទេ គម្រោងថ្មីនេះនឹងបញ្ចូលការបង្កើតគោលនយោបាយ និងឯកសារជួយក្រសួងអប់រំលើការធ្វើតេស្តអំណានថ្នាក់ដំបូងតាមអេឡិចត្រូនិចដើម្បីធានានូវសុពលភាព និងភាពអាចជឿជាក់បាននៃទិន្នន័យ និងការបង្កើតស្តង់ដាគណិតវិទ្យា ដែលជាមូលដ្ឋានមួយក្នុងការស្នើសុំបង្កើតសៀវភៅស្តង់ដាថ្នាក់ទី១ និងទី២ថ្មី។

## សកម្មភាពសំខាន់ៗ

បច្ចុប្បន្ននេះ អង្គការ ខេប កំពុងដាក់សំណើដើម្បីអនុវត្តគម្រោងថ្មី គឺរីក ២ នៅក្នុងសាលាបឋមសិក្សាចំនួន២៥ និងសាលាមត្តេយ្យ ៥ ក្នុងខេត្តស្វាយរៀង និងព្រៃវែងដោយបង្កើនការបង្កើតថ្មីលើវិស័យអប់រំ ជាពិសេស ការពង្រឹងអំណានថ្នាក់ដំបូង និងគណិតវិទ្យា និងពង្រីកសាលាបឋមសិក្សាចំនួន១១ និងមត្តេយ្យចំនួន១០ នៅក្នុងខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់ដែលជាចំណុចកណ្តាលប្រទេសកម្ពុជា។

### សកម្មភាពសំខាន់ៗរបស់គម្រោងរីក ២:

- ពង្រឹងយន្តការចុះឈ្មោះចូលរៀនតាមអាយុបានត្រឹមត្រូវនៅតាមសាលាដែលមានបញ្ហាកុមារចុះឈ្មោះចូលរៀនមិនទាន់អស់ក្នុងខេត្តគោលដៅទាំង៤។
- សាលារៀនភាគច្រើននឹងត្រូវបានពង្រឹងគុណភាពបង្រៀន និងរៀនរួមទាំងចំណេះដឹងផ្នែកបច្ចេកទេសដែលជះឥទ្ធិពលជាវិជ្ជមានដល់កុមារដែលមានតម្រូវការពិសេស។
- មាតាបិតា និងសហគមន៍ត្រូវបានជូនដំណឹង និងចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សាកូនរបស់ពួកគេតាមសាលារៀនក្នុងខេត្តគោលដៅទាំង៤។
- ការពង្រឹងអភិបាលកិច្ចល្អដោយផ្តោតទៅលើតម្លាភាព ការគ្រប់គ្រងថវិកា គណនេយ្យភាព និងការគ្រប់គ្រងទិន្នន័យឱ្យមានភាពប្រសើរឡើងនៅតាមកម្រិតសាលារៀន កម្រិតការិយាល័យ និងកម្រិតមន្ទីរអប់រំ។
- ការបង្កើតគោលនយោបាយរបស់ក្រសួងអប់រំនឹងត្រូវបានគាំទ្រដោយឯកសារស្រាវជ្រាវ និងការអនុវត្តល្អរបស់គម្រោង។

គោលបំណងរួមគឺរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៤-២០១៨ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំជាសកលសម្រាប់ទាំងអស់គ្នានៅបឋមសិក្សាដោយផ្តោតទៅលើការអនុវត្តសកម្មភាព និងការអភិវឌ្ឍគោលនយោបាយ ។

**គោលបំណងជាក់លាក់** គឺដើម្បីលើកកម្ពស់លទ្ធផលការសិក្សារបស់កុមារលើមុខវិជ្ជា ដូចជា៖ គណិត ភាសាខ្មែរ(អំណាន) និងបំណិនជីវិតដោយប្រើវិធីសាស្ត្រផ្សេងៗជាច្រើន ដើម្បីលើកកម្ពស់ការសិក្សាឱ្យបានប្រសើរឡើងទាំងនៅក្នុងសាលារៀន នៅផ្ទះ និងនៅតាមសាលាគោលដៅទាំងអស់ក្នុងខេត្តទាំង៤។

គម្រោង REACH II នឹងអនុវត្តដោយបញ្ចូលនូវវិធីសាស្ត្រជាច្រើនដោយផ្តោតទៅលើការប្រមូលកុមារ ការពង្រីកគុណភាពអប់រំ សុខភាព និងសុវត្ថិភាព ការចូលរួមរបស់សហគមន៍ និងអភិបាលកិច្ចល្អ។ គម្រោងនឹងផ្តោតខ្លាំងទៅលើការពង្រឹងអំណាន និងគណិតវិទ្យាដោយប្រើការបង្កើតថ្មីដែលអង្គការ ខេប បានបង្កើតឡើង ដូចជា សម្ភារៈពង្រឹងអំណាន ការរៀនតាមអេឡិចត្រូនិច (M-learning) និងការសិក្សាស្រាវជ្រាវក្រៅថ្នាក់។ គម្រោងនឹងបន្តកម្មវិធីពង្រឹងអំណានតាមអេឡិចត្រូនិចដល់សាលាដែលមានអភិបាលកិច្ចល្អកម្រិតខ្ពស់ ដើម្បីរួមចំណែកជាមួយរដ្ឋាភិបាលកម្ពុជាធ្វើសមាហរណកម្ម អាស៊ានខាងមុខ ដើម្បីបំពេញតម្រូវការការងារនាសតវត្សទី២១។ គម្រោងក៏នឹងបន្តអនុវត្តកម្មវិធីធ្វើតេស្តយ៉ាងសុក្រិត និងត្រឹមត្រូវ (ឧ. តេស្ត EGRA) ដើម្បីប្រៀបធៀបរវាងលទ្ធផល និងការចំណាយថវិកា។




សិក្ខាសាលាផ្សព្វផ្សាយលទ្ធផលគម្រោងរីក ១ និងផ្សព្វផ្សាយគម្រោងថ្មី រីក ២ ក្នុងខេត្តស្វាយរៀង។



សិស្សធ្វើការងារជាក្រុមដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាដែលបានជួបពាក់ព័ន្ធនឹងការអប់រំ និងរៀបចំផែនការដើម្បីដោះស្រាយបញ្ហាទាំងនោះ។

# “ សហគមន៍រឹងមាំកសាងបាននូវសាលារៀនដ៏រឹងមាំ! ”

## ការជះឥទ្ធិពលគម្រោងរីក ១ ( REACH I)

គម្រោងរីក (REACH) បានបង្កើតនូវឱកាសជាច្រើនដល់កុមារគ្រប់ដំណាក់កាលនៃការអប់រំ។ ការវាយតម្លៃគម្រោងពីផ្នែកខាងក្រៅដែលបានធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ ២០១៥ បានបង្ហាញថា គម្រោងបានបង្កើនចំណេះដឹង និងផ្លាស់ប្តូរឥរិយាបថរបស់គ្រូបង្រៀន នាយក និងបណ្ណារក្សនៅតាមសាលាគោលដៅដើម្បីឱ្យពួកគេមានភាពជឿជាក់ និងអាចបង្ហាញនូវជំនាញវិជ្ជាជីវៈរបស់ពួកគេដល់សិស្សានុសិស្ស។

វឌ្ឍភាពគួរឱ្យកត់សម្គាល់នៅក្នុងការប្រមូលកុមារចូលរៀន និងការកាត់បន្ថយអត្រាបោះបង់ការសិក្សាបានផ្តល់នូវក្តីសង្ឃឹមសម្រាប់និរន្តរភាពនាពេលអនាគត។ នៅអំឡុងពេលវាយតម្លៃគម្រោង គ្រប់អ្នកពាក់ព័ន្ធទាំងអស់បានសម្តែងចេញនូវការគាំទ្រពេញទំហឹងចំពោះគម្រោង និងឥរិយាបថជាវិជ្ជមានចំពោះការអប់រំ។ សកម្មភាពនេះនឹងអាចធ្វើឱ្យមានការចូលរួមច្រើននៅក្នុងសហគមន៍ដើម្បីរក្សានូវបរិយាកាសដ៏ល្អប្រសើរសម្រាប់ការចូលរៀនរបស់កុមារ និងគុណភាពអប់រំ។

ការតាំងចិត្ត និងការចូលរួមយ៉ាងខ្លាំងក្លារបស់គណៈកម្មការទ្រទ្រង់សាលា ក្រុមប្រឹក្សាឃុំ នាយកសាលា លោកគ្រូ អ្នកគ្រូ ក៏ដូចជាមាតាបិតា និងអាណាព្យាបាលសិស្ស ឆ្លុះបញ្ចាំងពីការកើនឡើងនៃការគាំទ្រផ្នែកថវិការបស់សហគមន៍នៅក្នុងផែនការអភិវឌ្ឍសាលារៀន។ នាពេលថ្មីៗនេះ គណៈកម្មការទ្រទ្រង់សាលាអាចរកថវិកាជិត ១000ដុល្លារអាមេរិក ជារៀងរាល់ឆ្នាំដើម្បីជួយអភិវឌ្ឍសាលារៀន។ ជាគំរូមួយគួរឱ្យកត់សម្គាល់ ដែលបានបង្ហាញដោយសាលាបឋមសិក្សា តាន្វ ជាកន្លែងដែលសហគមន៍រកបានថវិកាសម្រាប់បំពាក់ផ្ទាំងសូឡាឱ្យសាលារៀនដើម្បីប្រើប្រាស់ថេប្លេត (tablet) ក្នុងការជួយពង្រឹងអំណានដល់សិស្សនៅក្នុងបណ្ណាល័យ។ នៅក្នុងសាលាគោលដៅមួយចំនួនទៀត ក្រុមប្រឹក្សាកុមារបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគៀងគរធនធានពីមិត្តភក្តិរបស់ពួកគេតាមរយៈការបរិចាគវិភាគទានក្នុងប្រអប់មូលនិធិកុមារ ដែលបានត្រួតពិនិត្យរាល់សប្តាហ៍។ គ្រប់សាលារៀនទាំងអស់ដែលបានចូលរួមកម្មវិធីទស្សនកិច្ចសិក្សាទៅខេត្តដទៃ ទទួលបានបទពិសោធន៍ល្អៗជាច្រើន និងបានយកមកអនុវត្តភ្លាមៗដើម្បីកែលម្អសាលារៀន និងសហគមន៍របស់ពួកគេនៅពេលត្រឡប់មកវិញ។

## រូបភាពសកម្មភាពខ្លីៗ



សិស្សរីករាយលេងសួនកុមារដែលបានផ្តល់ឱ្យដោយគម្រោង REACH



សិស្សថ្នាក់ទី១ និងទី២ ប្រើប្រាស់កម្មវិធីអានខ្មែរតាមថាប់ប្លេត (Tablet) ដែលបង្កើតឡើងដោយអង្គការ ខេប ដើម្បីពង្រឹងអំណាន។

## ករណីសិក្សា

ប្រសិនបើយើងកសាងទំនុកចិត្តរបស់សហគមន៍បាន ពួកគេនឹងមកសាលា តាន្វ។ សាលាបឋមសិក្សា តាន្វ មានទីតាំងស្ថិតនៅភូមិតាន្វ ឃុំចំបក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ នៅឆ្នាំ២០១២ សាលារៀននេះបានចូលក្នុងគម្រោង REACH។ តាមរយៈវគ្គបណ្តុះបណ្តាលនានា និងទស្សនកិច្ចសិក្សា លោក ទូច វុទ្ធ អាយុ៧៨ឆ្នាំ ដែលជាសមាជិកគណៈកម្មការទ្រទ្រង់សាលា បានចាប់ផ្តើមគិតថា តើសហគមន៍អាចជួយពង្រឹងគុណភាពអប់រំបានដោយរបៀបណា? ជាលទ្ធផល គាត់បានចាប់ផ្តើមចូលរួមយ៉ាងសកម្មស្ទើរតែគ្រប់សកម្មភាព និងព្រឹត្តិការណ៍សំខាន់ៗរបស់សាលារៀន។ នៅក្នុងវិធីនេះ គាត់បានសហការជាមួយគម្រោង REACH ដើម្បីជួយកុមារងាយរងគ្រោះជាច្រើន។ គាត់បាននិយាយថា ចាប់តាំងពីទទួលការគាំទ្រពីគម្រោងមក អត្រាបោះបង់បានថយចុះ និងអត្រាឡើងថ្នាក់បានកើនឡើង។ ជាមួយគ្នានេះដែរ បរិស្ថានរូបវន្តជាច្រើនបានកែលម្អប្រសើរឡើងដូចជារបងសាលា សួនច្បារ សួនកុមារ បណ្ណាល័យស្អាត ការកែលម្អបន្ទប់រៀន និងកន្លែងដាក់កង់ធំទូលាយ។

លោក ទូច វុទ្ធ មានការប្តេជ្ញាចិត្តខ្ពស់។ គាត់មិនត្រឹមតែលះបង់ពេលវេលា និងកំលាំងកាយចិត្តប៉ុណ្ណោះទេ ប៉ុន្តែ គាត់ថែមទាំងបរិច្ចាគថវិកា និងសម្ភារៈផ្ទាល់ខ្លួនជួយសាលារៀនថែមទៀត។ ក្នុងនោះដែរ តាំងពីឆ្នាំ២០១២ ដល់២០១៥ គាត់រកថវិកាបានច្រើនជាង ៤,៧00ដុល្លារអាមេរិក សម្រាប់កែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន រួមទាំងការបំពាក់ផ្ទាំងសូឡាសម្រាប់ដំណើរការកម្មវិធីពង្រឹងអំណានតាមថេប្លេត (tablet) ដែលគម្រោង REACH បានផ្តល់ឱ្យ។ ថាប់ប្លេតទាំងនោះបានដំឡើងកម្មវិធីសូសវែរដែលហៅថា អានខ្មែរ ដើម្បីជួយពង្រឹងអំណានរបស់កុមារ។ ភាពជោគជ័យនៃការស្វែងរកថវិកាសម្រាប់អភិវឌ្ឍសាលារៀន ក្នុងនោះមួយផ្នែកកើតចេញពីការផ្តួចផ្តើមគំនិត និងយុទ្ធសាស្ត្ររបស់គម្រោងផងដែរ។ គាត់បានបន្ថែមទៀតថាអ្វីដែលសំខាន់បំផុតក្នុងការរកថវិកា និងការចូលរួម គឺការកសាងទំនុកចិត្តរបស់សហគមន៍។ ប្រជាជនជាច្រើនពិតជាឱ្យតម្លៃខ្ពស់លើការខិតខំ និងការតាំងចិត្តរបស់លោកពូ វុទ្ធ ខ្លាំងណាស់។

នៅថ្ងៃអនាគត លោក ទូច វុទ្ធ ចង់ឃើញសាលារៀនមានអាគារ២ជាន់ដោយបញ្ជាក់ថាសព្វថ្ងៃនេះចំនួនសិស្សមានការកើនឡើង ហើយលោកមិនចង់ឃើញថ្នាក់រៀនមួយដែលមានសិស្សច្រើនពេកនោះទេ វាបណ្តាលឱ្យសិស្សគ្មានអារម្មណ៍ល្អ និងធ្វើឱ្យការបង្រៀន និងរៀនគ្មានប្រសិទ្ធភាព។ ប៉ុន្តែ គាត់បានមានប្រសាសន៍ថាដើម្បីឱ្យសុបិន្តនេះក្លាយជាការពិត យើងត្រូវធ្វើកិច្ចសហការជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋានដើម្បីកសាងសេចក្តីទុកចិត្តគ្នាទៅវិញទៅមក។ គាត់សង្ឃឹមថា អង្គការ ខេប នឹងបន្តគាំទ្រផ្នែកបច្ចេកទេសដល់គ្រូបង្រៀនបន្តទៀត ចំណែកគាត់ និងសមាជិកគណៈកម្មការទ្រទ្រង់សាលាផ្សេងទៀត និងបង្កើនទំនាក់ទំនងល្អរវាងសហគមន៍ និងសាលារៀន។ ជាចុងបញ្ចប់ លោក វុទ្ធ បាននិយាយថា ប្រសិនបើកុមារទទួលបានការអប់រំល្អ ពួកគេនឹងទទួលបានអនាគតភ្លឺស្វាង៕



កុមារកំពុងរៀនអានតាមថាប់ប្លេតក្នុងបណ្ណាល័យ



លោក វុទ្ធ ឈរនៅកណ្តាល និងសមាជិក SSC នៅខាងស្តាំ

# គម្រោង ងាយស្រួលរៀន (E2L)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | ឆាលហ្វាន់ កម្ពុជា |
| អ្នកទទួលផលផ្ទាល់ | ៨.១៥៥ ដុល្លារអាមេរិក |
| បដិភាគទទួលក្នុងឆ្នាំ ២០១៥ | ៣៩២.១៨០ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផល ក្នុងម្នាក់ | ៤២ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | ស្វាយរៀង |
| ចំនួនស្រុកគ្របដណ្តប់ | ២ ស្រុក (ស្វាយជ្រុំ និងរមាសហែក) |
| បឋមសិក្សាគោលដៅ | ២១ សាលា |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ១ កក្កដា ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ៣០ មិថុនា ២០១៦ |

## បច្ចុប្បន្នភាពគម្រោង

គម្រោង ងាយស្រួលរៀន (E2L) គឺជាគម្រោងមួយក្នុងចំណោមគម្រោងថ្មីបំផុតរបស់អង្គការ ខេប។ គម្រោងនេះមានកិច្ចសហការជាមួយអង្គការឆាលហ្វានដែលបានបញ្ចូលទៅជាម្ចាស់ជំនួយបែបយុទ្ធសាស្រ្តបំផុតរបស់អង្គការ ខេប។ អង្គការឆាលហ្វានធ្វើការផ្តែកយុទ្ធសាស្រ្តអភិវឌ្ឍដ៏ជិតស្និទជាមួយដៃគូនៅក្នុងស្រុក ក្នុងនោះក៏មានអង្គការ ខេប ដើម្បីជួយបង្កើត និងអនុវត្តគម្រោងអប់រំ ហើយអង្គការ ខេប បានធ្វើការងារយ៉ាងជិតស្និទក្នុងការរៀបចំគម្រោង E2L ឡើងជាមួយដៃគូអង្គការឆាលហ្វានដែលដឹកនាំធ្វើសមាហរណកម្មរួម។

ជារួម លទ្ធផលគម្រោង E2L មួយចំនួនត្រូវបានពន្យារ ពេលចាប់ផ្តើមគម្រោងដំបូងដោយសារការចាប់ផ្តើមបានកើតឡើងនៅពាក់កណ្តាលឆ្នាំសិក្សា ធ្វើឱ្យមានពេលដ៏ខ្លីបំផុតក្នុងឱកាសអនុវត្តសកម្មភាពដ៏ច្រើនទាំងនេះ។ លទ្ធផលទាំងនេះត្រូវបានសម្រេចពន្យារពេលបន្ថែមទៀតដើម្បីបង្កភាពងាយស្រួលក្នុងការសម្រេចបានគោលបំណងរបស់គម្រោងក្នុងឆ្នាំសិក្សាថ្មីចាប់ផ្តើមនៅខែតុលា ឆ្នាំ២០១៥។ នៅពេលនោះហើយដែលអង្គការ ខេប បានប្រើប្រាស់ពេលក្នុងវិស្សមកាលរដូវក្តៅទាំងអស់ដើម្បីត្រៀមកំណត់អត្តសញ្ញាណរបស់គ្រូ រួមទាំងការអភិវឌ្ឍផែនការសកម្មភាព ការធ្វើការផ្ទាល់ និងយុទ្ធសាស្រ្តជជែកពិភាក្សាជាមួយភាគីពាក់ព័ន្ធ។ ទោះយ៉ាងណាក៏នៅតែសម្រេចបានសមិទ្ធផលជាច្រើនក្នុងរយៈពេលខ្លីនៃការអនុវត្ត ព្រមទាំងការកើនឡើងនៅក្នុងការចុះឈ្មោះ និងការកែលម្អប្រសិទ្ធភាពសាលារៀន។ គម្រោង E2L មានប្រសិទ្ធភាពក្នុងការបញ្ចុះបញ្ចូលសហគមន៍ដែលសេវាកម្មសាលារៀនកំពុងងើបឡើងវិញមានគុណភាពខ្ពស់។

ការរីកចំរើនជាគន្លឹះដែលធ្វើឡើងដោយគម្រោង E2L រហូតមកដល់ពេលនេះគឺមានដូចខាងក្រោម៖

- **ការវិវត្តអក្ខរកម្មថ្នាក់ដំបូង:** ក្នុងគោលបំណងដើម្បីបន្តការលើកកម្ពស់សមត្ថភាពការអានរបស់កុមារ បុគ្គលិកគម្រោងបានរួមសហការជាមួយក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យ (DTMTs) បានធ្វើការវាយតម្លៃអ៊ីក្រាថ្នាក់ទី ៣ សម្រាប់នៅតាមសាលាគោលដៅមុនដើម្បីប្រើជាមូលដ្ឋានគ្រឹះមួយ។ បណ្ណាល័យដែលសាលាបួនបានទទួលការកែលម្អឱ្យប្រសើរឡើង មានកន្លែងធំទូលាយសម្រាប់សិស្សអាន និងរៀបចំសម្ភារៈដែលអាចហៅបានថាបណ្ណាល័យសតវត្សទី២១ ដែលរួមបញ្ចូលទាំងកម្មវិធី M-Learning និងអានខ្មែរ (Aan Khmer) តាមរយៈការប្រើប្រាស់ឧបករណ៍ថេប្លេត (Tablet)។
- **ការអភិវឌ្ឍ និងការអនុវត្តផែនការអភិវឌ្ឍសាលា:** សាលាប្រើប្រាស់វិធីសាស្រ្តជំរុញភាគីពាក់ព័ន្ធចូលរួមដើម្បីកំណត់បញ្ហា ដំណោះស្រាយ និងដាក់បញ្ហាទាំងអស់នោះទៅក្នុងផែនការកែលម្អសាលារៀនមួយឱ្យបានទូលំទូលាយ។ មិនតែប៉ុណ្ណោះ ក៏មានសិក្ខាសាលាសិទ្ធិកុមារមួយស្វែងរកតម្រូវការរបស់កុមារនៅដើមសិក្ខាសាលានេះ ដើម្បីប្រាកដថាតម្រូការរបស់កុមារទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍសាលារៀន។ ផែនការនេះរួមមានទាំងការវិនិយោគមានភាពប្រសើរឡើង ដើម្បីដោះស្រាយកង្វះខាតគ្រូបង្រៀន ជួយកុមារដែលមានការសិក្សាតម្រូវការពិសេស ផ្តល់អាហារូបករណ៍ និងការផ្តួចផ្តើមការអប់រំបំណិនជីវិតផងដែរ។
- **ការដោះស្រាយការកង្វះគ្រូបង្រៀន:** ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាកង្វះខាតគ្រូ បុគ្គលិកគម្រោង E2L បានដឹកនាំកិច្ចប្រជុំជាច្រើនជាមួយសាលារៀន សហគមន៍ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក ដើម្បីកំណត់ពីតម្រូវការគ្រូសហគមន៍ និងបេក្ខជនដែលមានសមត្ថភាពអាចធ្វើការប្រឡងចូលសាលាគរុកោសល្យចេញពីសហគមន៍គោលដៅ។ គម្រោង E2L បានការគាំទ្រពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀងក្នុងការប្រើវិធីសាស្រ្តក្នុងការជ្រើសរើសបេក្ខជនក្នុងស្រុកជាដំណោះស្រាយអចិន្ត្រៃយ៍លើកង្វះខាតគ្រូបង្រៀននៅក្នុងសាលា។

គម្រោងមានគោលបំណងដើម្បីអភិវឌ្ឍសមាហរណកម្មគំរូសាលាកុមារមេត្រីដែលពិតជាមានលក្ខណៈល្អនៅក្នុងផ្នែកជាច្រើន រួមមាន៖ គុណភាពអប់រំ កម្មវិធីបញ្ចូលគ្នា និងជំរុញភាគីពាក់ព័ន្ធនៅក្នុងស្រុក ឧ. មាតាបិតា សហគមន៍ គ្រូបង្រៀនថ្នាក់គ្រប់គ្រងសាលា។ សកម្មភាព និងលទ្ធផលគម្រោង ងាយស្រួលរៀនត្រូវបានចាត់ជាកម្រងមាន៤ក្រុម រួមមាន៖ (១).លើកកម្ពស់ភាពងាយស្រួលនៃការអប់រំ (២).លើកកម្ពស់គុណភាពអប់រំ និងបញ្ហាពាក់ព័ន្ធ (៣).កម្មវិធីអក្ខរកម្មថ្នាក់ដំបូងពាក់ព័ន្ធខ្លាំងគឺការរៀនតាមស្នាតហ្វូន និង (៤).ការលើកកម្ពស់ការគ្រប់គ្រងសាលារៀន។

អំឡុងពេលម្ចាស់អំណោយជាច្រើនបានប្តូរមកបន្តគម្រោងរួមបញ្ចូលតែមួយដែលផ្តោតទៅលើកម្មវិធី ដូចជា កម្មធីពង្រឹងអំណាន អង្គការ ខេប មានមោទនភាពណាស់ក្នុងការរៀបចំគម្រោងជាលក្ខណៈសមាហរណកម្មមួយគឺគម្រោង ងាយស្រួលរៀន (E2L)នេះ។

## សកម្មភាពសំខាន់ៗ

- បង្កភាពងាយស្រួលទទួលការអប់រំ (ជាពិសេស កុមារី និងកុមារដែលងាយរងគ្រោះ) ធ្វើឱ្យប្រសើរឡើងក្នុងតំបន់គោលដៅ។
- ប្រសិទ្ធភាពការអប់រំ (ឧ. គុណភាពអប់រំ) ធ្វើឱ្យប្រសើរឡើងតាមរយៈការអភិវឌ្ឍ និងអនុវត្តកម្មវិធីសាលាកុមារមេត្រី ដែលពាក់នឹងតម្រូវការរបស់កុមារងាយរងគ្រោះ ជាពិសេស ក្មេងស្រី។
- សមត្ថភាពអំណានកុមារធ្វើឱ្យប្រសើរឡើងពីមូលដ្ឋានថ្នាក់ដំបូង (ថ្នាក់ទី១-៣)
- បង្កើនសមត្ថភាពគ្រប់គ្រងដៃគូក្នុងស្រុកដើម្បីផ្ទេរជំនួយអភិវឌ្ឍ ដែលជាការពង្រឹងភាពងាយស្រួលនៃការអប់រំ និងគុណភាព ក៏ដូចជាការផ្សព្វផ្សាយរបស់សហមមន៏ផងដែរ។



*បុគ្គលិកអង្គការឆាលហ្វានបានចុះមើលស្ទួនជីវៈដើម្បីស្វែងយល់អំពីសកម្មភាពបង្កើតថ្មី និងស្វែងយល់អំពីប្រសិទ្ធភាពកម្មវិធីបំណិនជីវិត។*



*ក្រុមការងារថ្នាក់ស្រុក និងខេត្ត (DTMT) បានអញ្ជើញចូលរួមក្នុងសិក្ខាសាលាស្តីពីការកសាងសមត្ថភាព ដើម្បីអភិវឌ្ឍវិធីថ្មីៗសម្រាប់បង្រៀនសិស្ស និងគ្រប់គ្រងសាលា។*

## “ ការរៀបចំគម្រោងសមាហរណកម្មដែលធានានូវផលជះរយៈពេលយូរក្នុងការអប់រំ ”

## ផលជះរបស់គម្រោង

- សមត្ថភាពអំណានរបស់កុមារនៅថ្នាក់ដំបូងមានការកើនឡើងយ៉ាងខ្លាំង បើយោងលើតេស្តអ៊ីក្រា គឺថ្នាក់ទី១កើនពីកម្រិត ៧% ដល់ ១៤% និងថ្នាក់ទី២កើនពីកម្រិត ៩% ដល់ ២៥%។ ធ្វើឱ្យប្រសើរឡើងអាចត្រូវបានកំណត់គុណលក្ខណៈការអនុវត្តន៍ប្រព័ន្ធឆ្លើយតបរហ័សរបស់គម្រោង ដែលបានរចនាឡើងដើម្បីជួយដល់សិស្សដែលមានតម្រូវការធំបំផុត។
- ការវាយតម្លៃគ្រូបង្រៀនបានបង្ហាញថា ៨0%នៃគ្រូទាំងអស់ដែលបានពិន្ទុខ្ពស់ជាង ៥0% នៅលើឧបករណ៍ស្តង់ដាមានន័យថា ជាទូទៅ ពិន្ទុមធ្យម ៧២% ដែលនេះបង្ហាញថា គ្រូបង្រៀនភាគច្រើនអាចប្រើសៀវភៅស្តង់ដាអំណានយ៉ាងមានប្រសិទ្ធិភាព ដែលជាឯកសារគោលដើម្បីគាំទ្រសៀវភៅស្នូលជាតិ ការធ្វើតេស្តតាមដំណាក់កាល និងតាមដានដំណើរការបង្រៀន និងរៀន។
- ការវាយតម្លៃឥរិយាបថលើកុមារមួយទៀត ដែលបានត្រួតពិនិត្យដំណើរការចូលអានបានបង្ហាញថា មានការកើនឡើងរហូតដល់ ៦៧% លើ ៥0% ដោយមានន័យថាពិន្ទុមធ្យមគឺ ៦៣%។



បុគ្គលិកអង្គការឆាលហ្វាន់ចុះទស្សនកិច្ចនៅបណ្ណាល័យសតវត្សរ៍ទី២១ថ្មីរបស់ គម្រោង E2L ដើម្បីរៀនសូត្រអំពីរចនាបទថ្មី និងប្រជាប្រិយភាពបណ្ណាល័យ

## រឿងជោគជ័យ:

### បណ្ណាល័យគំរូសតវត្សទី២១បានធ្វើឱ្យផ្លាស់ប្តូរសមត្ថភាពអំណាន និងទម្លាប់សិស្ស ក៏ដូចជាឥរិយាបថរបស់អ្នកពាក់ព័ន្ធសាលារៀនផងដែរ

ជាលទ្ធផលមួយក្នុងចំណោមលទ្ធផលសំខាន់ៗរបស់គម្រោង E2L គឺជាការអភិវឌ្ឍប្រភេទបណ្ណាល័យគំរូថ្មីត្រូវនឹងតម្រូវការនៅសតវត្សទី២១។ បណ្ណាល័យគំរូថ្មីដំបូងត្រូវបានកសាងឡើងនៅសាលាបឋមសិក្សា ចារ ខេត្តស្វាយរៀង និងធ្វើឱ្យការប្រើប្រាស់សម្ភារៈនៅអាគារនេះមានលក្ខណៈទូលំទូលាយ រួមមាន៖ បំពាក់ដោយហ្វំរមីកា និងកញ្ចក់។ បណ្ណាល័យចាស់ពីមុនដែលគាំទ្រថវិកាដោយម្ចាស់អំណោយផ្សេងៗ ប្រើប្រាស់គ្រឿងសង្ហារឹមធ្វើពីឈើហួសសម័យគ្មានភាពងាយស្រួលសម្រាប់បណ្ណាល័យសាលាជនបទ ដែលមានលក្ខណៈតូចចង្អៀត។ ជាលទ្ធផល ការរៀបចំបណ្ណាល័យគ្មានប្រសិទ្ធភាពក្នុងការប្រើប្រាស់របស់ពួកគេ គ្មានរំលេចពណ៌ទាក់ទាញ និងគ្មានក្តីស្រមៃល្អបង្ហាញដល់កុមារ។ ដោយមានការគាំទ្រពីអង្គការឆាលហ្វាន អង្គការ ខេប បានបង្ហាញពីការបំពាក់គ្រឿងសង្ហារឹម ហ្វ៉ំរមីកា ដែលសមរម្យបំផុតចំពោះទីកន្លែង និងទំហំបណ្ណាល័យនៅក្នុងស្រុក។ ការរៀបចំបណ្ណាល័យថ្មីនេះបានលើកកម្ពស់កន្លែងអំណានមានរំលេចពណ៌ល្អ គ្រឿងសង្ហារឹមមានមុខងារច្រើនយ៉ាង កន្លែងអានភ្លឺស្អាត និងមានបរិស្ថានទាក់ទាញ។ បណ្ណាល័យទាំងនេះក៏បានបង្ហាញអំពីឧបករណ៍រៀនបែបចល័តផងដែរ ដែលដំបូងធ្វើឱ្យកុមារជនបទអាចប្រើកម្មវិធីសូសវែរអានភាសាខ្មែរដោយភ្ជាប់នឹងកម្មវិធីសិក្សាថ្នាក់ជាតិ ដែលសម្រួលឱ្យពួកគេរៀនដោយខ្លួនឯងបានច្រើន។ ជោគជ័យបណ្ណាល័យគំរូថ្មីនេះមានការគួរឱ្យកត់សំគាល់ ហើយអង្គការ ខេប នឹងចាប់ផ្តើមបង្កើតបណ្ណាល័យបែបនេះចំនួន៥ទៀតនៅឆ្នាំក្រោយ។

បន្ទាប់ពីបណ្ណាល័យគំរូត្រូវជួសជុលឡើងវិញនៅខែកក្កដា ឆ្នាំ២០១៥ ឥរិយាបថសិស្សមានការផ្លាស់ប្តូរពីព្រោះពួកគេបានរកឃើញថាអ្វីដែលធ្វើឱ្យចូលចិត្តមកអានសៀវភៅនៅក្នុងបណ្ណាល័យគំរូថ្មីនេះ ហើយពួកគេក៏ចាប់ផ្តើមចូលចិត្តរៀនសូត្រយ៉ាងសកម្ម។ លោក សេក សាម៉ុន ជាលេខាសាលាបានពន្យល់ថា បណ្ណាល័យគំរូនេះត្រូវបានជួសជុលឡើងវិញដោយគម្រោង ងាយស្រួលរៀន និងបានបើកប្រើប្រាស់ជាផ្លូវការនៅខែកក្កដា ឆ្នាំ២០១៥។ ដោយមានស្នាមញញឹម និងទឹកមុខសប្បាយ លោកបាននិយាយថា ចំនួនសិស្សមកអានសៀវភៅនៅបណ្ណាល័យមានការកើនឡើងពី៣0% រហូតជាង៨0%។ *“ចំនួនសិស្សកើនឡើងមកអានសៀវភៅ និងលេងល្បែងសិក្សានៅក្នុងបណ្ណាល័យគំរូនេះគឺជាចំនួនមិនគួរឱ្យជឿព្រោះពីមុនគ្មានចំនួនសិស្សច្រើនមកប្រើប្រាស់បណ្ណាល័យទេ”*។ បណ្ណាល័យថ្មីនេះបានជួយអភិវឌ្ឍសមត្ថភាពអំណានកុមារបានច្រើន។ បច្ចុប្បន្ននេះ សាលាបឋមសិក្សា ចារ មានបណ្ណាល័យនាំមុខគេក្នុងការជួយលើកកម្ពស់ការអនុវត្តន៏ស្តង់ដាអំណានតាមរយៈប្រព័ន្ធឆ្លើយតបរហ័ស ដែលត្រូវបានបង្កើតឡើងផងដែរ ដើម្បីជួយសិស្សកំពុងព្យាយាមរៀនអំណាន។ ប្រព័ន្ធឆ្លើយតបរហ័សផ្តែកលើកម្មវិធីសូសវែរយ៉ាងខ្លាំងដើម្បីជួយកុមារហ្វឹកហ្វឺនអំណាន។

បណ្ណាល័យគំរូក៏បានទទួលការគាំទ្រយ៉ាងខ្លាំងផងដែរពីគណៈកម្មការទ្រទ្រង់សាលា។ លោក ចេន មករា ដែលជាសមាជិកគណៈកម្មការទ្រទ្រង់សាលាបានមានប្រសាសន៏ថា គណៈកម្មការទ្រទ្រង់សាលាបានផ្តល់មូលនិធិមួយចំនួនបានមកពីសហគមន៏ដើម្បីដាក់បង្អួចជញ្ជាំងកញ្ចក់ធ្វើឱ្យបណ្ណាល័យមានពន្លឺបែបធម្មជាតិ។ ប្រជាជននៅទីនេះពិតជាមានការពេញចិត្តបណ្ណាល័យនេះណាស់ និងសូមឱ្យគ្រប់សាលាទាំងអស់មានបណ្ណាល័យដូចនេះ៕



សិស្សត្រូវបានលើកទឹកចិត្តឱ្យចូលអានសៀវភៅនៅបណ្ណាល័យសតវត្សទី២១យ៉ាងសកម្ម និងរៀនភាសាខ្មែរតាមរយៈកម្មវិធីសូវែរថ្មីដើម្បីលើកកម្ពស់អក្ខរកម្ម។



# ២៦

# គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ (E4K)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការ All Children Reading ដែលទទួលមូលនិធិរួមពី (ACR)<br>• World Vision<br>• USAID<br>• DFAT |
| អ្នកទទួលផលផ្ទាល់ | សិស្សថ្នាក់ទី២ និងថ្នាក់ទី៣ |
| ថវិកាទទួលក្នុងឆ្នាំ ២០១៥ | ៧៣.៣៣៥ ដុល្លាអាមេរិក |
| ថវិកាប្រតិបត្តិក្នុងឆ្នាំ ២០១៥ | ៧៣.៤៥៨,៧២ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | កំពង់ចាម និងត្បូងឃ្មុំ |
| ចំនួនស្រុកគ្របដណ្តប់ | ១១ ស្រុក |
| អនុវិទ្យាល័យគោលដៅ | ១៥ សាលា (សាលាអនុវត្តមានចំនួន ១០ និង សាលាប្រៀបធៀបមានចំនួន ៥) |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | ១៥ មករា ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | ១៤ មករា ២០១៧ |

## បច្ចុប្បន្នភាពគម្រោង

នៅខែមីនា ឆ្នាំ២០១៤ អង្គការ ខេប បានធ្វើសំណើសុំថវិកាសម្រាប់ការច្នៃប្រឌិតទៅលើកម្មវិធីអំណានពីអង្គការ ACR។ ក្រោយមកនៅខែវិច្ឆិកា ឆ្នាំ២០១៤ អង្គការ ខេប ក៏បានទទួលព័ត៌មានថាបានឈ្នះថវិកាដែលស្នើសុំ។ នៅខែមករា ឆ្នាំ ២០១៥ កិច្ចព្រមព្រៀងរវាងអង្គការ ខេប និងអង្គការទស្សនៈពិភពលោកដែលជាអង្គការគ្រប់គ្រង់លើសំណើសុំត្រូវបានបង្កើត។ នៅខែកុម្ភៈ ឆ្នាំ២០១៦ គណៈប្រតិភូរបស់គម្រោងដែលរួមបញ្ចូលទាំងធនធានសិក្សា (ដៃគូសហគ្រាសឯកជន) បានចូលរួមក្នុងព្រឹត្តិការណ៍សម្ពោធន៏គម្រោងជាផ្លូវការនៅទីក្រុងវ៉ាស៊ិនតោន សហរដ្ឋអាមេរិក។ នៅឆ្នាំដំបូងនេះ ការអនុវត្តសកម្មភាពគម្រោងគឺផ្តោតចំបងលើការអភិវឌ្ឍកម្មវិធីអេឡិចត្រូនិច ដែលអាចជួយបំលែងអត្ថបទអំណានសៀវភៅសិក្សាគោលឱ្យទៅជាអត្ថបទបែបអេឡិចត្រូនិច និងរួមបញ្ចូលតេស្តវាយតម្លៃដោយស្វ័យប្រវត្តិ។ ក្រុមហ៊ុនផលិតកម្មវិធីសូសវែរឈ្មោះ ខែម អាន ត្រូវបានជ្រើសរើសពីការប្រកួតប្រជែងនៅដើមឆ្នាំរបស់គម្រោង ហើយបានបង្កើតសៀវភៅអេឡិចត្រូនិចជាភាសាខ្មែរ។

ក្នុងអំឡុងពេលអភិវឌ្ឍសៀវភៅអេឡិចត្រូនិច អង្គការ ខេប បានធ្វើការវិភាគអត្ថបទក្នុងសៀវភៅសិក្សាគោលដើម្បីបង្កើតរូបមន្តកម្រិតអំណាន ដោយធ្វើការវាស់ទៅកម្រិតលំបាកនៃអត្ថបទ ដើម្បីអាចបង្កើតសៀវភៅអេឡិចត្រូនិចតាមកម្រិតសមត្ថភាពសិស្ស។ នេះគឺជាលើកទីមួយហើយដែលទ្រឹស្តីរូបមន្តកម្រិតអានត្រូវបានយកមកប្រើសម្រាប់ភាសាខ្មែរ ហើយក៏ជាសមិទ្ធផលដ៏ធំធេងសម្រាប់ការបង្កើតអត្ថបទអានតាមកម្រិត។

## ប្រវត្តិ និងគោលបំណង

គម្រោងសៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ (E4K) គឺជាគម្រោងដែលធ្វើការផ្តែកទៅលើបច្ចេកវិទ្យាជាមូលដ្ឋានដើម្បីលើកកម្ពស់សមត្ថភាពអានរបស់កុមារនៅកម្ពុជា។ គម្រោងនេះគឺជាគម្រោងមួយក្នុងចំណោមគម្រោងជាសកលទាំង ១៥ ដែលត្រូវបានជ្រើសរើសចេញពីសំណើសុំគម្រោងសរុបចំនួន២៥០ ដោយអង្គការ All Children Reading។

គម្រោងនេះមានគោលការណ៍សំខាន់ៗចំនួន ៤ ក្នុងការអភិវឌ្ឍសៀវភៅអេឡិចត្រូនិច រួមមាន៖ (i) ការបង្កើតសៀវភៅអានតាមកម្រិតសមត្ថភាពសិស្ស (ដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិច)។ (ii) ការបង្កើតតេស្តខ្លីៗបញ្ចូលទៅក្នុងសៀវភៅអាន។ (iii) ការបង្កើតវិធីសាស្រ្តបង្រៀនអំណានតាមតម្រូវការសិស្ស (DCLS)(ឧ. ក្រុមអំណានតាមកម្រិតសមត្ថភាព) ដែលកុមារអាចទទួលបានភាពជឿជាក់ពីការអានក្នុងកម្រិតមួយត្រឹមត្រូវ (ដែលផ្ទុយគ្នានឹងការប្រើប្រាស់វិធីសាស្រ្ត ឬសម្ភារៈអំណានតែមួយប្រភេទសម្រាប់សិស្សគ្រប់រូប) និង (iv) ការចែកផ្សាយសៀវភៅអេឡិចត្រូនិចតាមរយៈការចូលរួមពីដៃគូសហគ្រាសសង្គមធនធានសិក្សា (TTS)។ ជាសរុប ការប្រើប្រាស់សៀវភៅអេឡិចត្រូនិចតាមកម្រិតសមត្ថភាពនឹងក្លាយជាមូលដ្ឋានដ៏សំខាន់មួយក្នុងការលើកកម្ពស់ការបង្រៀនអំណានតាមតម្រូវការសិស្ស (DCLS)។

នៅក្នុងឆ្នាំនេះ គម្រោងបានបន្តកសាងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយក្រុមការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា លើការកែសម្រួលអត្ថបទក្នុងសៀវភៅសិក្សាគោលឱ្យទៅជាអត្ថបទអានបែបអេឡិចត្រូនិចតាមកម្រិតសមត្ថភាព។




*កម្មវិធី E4K ថ្នាក់ទី២ និងថ្នាក់ទី៣*

បន្ទាប់ពីកែសម្រួល និងប្រើប្រាស់រូបមន្តកម្រិតអានដូចបានរៀបរាប់ខាងលើ ក្រុមការងារអង្គការ ខេប និងអ្នកនិពន្ធក្រសួងដែលមកពីនាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបានបង្កើតអត្ថបទអានបានចំនួន ២៤អត្ថបទ ស្មើនឹង ៧២អត្ថបទតាមកម្រិតសមត្ថភាព ព្រោះអត្ថបទនីមួយៗមានបីកម្រិតសមត្ថភាព។ ដោយក្នុងនោះអត្ថបទថ្នាក់ទី២ មាន១០អត្ថបទ និងថ្នាក់ទី៣ មាន ១៤អត្ថបទ។

## រូបមន្តអំណានដែលបានអនុវត្ត

Figure 3:Average Sentence Length of Each E-book in Grades 2 & 3




| | Ebook A | Ebook B | Ebook C | Ebook D | Ebook E | Ebook F | Ebook G | Ebook H | Ebook I | Ebook J | Ebook K | Ebook L | Ebook M | Ebook N |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Grade 2 Lv1 | 15.17 | 15.50 | 16.00 | 16.00 | 16.67 | 16.83 | 17.17 | 17.33 | 17.50 | 17.67 | | | | |
| Grade 2 Lv2 | 16.25 | 16.88 | 17.25 | 17.38 | 17.63 | 18.00 | 18.50 | 18.50 | 18.63 | 19.25 | | | | |
| Grade 2 Lv3 | 18.40 | 18.40 | 18.50 | 18.90 | 19.10 | 19.50 | 19.60 | 19.70 | 20.30 | 20.60 | | | | |
| Grade 3 Lv1 | 18.57 | 18.71 | 18.86 | 19.57 | 20.14 | 20.43 | 20.71 | 20.86 | 21.00 | 21.43 | 21.71 | 22.14 | 22.71 | 23.71 |
| Grade 3 Lv2 | 19.33 | 20.44 | 20.56 | 20.89 | 21.56 | 22.22 | 22.56 | 22.67 | 22.67 | 23.11 | 23.56 | 23.89 | 24.33 | 25.56 |
| Grade 3 Lv3 | 21.00 | 21.64 | 22.64 | 23.00 | 23.55 | 23.64 | 24.18 | 24.45 | 24.45 | 24.55 | 24.91 | 26.27 | 26.91 | 28.18 |

ដូចបានឃើញនៅក្នុងតារាងនេះ កម្រិតលំបាកនៃអត្ថបទពីមួយកម្រិតទៅមួយកម្រិតកើនឡើងបន្តិចម្តងៗ។ នេះជាសមិទ្ធផលដ៏ធំធេងដែលគម្រោងសម្រេចបានលើការបង្កើតអត្ថបទឱ្យមានកម្រិតលំបាកកើនឡើងពីមួយអត្ថបទទៅមួយអត្ថបទជាក់ស្តែងដូចបង្ហាញក្នុងក្រាហ្វិចខាងលើ។ ក្រៅពីនេះ ក្រាហ្វិចក៏បានបង្ហាញថាកម្រិតលំបាកនៃអត្ថបទកម្រិតទី៣ក្នុងថ្នាក់ទី២ ទាបជាងអត្ថបទកម្រិតទី១ក្នុងថ្នាក់ទី៣។ អត្ថបទដែលបានកែសម្រួលថ្មីទៅតាមកម្រិតនេះខុសពីអត្ថបទសៀវភៅសិក្សាគោលរបស់ក្រសួងដែលកម្រិតលំបាកពីមួយអត្ថបទទៅមួយអត្ថបទឡើងចុះមិនស្មើគ្នា។

## រូបភាពសំខាន់ៗនៃដំណើរការអភិវឌ្ឍសៀវភៅអេឡិចត្រូនិច



កិច្ចអង្គប្រជុំអ្នកនិពន្ធសៀវភៅអេឡិចត្រូនិចៈ អ្នកនិពន្ធរួមមានទាំងអង្គការ ខេប និងក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់រូបមន្តអំណានដើម្បីអភិវឌ្ឍកម្រិតអ្នកអាន។



កិច្ចអង្គប្រជុំជាមួយអ្នកបង្កើតសូសវែរៈ ក្រុមការងារគម្រោង E4K ផ្តល់ព័ត៌មានត្រឡប់អំពីមូលដ្ឋានគ្រឹះ App ដល់អ្នកបង្កើតសូសវែរ។

## សកម្មភាពសំខាន់ៗ

អំឡុងពេលអនុវត្តសកម្មភាពគម្រោង E4K នៅក្នុងឆ្នាំទី១នេះ គម្រោងបានផ្តោតជាចំបងទៅលើការផលិតឯកសារ និងការអភិវឌ្ឍសូសវែរ ហើយគម្រោងក៏រួមបញ្ចូលនៅការរៀបចំការស្រាវជ្រាវជាលក្ខណៈសាកល្បង (ពិសោធន៍) ដែលនឹងអាចធ្វើឱ្យគម្រោងអនុវត្តស្តង់ដា ដោយការត្រួតពិនិត្យយ៉ាងច្បាស់លាស់ទៅលើផលជះរបស់គម្រោង។ រហូតដល់ចុងឆ្នាំនេះ គម្រោងបានសម្រេចបាននូវលទ្ធផលដែលបានអនុវត្តជាបន្តបន្ទាប់ដូចបានរៀបរាប់ខាងក្រោម៖

- បានកំណត់សមភាពក្រុមការងាររបស់ក្រសួងដើម្បីចូលរួមក្នុងការវិភាគខ្លឹមសារអត្ថបទ និងដំណើរការកែសម្រួលនឹងនិពន្ធអត្ថបទ។ ក្រុមការងារត្រូវបានចាត់តាំងពីនាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។
- បានបង្កើតរូបមន្តកម្រិតអំណានដើម្បីសម្រួលដល់ការបង្កើតអត្ថបទតាមកម្រិតសមត្ថភាព។
- បានបង្កើតអត្ថបទតាមកម្រិតចំនួន៧២កម្រិតដោយផ្អែកលើការប្រើប្រាស់រូបមន្តកម្រិតអំណានទៅលើអត្ថបទនៃសៀវភៅសិក្សាគោលដែលស្របតាមកម្មវិធីសិក្សារបស់ក្រសួង។
- បានបង្កើតគោលការណ៍ណែនាំស្តីពីការបង្កើតកម្មវិធីអេឡិចត្រូនិចដោយរួមបញ្ចូលនូវសម្លេង ការប្រើពណ៌អត្ថបទ និងតន្ត្រីជាដើម។ល។
- បានបង្កើតទ្រង់ទ្រាយកម្មវិធីសៀវភៅអេឡិចត្រូនិចដោយភ្ជាប់ជាមួយមុខងារបែបអន្តរកម្ម។
- បានកំណត់គោលការណ៍ក្នុងការជ្រើសរើសដោយចៃដន្យនូវសាលាគោលដៅដោយផ្អែកលើបញ្ជីឈ្មោះសាលាដែលបានចាត់តាំងពីការិយាល័យអប់រំស្រុក និងធ្វើការជម្រុះតាមរយៈលក្ខណៈវិនិច្ឆ័យ និងការចុះត្រួតពិនិត្យសាលា។
- បានធ្វើការបែងចែកសាលាគោលដៅជាពីរប្រភេទ គឺសាលាអនុវត្តសកម្មភាពគម្រោង និងសាលាប្រៀបធៀប។




រូបភាពទី៣ៈ កម្មវិធីសៀវភៅអេឡិចត្រូនិចភាសាខ្មែររបស់គម្រោង E4K មាន៣កម្រិតសមត្ថភាព



ការបង្ហាញអំពីកម្មវិធីរបស់គម្រោង E4K ដល់លោកនាយកសាលា

# ២៨ គម្រោង ពង្រឹងសិទ្ធិអំណាចយុវជន តាមរយៈការអប់រំ និងការតស៊ូមតិ ( EYEA)

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | Work Precision Instruments (WPI) |
| អ្នកទទួលផលផ្ទាល់ | យុវជនទាំងក្នុង និងក្រៅសាលាចំនួន ៨៨៣នាក់ |
| ថវិកាទទួលបានក្នុងឆ្នាំ ២០១៥ | ១៨.៦៤២ ដុល្លាអាមេរិក |
| ថវិកាសម្រាប់អ្នកទទួលផលក្នុងម្នាក់ | ២១ ដុល្លាអាមេរិក |
| ខេត្តគ្របដណ្តប់ | កំពង់ចាម |
| ស្រុកគ្របដណ្តប់ | ៣ ស្រុក (ជើងព្រៃ កំពង់ចាម ត្បូងឃ្មុំ) |
| បឋមសិក្សាគោលដៅ | គ្មាន |
| វិទ្យាល័យគោលដៅ | ៣ (វិ. ហស.ស្គន់ អនុវិ. ហស អនុវត្ត វិ. សម្តេចម៉ែ) |
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | មករា ២០១៥ |
| កាលបរិច្ឆេទបញ្ចប់គម្រោង | កញ្ញា ២០១៥ |

## គោលបំណង

ពង្រឹងសិទ្ធិអំណាចយុវជនងាយរងគ្រោះនៅក្នុងទីជនបទ និងទីប្រជុំជន តាមរយៈការអប់រំ និងការបណ្តុះបណ្តាលឱ្យក្លាយជាពលរដ្ឋដែលត្រូវបានផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច សង្គម និងការតស៊ូមតិ ។

## សកម្មភាព ឬសេវាកម្មគោល

1. សេវាកម្មប្រឹក្សាអាជីពនៅសាលារៀន
2. គាំទ្របច្ចេកទេសដល់កម្មវិធីយុវជនរបស់អង្គការ ខេប ទាំងអស់
3. បង្កើតបណ្តាញទិន្នន័យភ្ជាប់សេវាកម្មផ្ញើសាររបស់ក្រុមហ៊ុនទូរស័ព្ទ។
4. គោលការណ៍ណែនាំសម្រាប់សេវាកម្ម/មណ្ឌលព័ត៌មាន។
5. ការបង្កើតបណ្តាញ និងភាពជាដៃគូ
6. សេវាកម្មភ្ជាប់ខាងក្រៅមកមណ្ឌល
7. មូលនិធិជំនួយដើម្បីគាំទ្រយុវជនងាយរងគ្រោះដែលចង់ចុះឈ្មោះក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។

## សេចក្តីសង្ខេបគម្រោង

គម្រោង **ពង្រឹងសិទ្ធិអំណាចយុវជនតាមរយៈការអប់រំ និងការតស៊ូមតិ** បានកើតចេញពីគម្រោង **ការអប់រំដើម្បីពង្រឹងសិទ្ធិអំណាចយុវជន** (EYE) ដែលគាំទ្រមូលនិធិដំបូង ប៉ុន្តែក្រោយមកនៅចុងឆ្នាំ២០១៤ ត្រូវបានបញ្ឈប់ការគាំទ្រមូលនិធិពីអង្គការ Save the Children។ ដោយសារតែការតាំងចិត្តខ្ពស់របស់ខ្លួនចំពោះបញ្ហាដែលពាក់ព័ន្ធនឹងការពង្រឹងសិទ្ធិអំណាចយុវជនដូចដែលបានកែតម្រូវនៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៤-១៩ អង្គការ ខេប បានសម្រេចចិត្តធ្វើការតស៊ូមតិយ៉ាងខ្លាំងចំពោះធនធានដែលមានដើម្បីបន្តគម្រោងនេះ ហើយក៏ជាការវាស់ស្ទង់ផ្ទៃក្នុងមួយរហូតដល់អង្គការ ខេប អាចបង្កើតផ្នែកអភិវឌ្ឍយុវជននៅក្នុងស្ថាប័នដែលនឹងផ្តល់ការគាំទ្របច្ចេកទេសសម្រាប់ការបង្កើតកម្មវិធីយុវជននៅអង្គការ ខេប។ ការពិភាក្សាថ្មីៗនេះជាមួយអង្គការឆាលហ្វានបានផ្តល់ការលើកទឹកចិត្តមួយដល់ការបង្កើតផ្នែកនេះក្នុងពេលអនាគត។ អង្គការ ខេប បានដាក់ឈ្មោះថ្មីនូវគម្រោងចាស់របស់ខ្លួនទៅជាគម្រោង **ពង្រឹងសិទ្ធិអំណាចយុវជនតាមរយៈការអប់រំ និងការតស៊ូមតិ** ឬ EYEA ដើម្បីឱ្យខុសប្លែកពីគម្រោង EYE របស់អង្គការ Save the Children ដែលបានប្តូរទិសដៅទៅទីក្រុងភ្នំពេញ។ គម្រោងនេះបានធ្វើការយ៉ាងជិតស្និទជាមួយគម្រោងដែលផ្តោតលើយុវជនផ្សេងទៀតនៅក្នុងអង្គការ ខេប ដូចជា GEI CTSP និង BSI ហើយបានផ្តល់ការគាំទ្របច្ចេកទេសយ៉ាងខ្លាំងដល់សេវាប្រឹក្សាអាជីព ការកសាងធនធានឯកសារដែលបានរៀបចំអំឡុងពេលការគាំទ្ររបស់ EYE។

អស់រយៈពេលមួយឆ្នាំនេះ EYEA បានកសាងភាពជាដៃគូជាមួយស្ថាប័នហិរញ្ញវត្ថុ និង MFIs ដូចជាធានាគារអេស៊ីលីដា គ្រឹះស្ថានហិរញ្ញវត្ថុអម្រឹត ស្ថាបនាព្រមទាំងសមភាគីរដ្ឋាភិបាលនៅក្នុងខេត្តកំពង់ចាម ដូចជា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត (PTC) មណ្ឌលការងារខេត្ត មណ្ឌលយុវជន អង្គការអន្តរជាតិ និងអង្គការក្នុងស្រុកមួយចំនួនទៀត។ គោលបំណងចម្បងនៃការបង្កើតបណ្តាញនេះ គឺដើម្បីភ្ជាប់គម្រោង និងអ្នកផ្តល់សេវាកម្មដល់យុវជនផ្សេងទៀតដើម្បីជាសវាងការធ្វើជាន់ការងារគ្នា និងធ្វើសេវាកម្មបន្តដល់ស្ថាប័នខ្លះខាងលើ។

មណ្ឌលយុវជនរបស់ EYEA គឺបង្កើតឡើងចំកណ្តាលសម្រាប់យុវជនមកទទួលសេវាប្រឹក្សាទទួលបានការកសាងសមត្ថភាពក្នុងការស្វែងរកអាជីព និងស្វែងរកការងារធ្វើ។ មណ្ឌលផ្តល់ឱកាសស្វ័យសិក្សាជាច្រើនដោយផ្តល់នូវភាពងាយស្រួលដល់ការប្រើប្រាស់ថេប្លែត សម្ភារៈអាន កុំព្យូទ័រសម្រាប់ការស្រាវជ្រាវ។ EYEA ក៏បានបង្កើតប្រព័ន្ធទិន្នន័យយុវជនដែលវាប្រើប្រាស់សម្រាប់ផ្ញើសារជាកញ្ចប់ដល់យុវជនទាំងនៅក្នុងសាលា និងក្រៅសាលាចំពោះការបំប៉នសមត្ថភាព និងឱកាសការងារផងដែរ។

## រូបភាពសំខាន់ៗ







*ការប្រឹក្សាមួយទល់មួយ↑*

*← សិស្សប្រើ IMac ដើម្បីមើលការងារអាជីព (រូបខាងលើឆ្វេង)*

*← ការសមសកម្មភាពរបស់សិស្ស (រូបខាងក្រោមឆ្វេង)*

## បច្ចុប្បន្នភាពគម្រោង

គម្រោង EYEA បានធ្វើការយ៉ាងសកម្មក្នុងការលើកកម្ពស់សេវាប្រឹក្សាមួយទល់និងមួយនៅក្នុងសាលាគម្រោង BSI។ ក្នុងរយៈពេលមួយឆ្នាំ គម្រោងបានរកឃើញសិស្សដែលងាយរងគ្រោះជាង ២០០នាក់ ដែលត្រូវការការប្រឹក្សាជាបុគ្គលមួយទល់និងមួយ ហើយទទួលបានជោគជ័យក្នុងការគាំទ្រផ្សេងៗសឹងតែ ៨០% នៃសិស្សទាំងនោះ។

**សកម្មភាពប្រឹក្សារបស់គម្រោង EYEA ជាមួយសិស្សដែលងាយរងគ្រោះ**

| សាលា | ការសិក្សាអំពីចំនួនសិស្ស | | សិស្សដែលងាយគ្រោះទាំងអស់ជា% | | សិស្សដែលងាយគ្រោះបន្ទាប់ពីសិក្សាជា% | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សាលាអនុវត្ត | ២២៤ | ១៤២ | ១០% | ៨% | ៩៦% | ១០០% |
| វិ. ហស ស្គន់ | ៨៦២ | ៣៧៩ | ១៤% | ១២% | ៥១% | ៤៨% |
| វិ. សម្តេចម៉ែ | ៣៩២ | ១៧៥ | ១៤% | ១១% | ៨២% | ៩០% |
| **សរុប** | **១.៤៧៨** | **៦៩៦** | **១៤%** | **១១%** | **៦៥%** | **៧៧%** |

# ព្រឹត្តិការណ៍សំខាន់ៗ និងការអភិវឌ្ឍនៅក្នុងឆ្នាំនេះ

## *“ ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន ”*

ឆ្នាំ២០១៥គឺជាឆ្នាំព្រឹត្តិការណ៍មួយដែលទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID)បានបញ្ចប់ការផ្តល់មូលនិធិដល់កម្មវិធីរបស់អង្គការ ខេប រួមមានកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា (SDPP) ដែលជាកម្មវិធីដ៏ធំបំផុតរបស់អង្គការ ខេប ត្រូវបានបិទបញ្ចប់នៅខែកញ្ញា ឆ្នាំ២០១៥។ ទោះបីជាយ៉ាងណាក៏ដោយ ដៃគូថ្មីជាមួយអង្គការឆាលហ្វាន អូស្ត្រាលី បានសន្យាធ្វើជាដៃគូដ៏សំខាន់ថ្មីជាមួយអង្គការ ខេប ដែលនឹងមានរយៈពេលយូរអង្វែង ហើយគឺជាដៃគូក្នុងចំណោមដៃគូមានសមភាពដែលអង្គការ ខេប មានសេរីភាពសម្រេចចិត្តរៀបចំគម្រោងដើម្បីលើកកម្ពស់ការច្នៃប្រឌិតថ្មីមានស្រាប់។ ព្រឹត្តិការណ៍សំខាន់មួយទៀតនៅចុងឆ្នាំនេះគឺ ការធ្វើកិច្ចព្រមព្រៀងជាមួយក្រសួងអប់រំ យុវជន និងកីឡា អង្គការ ខេប បានទទួលថវិកាផ្ទាល់ពីក្រសួងអប់រំ យុវជន និងកីឡា មកអនុវត្តកម្មវិធីសាកល្បងគម្រោងសាលារៀនជំនាន់ថ្មី។ ខាងក្រោមគឺជាសេចក្តីសង្ខេបព្រឹត្តិការណ៍នៅក្នុងឆ្នាំនេះ...។



### ជំនួបដំបូងរបស់នាយកប្រតិបត្តិអង្គការ ខេប ជាមួយលោកជំទាវរបស់សហរដ្ឋអាមេរិក

អង្គការ ខេប មានកិត្តិយសដ៏អស្ចារ្យនៅក្នុងឆ្នាំនេះដោយមានការអញ្ជើញពីស្ថានទូតសហរដ្ឋអាមេរិកចូលរួមពិភាក្សាតុមូលមួយជាមួយលោកជំទាវ **មីហ្សែល អូបាម៉ា**។ អង្គការ ខេប គ្រាន់តែជាអង្គការសង្គមស៊ីវិលប៉ុណ្ណោះដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ ដែលបានធ្វើឱ្យអង្គការ ខេប មានកិត្តិយសពន់ពេក។ ការពិភាក្សាជាមួយលោកជំទាវ **មីហ្សែល អូបាម៉ា** ដោយផ្អែកលើបទពិសោធន៍របស់អង្គការ ខេប លោក **សៅ វណ្ណា** ជានាយកប្រតិបត្តិ (រូបនៅខាងស្តាំ) បានសម្តែងទស្សនៈអំពីកុមារកម្ពុជាមានឯកសិទ្ធិតិចក្នុងការអប់រំ។ នេះគឺជាព្រឹត្តិការណ៍រំភើបមួយសម្រាប់ភាពជាមេដឹកនាំរបស់អង្គការ ខេប និងក៏ជាការជំរុញទឹកចិត្ត ខេប ប្រឹងកែលម្អការអប់រំសម្រាប់ទាំងកុមារា និងកុមារី។ http://news.yahoo.com/us-first-lady-meets-cambodian-students-girls-education-045035719.html



### អង្គការ ខេប បានចុះអនុស្សារណៈយោគយល់គ្នាជាមួយក្រសួងអប់រំ យុវជន និងកីឡា

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥ អង្គការ ខេប បានចុះអនុស្សារណៈយោគយល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើការសាកល្បងគម្រោង សាលារៀនជំនាន់ថ្មីដែលជាកំណែទម្រង់ថ្នាក់ជាតិថ្មីមួយនៅសាលារាជធានីភ្នំពេញ។ ឯឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះក្នុងនាមក្រសួងអប់រំជាមួយលោក **សៅ វណ្ណា** ក្នុងនាមអង្គការ ខេប។ នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយនៅក្នុងប្រទេសកម្ពុជា បានបង្ហាញថា ជាលើកដំបូងហើយដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ប្រាក់អនុគ្រោះពន្ធដល់អង្គការសង្គមស៊ីវិលដើម្បីអភិវឌ្ឍការអប់រំ។ អង្គការ ខេប ជឿជាក់ថា នេះជាព្រឹត្តិការណ៍អទិភាពមួយដែលរដ្ឋាភិបាលធ្វើការអភិវឌ្ឍ និងពង្រឹងកិច្ចព្រមព្រៀងរវៀងរដ្ឋាភិបាល និងសង្គមស៊ីវិលដើម្បីលើកកម្ពស់កំណែទម្រង់វិស័យអប់រំ។

# ព្រឹត្តិការណ៍សំខាន់ៗ និងការអភិវឌ្ឍនៅក្នុងឆ្នាំនេះ

*“ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន ”*

## អង្គការ ខេប ទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីសាលាបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកកសិកម្ម និងបច្ចេកវិទ្យា ប្រទេសថៃ



នៅក្នុងកំឡុងពេលសាលាបណ្តុះបណ្តាលវិជ្ជាជីវៈកំពុងទទួលស្វាគមន៍ បុគ្គលិក និងសិស្សអាហារូបករណ៍របស់អង្គការ ខេប រួមជាមួយនឹងបុគ្គលិករបស់សាលាបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានអញ្ជើញចូលរួមថតរូបជុំគ្នាជាអនុស្សាវរីយ៍បន្ទាប់ពីពួកគេបានជួបសំណេះសំណាល និងចែករំលែកឱ្យគ្នាទៅវិញទៅមកប្រកបដោយភាពកក់ក្តៅ និងសេចក្តីសប្បាយរីករាយ។

អង្គការ ខេប ទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីសាលាបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកកសិកម្ម និងបច្ចេកវិទ្យា ខេត្តបុរីរាម នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៥។ អង្គការ ខេប បានចរចារជាមួយសាលាបណ្តុះបណ្តាលនេះប្រកបដោយភាពជោគជ័យ ដើម្បីផ្តល់អាហារូបករណ៏ដល់យុវជនកម្ពុជាចំនួន១០នាក់ទៀតនៅឆ្នាំក្រោយ ក្នុងកិច្ចសហការជាមួយរដ្ឋាភិបាលថៃ។ យុវជនកម្ពុជាដែលបានបញ្ចប់បិរញ្ញាប័ត្ររងរយៈពេល២ឆ្នាំបច្ចុប្បន្ននេះគឺរូបភាពអង្គុយខាងមុខ។ ជាសរុប អង្គការ ខេប បានឧបត្ថម្ភយុវជនកម្ពុជាចំនួន១១នាក់ទៅបន្តការសិក្សានៅប្រទេសថៃ ដែលបានមកពីការតស៊ូមតិរបស់អង្គការ ខេប រួមមានៈ ការស្នាក់នៅ និងថ្លៃសិក្សា។ សូមអរគុណច្រើនដល់ក្រុមមន្ត្រីគម្រោងអប់រំកុមារី (GEI) និងអង្គការមូលនិធិអ្នកទ្រទ្រង់ដែលបានធ្វើឱ្យមានឱកាសដ៏ល្អសម្រាប់យុវជនកម្ពុជា។

## កម្មវិធីរាត្រីជួបជុំមាតាបិតាសិស្ស





មាតាបិតាបានចូលរួមកម្មវិធីរាត្រីជួបជុំមាតាបិតាសិស្សដែលត្រូវបានរៀបចំឡើងដោយអង្គការ ខេប និងសាលាអនុវត្តក្នុងខេត្តកំពង់ចាម ដែលជាកន្លែងកូនៗរបស់ពួកគាត់ធ្វើបទបង្ហាញអំពីការអនុវត្តពិសោធន៍ជាក់ស្តែងក្រោយពេលសិក្សានៅក្នុងថ្នាក់រួច។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ អង្គការ ខេប បានធ្វើការយ៉ាងជិតស្និទជាមួយសាលាអនុវត្តដើម្បីរៀបចំកម្មវិធីរាត្រីជួបជុំមាតាបិតាសិស្ស។ ព្រឹត្តិការណ៏នេះបានចាប់ផ្តើមចេញពីការអនុវត្តរបស់សាលារដ្ឋដែលជាកន្លែងមាតាបិតាសិស្សជួបជុំគ្នាតាមធម្មតានៅពេលថ្ងៃ។ កម្មវិធីនេះធ្វើឡើងដើម្បីប្រាកដថា មានចំនួនអ្នកចូលរួមច្រើន។ ការរៀបចំកម្មវិធីយប់នេះមានមាតាបិតាចូលរួមច្រើនជាង ៣០០នាក់។ សាលាបានរៀបចំសកម្មភាពជាច្រើន ដូចជាៈ ការពិសោធន៍ ការសម្តែងល្ខោនខ្លីៗ និងចម្រៀងបង្ហាញដល់មាតាបិតាអំពីអ្វីដែលកូនៗរបស់ពួកគេកំពុងសិក្សា។ បន្ទាប់មក សិស្សបាននាំមាតាបិតារបស់ខ្លួនដើរមើលសាសារៀន និងជួបជាមួយលោកគ្រូអ្នកគ្រូនៅថ្នាក់រៀនពួកគេ។ កម្មវិធីនេះបង្កើតជាព្រឹត្តិការណ៏ច្នៃប្រឌិតថ្មីគំរូ ដែលជាមធ្យោបាយសម្រាប់សាលារៀនធ្វើការងារពាក់ព័ន្ធយ៉ាងជិតស្និទជាមួយមាតាបិតាសិស្ស។



លោកស្រី ជូលី ជុន បានទស្សនាសួនជីវៈដោយមានការទទួលស្វាគមន៍ពីសិស្ស និងបានស្តាប់ការពន្យល់របស់សិស្សអំពីការសិក្សានៅសាលារៀន។

## ទស្សនកិច្ចរបស់អនុរដ្ឋទូតសហរដ្ឋអាមេរិក

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ អង្គការ ខេប បានរៀបចំទទួលដំណើរទស្សនកិច្ចរបស់លោកស្រីអនុរដ្ឋទូតស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា នៅសាលាអនុវត្ត ដែលជាសាលាមួយក្នុងចំណោមសាលាគោលដៅរបស់អង្គការ ខេប ក្នុងក្រុងកំពង់ចាម។ ទស្សនកិច្ចនេះធ្វើឡើងដើម្បីសិក្សាអំពីការរីកចម្រើនពីអន្តរាគមន៍របស់អង្គការ ខេប តាមរយៈកម្មវិធីជាច្រើន រួមមានៈ គម្រោង កែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC) គម្រោង សាលារៀនដៃគូ (BSI) និងគម្រោងពង្រឹងសិទ្ធិអំណាចយុវជនតាមរយៈការអប់រំ និងការតស៊ូមតិ (EYEA)។ ការប្រតិបត្តិការដោយលក្ខណៈស្វ័យយ័ត សាលានេះបានក្លាយជាសាលារៀនធម្មនុញ (Charter School) ដំបូងនៅប្រទេសកម្ពុជា។

អំឡុងពេលទស្សនកិច្ច លោកស្រី **ជូលី ជុន** អនុរដ្ឋទូតស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជាមានចំណាប់អារម្មណ៏យ៉ាងខ្លាំងនឹងការបង្កើតថ្មី និងត្រេកអរដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកបានដើរតួនាទីមួយផ្នែកក្នុងការវិវត្តន៏នេះ។

# ព្រឹត្តិការណ៍សំខាន់ៗ និងការអភិវឌ្ឍនៅក្នុងឆ្នាំនេះ

*“ ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន ”*




*ក្រុមមន្ត្រីការងារកម្មវិធី SDPP នៅទីក្រុងវ៉ាស៊ិនតោន ឌីស៊ី*



*លោក ជា កុសល ធ្វើបទសម្ភាសន៍ជាមួយវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA)*

## ក្រុមការងារកម្មវិធី SDPP បានចូលរួមសន្និបាទ

អង្គការ ខេប បានបញ្ជូនបុគ្គលិកចំនួន៤រូបចេញពីកម្មវិធី SDPP រួមមាន៖ លោក **ជា កុសល** (ប្រធានសម្របសម្រួលប្រចាំប្រទេសកម្ពុជា) លោកស្រី **ឃៃរូល ទីលៀម** (អ្នកជំនាញស្រាវជ្រាវ និង M&E) លោក **ឡុក រដ្ឋា** (ប្រធានកម្មវិធី IMS) និងលោក **ជា ថា** (ប្រធានកម្មវិធី EMS) ដើម្បីចូលរួមសន្និបាទ CIES ២០១៥ នៅរដ្ឋធានីវ៉ាស៊ិនតោន ឌីស៊ី ក្នុងខែមីនា ឆ្នាំ២០១៥។ ក្រុមការងារនេះត្រួតពិនិត្យកម្មវិធី និងធ្វើបទបង្ហាញអំពីផលជះរបស់កម្មវិធី SDPP ទៅលើការបោះបង់ការសិក្សាសិស្ស។ ក្រុមការងារកម្មវិធី SDPP បានចូលរួមធ្វើបទបង្ហាញជាមួយអ្នកតំណាងកម្មវិធី SDPP ចំនួនបីប្រទេសទៀតរួមមាន៖ Timor Leste (បង្ហាញដោយអង្គការ Care) Tajikistan (បង្ហាញដោយអង្គការ Creative Associates) និងប្រទេសឥណ្ឌា។ លោក **កុសល** ត្រូវបានអញ្ជើញចូលរួមធ្វើបទសម្ភាសន៍ជាមួយវិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) នៅរដ្ឋធានីវ៉ាស៊ិនតោនថា អត្រាបោះបង់ការសិក្សាអនុវិទ្យាល័យក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ប៉ុន្តែដោយមានអន្តរាគមន៍ពីកម្មវិធី SDPP បានធ្វើឱ្យផលប៉ះពាល់នេះកាត់បន្ថយ។ ទស្សនកិច្ចនៅក្នុងសន្និបាទ CIES នេះគាំទ្រថវិកាដោយ USAID នៅរដ្ឋធានីវ៉ាស៊ិនតោន និងក៏ជាកិត្តិយសមួយសម្រាប់ក្រុមមន្ត្រីការងារអង្គការ ខេប ដែរ។



*លោក អ៊ុល រុន ទីប្រឹក្សាជាតិជាន់ខ្ពស់ពន្យល់អំពីផលិតផលគម្រោ E4K នៅលើតុពិពណ៌ អង្គការ ខេប ក្នុងរដ្ឋធានីវ៉ាស៊ីងតោន ឌីស៊ី។*

## អង្គការ ខេប ទទួលលបានថវិកាពីអង្គការ All Children Reading (ACR)

អង្គការ ខេប បានទទួលថវិកាចំនួន ២៤៣.000ដុល្លាអាមេរិកពីអង្គការ *All Children Reading Grand Challenge* សម្រាប់កម្មវិធីបង្កើតថ្មី (ឈ្មោះថា គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ ឬ E4K) ដើម្បីលើកម្ពស់អំណានថ្នាក់ដំបូង។ មានអង្គការចំនួនជាង ២៥0 បានដាក់ពាក្យស្នើសុំមូលនិធិ ហើយមានតែចំនួន១៥អង្គការប៉ុណ្ណោះ រួមមានអង្គការ ខេប ផងដែរដែលបានទទួលមូលនិធិនេះ។ មូលនិធិនេះនឹងធ្វើឱ្យអង្គការ ខេប អាចវិនិយោគក្នុងកម្មវិធីបង្កើតថ្មីពាក់ព័ន្ធនឹងការបង្កើតសៀវភៅសិក្សាភាសាខ្មែរតាមអេឡិចត្រូនិច និងក៏ជាលើកដំបូងហើយដែលអង្គការ ខេប សម្រេចបាន។ សៀវភៅនេះរៀបតាមកម្រិតសមត្ថភាព និងបញ្ចូលនូវលក្ខណៈទាក់ទាញយ៉ាងច្រើន។ ក្រុមមន្ត្រីការងារចំនួន៣រូបត្រូវបានអញ្ជើញទៅរដ្ឋធានីវ៉ាស៊ីងតោន ឌីស៊ី ដើម្បីរួមសម្ពោធគម្រោងជុំទី២នៃថវិការបស់អង្គការ ACR និងទទួលយកថវិកានេះជាផ្លូវការ។ រូបថតឈរខាងមុខ និងក្រោយ គឺលោក **អ៊ុល រុន** ទីប្រឹក្សាជាតិជាន់ខ្ពស់ លោក **ស៊ុំ វណ្ណៈ** ប្រ.ធនធានសិក្សា និងលោក **ឃីត ប្រាជ្ញរបើក** ទីប្រឹក្សាបច្ចេកទេស។




*លោក អ៊ុល រុន ធ្វើបទបង្ហាញនៅសន្និបាទក្នុងតំបន់របស់អង្គការឆាលហ្វាន់ ក្នុងក្រុងហាណូយ*

## កិច្ចប្រជុំក្នុងតំបន់របស់អង្គការឆាលហ្វាន

ដោយមានការអញ្ជើញពីអង្គការឆាលហ្វាន អង្គការ ខេប បានបញ្ជូលលោក **អ៊ុល រុន** ទីប្រឹក្សាជាតិជាន់ខ្ពស់ និងលោក **ហ៊ិន ស៊ីមហួន** នាយករងប្រតិបត្តិ ទៅចូលរួមសន្និបាទក្នុងតំបន់នៅក្រុងហាណូយរបស់បណ្តាប្រទេស ដែលមានការិយាល័យអង្គការឆាលហ្វានទាំងអស់ នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥។ អង្គការឆាលហ្វានបានធ្វើការផ្លាស់ប្តូរយុទ្ធសាស្ត្រដ៏ធំ ដើម្បីធ្វើការងារបន្ថែមទូលាយតាមរយៈដៃគូក្នុងស្រុក។ ដោយមានការពេញចិត្តកម្រិតខ្ពស់នឹងការងារអង្គការ ខេប ពីអង្គការឆាលហ្វាន អង្គការ ខេប ត្រូវអញ្ជើញធ្វើជាវាគ្មិនដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររបស់ខ្លួន និងការបង្កើតថ្មីៗ។ លោក **អ៊ុល រុន** បានធ្វើបទបង្ហាញនៅក្នុងសន្និបាទនេះ ហើយក៏បានចែករំលែកអំពីការផ្តើតថ្មីជាច្រើននាពេលបច្ចុប្បន្នរបស់អង្គការ ខេប។

# ព្រឹត្តិការណ៍សំខាន់ៗ និងការអភិវឌ្ឍនៅក្នុងឆ្នាំនេះ

*“ ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន ”*

## ការបង្កើតថ្មីក្នុងឆ្នាំ២០១៥

អង្គការ ខេប បានផ្លាស់ប្តូរយុទ្ធសាស្ត្រពីកម្មវិធីមួយទៅកម្មវិធីមួយទៀតដោយស៊ីជម្រៅ។ អង្គការ ខេប បានសម្រេចកិច្ចការជាច្រើនគួរឱ្យកត់សំគាល់ ដែលជាសក្តានុពលដើម្បីលើកកម្ពស់ការផ្លាស់ប្តូរប្រព័ន្ធអប់រំជាលក្ខណៈទូលំទូលាយ។ កិច្ចការទាំងនេះរួមមានដូចខាងក្រោមៈ



1. **ការអនុម័តគំរូសាលារៀនធម្មនុញ (Charter School) និងការអភិវឌ្ឍអប់រំដោយប្រើគំរូច្រើនបែបៈ** គម្រោងសាលារៀនដៃគូបានបង្កើតសាលាធម្មនុញគំរូនៅក្នុងប្រទេសកម្ពុជា ដែលបច្ចុប្បន្ននេះត្រូវបានអនុម័តដោយក្រសួងថាជាផ្នែកមួយនៃ***កម្មវិធីកំណែទម្រង់អប់រំថ្នាក់ជាតិ***។ គម្រោងនេះមានឈ្មោះថា ***សាលារៀនជំនាន់ថ្មី*** ផ្តួចផ្តើមឡើងដើម្បីលើកកម្ពស់ស្តង់ដាសិក្សាជាអតិបរមាដល់សាលារៀនរដ្ឋ ដែលផ្តោតទៅលើបច្ចេកវិទ្យា និងបំណិនសតវត្សទី២១នេះ។ គំនិតនេះក៏ជួយធ្វើឱ្យផែនការអភិវឌ្ឍមានច្រើនបែប ដូច្នេះ ការវិនិយោគមិនសំដៅតែទៅលើគំរូស្តង់ដាអប្បរមាតែមួយប៉ុណ្ណោះទេ។
2. **ជាដៃគូថ្មីជាមួយរដ្ឋាភិបាលក្នុងការអនុវត្តផ្ទាល់លើកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាៈ** ការសម្រេចចិត្តរបស់ក្រសួងអប់រំក្នុងការផ្តល់មូលនិធិផ្ទាល់ដល់អង្គការ ខេប ដើម្បីអនុវត្តកំណែទម្រង់តាមរយៈគម្រោងសាលារៀនជំនាន់ថ្មី គឺជាព្រឹត្តិការណ៍ផ្លាស់ប្តូរដ៏សំខាន់មួយ ដែលអង្គការក្នុងស្រុកធ្វើអន្តរកម្មជាមួយរដ្ឋាភិបាល។ ប្រសិនបើអង្គការ ខេប អាចបង្ហាញលទ្ធផលដែលមានគុណភាពខ្ពស់ និងការទទួលខុសត្រូវក្នុងការអនុវត្ត នោះនឹងផ្តល់នូវមធ្យោបាយដ៏សំខាន់ដល់កំណែទម្រង់អប់រំរបស់រដ្ឋាភិបាលដើម្បីទទួលបាននូវរបៀបនៃការអភិវឌ្ឍបែបថ្មី។



3. **ការអនុម័ត្ររូបមន្តកម្រិតអំណានភាសាខ្មែរៈ** តាមរយៈគម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ (E4K) អង្គការ ខេប បានអភិវឌ្ឍមូលដ្ឋានពិសោធន៏ជាក់ស្តែងតាមរយៈការបង្កើតអត្ថបទតាមកម្រិតសមត្ថភាព ដោយប្រើប្រាស់សំណេរអំណានដូចជា ពាក្យ និងប្រវែងល្បះ។ រូបមន្តនេះនៅក្នុងកម្មវិធីអភិវឌ្ឍកម្មវិធីសិក្សាបានធ្វើឱ្យអ្នកសរសេរសៀវភៅរបស់ក្រសួងអប់រំឈប់ប្រើវិធីពីមុនដើម្បីសរសេរសៀវភៅសិក្សាមកប្រើប្រាស់វិធីមួយដែលមានការវិភាគបែបប្រព័ន្ធដោយប្រើប្រាស់រូបមន្តស្តង់ដា។
4. **ការប្តូរសៀវភៅអំណានភាសាខ្មែរមកជាទម្រង់អេឡិចត្រូនិចដែលមានលក្ខណៈទាក់ទាញៈ** គម្រោង E4K ក៏បានជួយក្រសួងអប់រំផងដែរដើម្បីពិចារណាពីការប្តូរសៀវភៅសិក្សាភាសាខ្មែរទៅជាទម្រង់អេឡិចត្រូនិចដែលមានលក្ខណៈទាក់ទាញ។ ការបង្កើតសៀវភៅសិក្សាទាំងអស់នេះតាមទម្រង់អេឡិចត្រូនិច និងផែនការចែកចាយតាមរយៈបណ្តាញទីផ្សារនឹងជួយឱ្យប្រទេសកម្ពុជានាំមកនូវកម្មវិធីសិក្សាក្នុងសតវត្សទី២១នេះ។
5. **ការអនុម័តស្តង់ដាអំណានសម្រាប់ថ្នាក់ទី១ និងទី២:** អង្គការ ខេប និងអង្គការអប់រំពិភពលោកបានតស៊ូមតិសុំឱ្យក្រសួងអប់រំ យុវជន និងកីឡា អនុម័តស្តង់ដាអំណានថ្នាក់ជាតិដោយជោគជ័យ។ បច្ចុប្បន្ននេះរដ្ឋាភិបាលបានកំពុងបោះពុម្ពសៀវភៅស្តង់ដាអំណានចំនួនប្រមាណ ២០.000ក្បាលសម្រាប់ចែកចាយទូទាំងប្រទេស។ សៀវភៅស្តង់ដានេះនឹងជួយប្តូរការវិនិយោគអំណានថ្នាក់ដំបូងគំរូចាស់ទៅជាវិធីសាស្ត្រពង្រឹងអំណានផ្អែកលើយន្តការវាយតម្លៃដើម្បីជួយទ្រទ្រង់។
6. **សុពលភាពលើពិសោធន៏ប្រព័ន្ធរំលឹកជាមុនដែលជាវិធីមានប្រសិទ្ធភាពដើម្បីកាត់បន្ថយការបោះបង់ការសិក្សាៈ** កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សាបានអភិវឌ្ឍ និងបានធ្វើតេស្តពិសោធន៏ពីប្រសិទ្ធភាពប្រព័ន្ធរំលឹកជាមុន ជាវិធីមួយដើម្បីកាត់បន្ថយអត្រាបោះបង់ខ្ពស់ជាប្រវត្តិសាស្ត្រនៅកម្រិតអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា។ ការសាកល្បងនេះគឺជាជោគជ័យដ៏ធំ និ៎ងមានសក្តានុពលយ៉ាងសំខាន់សម្រាប់ជួយប្រទេសកម្ពុជាក្នុងការកាត់បន្ថយអត្រាបោះបង់ការសិក្សា។
7. **បណ្ណាល័យគំរូសតវត្សទី២១:** ដោយចាប់ដៃគូជាមួយអង្គការឆាលហ្វាន អង្គការ ខេប បានអភិវឌ្ឍគំរូដែលមានលក្ខណៈផ្លាស់ប្តូរថ្មីៗសម្រាប់សេវាកម្មបណ្ណាល័យនៅសាលាជនបទដែលដើរតួនាទីល្អជាងមុនដើម្បីរៀបចំការអប់រំ និងបច្ចេកវិទ្យាថ្មី។ គំរូថ្មីនេះបានរាលដាលលឿន និងអាចផ្លាស់ប្តូរទម្លាប់ និងទំហំវិនិយោគតាមបណ្ណាល័យសាលារៀន។



# ព្រឹត្តិការណ៍សំខាន់ៗ និងការអភិវឌ្ឍនៅក្នុងឆ្នាំនេះ

*" ការអភិវឌ្ឍតាមរយៈបណ្ដាញ និងនៅថ្នាក់មូលដ្ឋាន "*

## បច្ចុប្បន្នភាព ធនធានសិក្សា-ខេប

ធនធានសិក្សាខេបគឺជាសហគ្រាសសង្គមដំបូងគេនៅកម្ពុជា ដែលគាំទ្រការផលិតសម្ភារៈបង្រៀន និងរៀន (www.tts-kape.org)។ អង្គការ ខេប បានបង្កើតធនធានសិក្សា-ខេប តាមរយៈយុទ្ធសាស្ត្រអភិវឌ្ឍរយៈពេល៥ឆ្នាំរបស់ខ្លួនដើម្បីស្វែងរកមូលនិធិផ្សេងៗ និងជាមធ្យោបាយសម្រាប់រក្សានិរន្តរភាពសម្ភារៈបង្រៀន និងរៀន។ ធនធានសិក្សា-ខេប គឺជាដំណោះស្រាយនៅក្នុងការចំណាយផ្នែកទាំងពីរនេះ។

នៅឆ្នាំនេះ ធនធានសិក្សាបានទទួលការបញ្ជាទិញជាង ៣00.000ដុល្លាអាមេរិកក្នុងប្រតិបត្តិការលើសពីការរំពឹងទុក។ បច្ចុប្បន្ននេះ ធនធានសិក្សាបានសងបំណុលដែលខ្ចីពីអង្គការ ខេប រួចរាល់ ហើយបានចាប់ផ្ដើមផ្ដល់មូលនិធិដល់ប្រតិបត្តិការគម្រោងខ្លះរបស់អង្គការ ខេប ជាពិសេស គម្រោងសាលារៀនជំនាន់ថ្មី។ រហូតមកដល់ពេលនេះ ធនធានសិក្សាបានផលិតសម្ភារៈបង្រៀន និងរៀនជាភាសាខ្មែរចំនួន ៣៤មុខដោយជោគជ័យសម្រាប់សាលារដ្ឋ និងឯកជននៅក្នុងប្រទេសកម្ពុជា។ ដោយផ្ដោតលើសម្ភារៈបង្រៀន និងរៀន ធនធានសិក្សាបានបំពេញនូវកង្វះខាតមួយចំនួននៅក្នុងវិស័យអប់រំ ដោយមានការចូលរួមជាប្រព័ន្ធ។ បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា បានឯកភាពផ្លូវការលើល្បែងសិក្សាជាង២៦មុខ និងល្បែងសិក្សាដទៃ៨មុខទៀតកំពុងកែសម្រួល។ ធនធានសិក្សាក៏បានផ្ដល់វគ្គតម្រង់ទិសដល់សិក្ខាកាមសរុប ១.៥២៨នាក់ (ស្ត្រី ៨៣0នាក់) រួមមាន៖ នាយកសាលា គ្រូបង្រៀន និងអ្នកអប់រំក្នុងសហគមន៍នៅក្នុងឆ្នាំ២០១៥នេះ។ នៅឆ្នាំក្រោយនេះ ធនធានសិក្សានឹងពិចារណាពង្រីកការផលិតសូសវែរបញ្ចូលទៅក្នុងការអប់រំ៕

















ហិបសម្ភារៈបង្រៀន និងរៀនត្រូវបានស្នើទិញពីសាលារៀនរដ្ឋនៅទូទាំងប្រទេសមានការកើនឡើង។


សិស្ស និងសាលារបស់ពួកគេមានសេចក្ដីរីករាយទទួលបានសម្ភារៈបង្រៀន និងរៀនយកទៅប្រើប្រាស់។


មាតាបិតាសិស្សបានទិញសម្ភារៈបន្ថែមសម្រាប់ឱ្យកូនរបស់ពួកគាត់រៀននៅផ្ទះ។

សូមកុំភ្លេចចុច “LIKE” និង “Share” ទំព័រ Facebook របស់យើង: www.facebook.com/ttskape ។

# ការបង្ហាញផ្នែកហិរញ្ញវត្ថុ

## សាច់ប្រាក់ និងការចំណាយ

| សេចក្តីពណ៌នា | ចំនួនសាច់ប្រាក់ជាដុល្លារអាមេរិក (US$) |
|---|---|
| ចំណូលថវិកាសរុបក្នុងគម្រោងប្រចាំឆ្នាំ២០១៥ | ២.០៧៦.០៨២,៣៨ |
| សមតុល្យចុងគ្រាពីឆ្នាំ២០១៤ | ១៥៤.៩៦៦,៦៧ |
| ចំណូលការប្រាក់ | ៥៨៩,០០ |
| ទ្រព្យដែលអាចប្រើប្រាស់ក្នុងឆ្នាំ២០១៥ | ២.២៣១.៦៣៨,០៥ |
| សរុបថវិកាចំណាយប្រចាំឆ្នាំ២០១៥ | ២.០៩៣.១៦៤,៥០ |
| អត្រាប្រើប្រាស់ថវិកា | ៩៤% |

## និន្នាការទទួលថវិការ




## តើថវិកាជំនួយត្រូវយកទៅប្រើប្រាស់ដូចម្តេច?




## លំហូរចំណូលឆ្នាំ ២០១៥

| ម្ចាស់ជំនួយ | ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក |
|---|---|
| **SDPP**/USAID/Creative Associates International, Inc. (CAI) | ៧៦៩.២៤២,៨៧ |
| **REACH**/WeWorld | ៣៧២.១៦២,៥១ |
| **E2L**/ChildFund Cambodia | ១៩៦.៣៥៨,១២ |
| **QLE**/Save the Children (SC)/ Norwegian Agency for Development Cooperation (NORAD) | ១៥៥.៧៩៧,៧១ |
| **BSI**/The Oaktree Foundation (TOF)/ Breteau Foundation/Apple Corporation | ១៤៤.៤០៧,១២ |
| **GEI**/The Oaktree Foundation (TOF) | ១២៤.៩៦៦,៦៧ |
| **SfE**/Classroom of Hope (CoH)/ Global Development Group (GDG) | ១១៣.៣៧៥,០០ |
| **EAC**/Educate A Child (EAC)/Qatar Foundation/Aide et Action(AeA) | ៨៣.៧៣៦,៦២ |
| **E4K**/USAID/World Vision/DFAT | ៧៣.៣៩៣,២៨ |
| **CTSP**/The Asia Foundation (TAF) | ៥០.៦១៥,០៣ |
| **BfC**/USAID/The Asia Foundation (TAF) | ៣៨.៧១៧,៧៨ |
| **EYEA**/Work Precision Instruments (WPI)/Save the Children | ៣៦.៤១៤,០៩ |
| **PEI**/Lotus Outreach (LO) | ៣៩.៥០៧,១១ |
| **ISHS**/The Breteau Foundation (TBF) | ៨.០៩៣,៦៨ |
| **ការទទួលប្រាក់ចំណូលថ្មីឆ្នាំ២០១៥** | **២.២៣១.៦៣៨,០៥** |

## សេចក្តីថ្លែងអំណរគុណ!

ជូនសមុខឱ្យកុមារ គ្រូបង្រៀន ឪពុកម្តាយ និងក្រុមអ្នកទទួលផលទាំងនោះមកពីកម្មវិធីរបស់យើង អង្គការ ខេប សូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់សម្រាប់ការផ្តត់ផ្គង់របស់ពួកគេក្នុងឆ្នាំនេះ និងឆ្នាំមុនៗកន្លងមកៗ ហិរញ្ញវត្ថុ និងការផ្តត់ផ្គង់បានធ្វើឱ្យអង្គការ ខេប មានសេវាកម្មមានន័យគ្រប់គ្រាន់ៗ សូមអរគុណ!

# រចនាសម្ព័ន្ធអង្គការ ខេប ក្នុងឆ្នាំ២០១៥




| | | | | | |
|---|---|---|---|---|---|
| **App. Dp** | អ្នកអភិវឌ្ឍ App. | **EAC** | គម្រោង អប់រំកុមារ | **M&ES/RT** | មន្ត្រីជំនាញផ្នែកតាមដាន និងវាយតម្លៃ/គ្រូបណ្តុះបណ្តាលអំណាន |
| **AS** | អ្នកជំនួយការ | **EYEA** | គម្រោង ពង្រឹងសិទ្ធិអំណាចយុវជនតាមរយៈការអប់រំ និងការតស៊ូមតិ | **PA** | អ្នកជំនួយការកម្មវិធី |
| **BfC** | គម្រោង សៀវភៅសម្រាប់កម្ពុជា | **ICT in ES** | មន្ត្រីជំនាញទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មានវិទ្យាផ្នែកអប់រំ | **PC** | មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត |
| **BSI** | គម្រោង សាលារៀនដៃគូ | **IEP** | កម្មវិធីអប់រំបញ្ចូលគ្នា | **PED/DCD** | នាយកដ្ឋានបឋមសិក្សា/នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| **DPO** | មន្ត្រីបច្ចេកទេសថ្នាក់ស្រុក | **Illustrator** | អ្នកគូរគំនូរ | **RTL** | ប្រធានក្រុមស្រាវជ្រាវ |
| **E2L** | គម្រោង ងាយស្រួលរៀន | **KLS** | មន្ត្រីជំនាញផ្នែកភាសាខ្មែរ | **SDPP** | កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់ការសិក្សា |
| **E4K** | គម្រោង សៀវភៅអេឡិចត្រូនិចសម្រាប់ភាសាខ្មែរ | **M&EO** | មន្ត្រីកម្មវិធីផ្នែកតាមដាន និងវាយតម្លៃ (MIS) | **TL** | ប្រធានក្រុម |

ផ្នែកដឹកនាំ

◄····► ព្រួញមុខពីរ = ទំនាក់ទំនងជាមួយទីប្រឹក្សា

ប្រអប់ដាច់ៗ = ស្វ័យយ័តភាព។ SDPP គឺជាគម្រោងពាក់កណ្តាលស្វ័យយ័ត។ គណៈកម្មការគ្រប់គ្រងមូលនិធិសុខភាពមានស្វ័យយ័តភាពពេញលេញ។

**POs**** កម្មវិធី **IEP** មាន៖ គម្រោង អប់រំកុមារី (**GEI**) គម្រោង អាហារូបករណ៍សិស្សនៅសាកលវិទ្យាល័យ (**CTSP**) និងគម្រោង សេវាអប់រំជនជាតិព្នង (**PEI**)។ "POs" បង្ហាញអំពីមន្ត្រីទាំងអស់នៅក្នុងកម្មវិធី **IEP** ។

*សូមបញ្ជាក់ថា លំដាប់ថ្នាក់ក្នុងរចនាសម្ព័ន្ធខាងក្រោមផ្នែកដឹកនាំ ប្រធានផ្នែកនីមួយៗមិនត្រូវបានបញ្ចូលទៅក្នុងផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស/រដ្ឋបាល ដែលបានកំណត់ហើយនៅក្នុងបញ្ជីឈ្មោះ។